ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>**

**<u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩**

**សវនាការលើកទី៧៧**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

កញ្ញា ណាតាសា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតេអូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត *(Mr.William SMITH)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

លោក ចាន់ រ៉ាវុធ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ុនណា

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោក ការីម ខាន *(Mr. Karim KHAN)*

លោកស្រី ស៊ីលឃិ ស្ទូតហ្ស៊ីនស្គី

*(Ms. Silke STUDZINSKY)*

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JACQUIN)*

លោក ហ្វីលីព កាណូន

*(Mr. Philippe CANNONE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោក ការីម ខាន | អង់គ្លេស |
| លោកស្រី ជា លាង | ខ្មែរ |

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលមកក្នុងបន្ទប់សវនាការ)*

[០៩:០២:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគីដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមកិច្ចដំណើរការសវនាការនៅក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់ឈើរាងរង្វង់ក្រចកសេះ ដែលរៀបចំទុកសម្រាប់ជនជាប់ចោទនៅមុខអង្គជំនុំជម្រះ ទីនោះ។

*(ជនជាប់ចោទធ្វើដំណើរទៅកាន់ឈើរាងរង្វង់ក្រចកសេះ)*

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមអញ្ជើញសហព្រះរាជអាជ្ញាឡើងធ្វើសេចក្តីសន្និដ្ឋានតប បើសិនបើមាន ហើយអង្គជំនុំជម្រះសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាមួយម៉ោងនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានតបនេះ។

សូមអញ្ជើញ!

**លោក វីលៀម ស្មីត៖**

សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម ជាទីគោរព មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សាធារណជន ហើយនិងប្រជាពលរដ្ឋកម្ពុជាទាំងអស់។

ថ្ងៃនេះ យើងមានពេលវេលាខ្លី ដើម្បីឆ្លើយតបទៅនឹងបញ្ហាមួយចំនួន។ ដូច្នេះ យើងនឹងនិយាយសង្ខេបៗ ទាក់ទងទៅនឹងភ័ស្តុតាងនៅក្នុងសារណារបស់យើង។ ដូច្នេះខ្ញុំ យើងនឹងមានសារណាដោយ

សង្ខេប បន្ទាប់មកខ្ញុំនឹងជូនវេទិកាទៅដល់សហព្រះរាជអាជ្ញាជាតិដើម្បីនឹងបន្ត។ បន្ទាប់មកទៀត ខ្ញុំនឹងសម្ដែងនូវការសន្និដ្ឋានបន្ទាប់ទៅទៀត។

[០៩:០៥:១០]

អយ្យការបានពិនិត្យនូវកត្តាមួយចំនួនដែលមេធាវីលើកឡើងពីម្សិលមិញនោះ ហើយក្នុងការការពាររឿងក្ដីនេះ គាត់បានបញ្ជាក់នូវបញ្ហាមួយចំនួនដោយមិនផ្អែកទៅលើភ័ស្ដុតាង។ ទាក់ទងទៅនឹងបញ្ហានេះ សូមអង្គជំនុំជម្រះពិនិត្យមើលនូវសេចក្ដីសន្និដ្ឋានដែលដាក់ជូននៅឆ្នាំ២០០៨ ដែលទាក់ទងទៅនឹងសេចក្ដីសន្និដ្ឋានដែលមាន ២០០ទំព័រ ដែលមានលេខយោង-- សេចក្ដីផ្ដើមនៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ហើយនិងដែលមានចំណងជើង ហើយនិងអត្ថបទយោងរាប់ពាន់ដែលគាំទ្រអ្វីៗទាំងអស់ដែលយើងបាននិយាយអំពីរឿងក្ដីនេះ តាំងពីចំណុចចាប់ផ្ដើមរហូតដល់ទីបញ្ចប់នេះ។

អយ្យការ តំណាងអយ្យការមានសំណុំរឿងរបស់ខ្លួនច្បាស់ ហើយអង្គជំនុំជម្រះត្រូវតែពិនិត្យមើលរាល់ការលើកឡើងរបស់មេធាវីការពារ ដោយផ្អែកទៅលើភ័ស្ដុតាង និងឯកសារទាំងអស់ដែលមាន។ ឧទាហរណ៍ ដោយសង្ខេបមួយដែលទាក់ទងទៅនឹងមតិយោបល់របស់មេធាវីការពារនោះ ពីម្សិលមិញ មេធាវីការពារបានលើកឡើងថា នៅក្នុងសារណាសង្ខេបរបស់សហព្រះរាជអាជ្ញានេះ មិនមានពាក្យណាមួយ មិនមានប្រយោគណាមួយដែលទទួលស្គាល់ ការទទួលស្គាល់ដោយមានកម្រិតដែលជនជាប់ចោទបានផ្ដល់នោះទេ។ គាត់បានបញ្ជាក់ថា គាត់នឹងប្រកាន់ជំហរហ្នឹង ប៉ុន្តែគាត់ថា គាត់នឹងទទួលនូវគុណសម្បត្តិមួយចំនួនអំពីបញ្ហានោះ។

[០៩:០៧:០០]

អ៊ីចឹង យើងនិយាយពីបញ្ហានេះនៅពេលនេះ។ ប្រសិនជាយើងពិនិត្យមើលទំព័រទី៦ នៅក្នុងសារណាសង្ខេបរបស់ខ្ញុំ របស់យើងគឺ ជនជាប់ចោទបានឯកភាពទៅលើអង្គហេតុមួយចំនួន ដែលជាបទល្មើសមួយចំនួន។ គាត់ទទួលការទទួលខុសត្រូវជាមុខងាររបស់គាត់ថា មានអំណាចមួយ ហើយគាត់បានបញ្ជាកអំពីការសូមទោសចំពោះជនរងគ្រោះនិងក្រុមគ្រួសាររបស់គេ។ នេះជាចំណុចមួយដែលថាជាកត្តាស្ថានសម្រាលទោសរបស់គាត់ ប្រសិនបើគាត់មានពិរុទ្ធភាព។ ហើយយើងបាននិយាយនៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងហើយ ម្សិលមិញមេធាវីការពារនិយាយថា មិនមានពាក្យណាមួយម៉ាត់នៅក្នុងនោះទេ។ ដូច្នេះ មតិរបស់គាត់ដែលគាត់ថា អ្វីដែលសហព្រះរាជអាជ្ញានិយាយមិនពិតទាំងអស់នោះ ហើយគាត់បាននិយាយដោយមិនត្រឹមត្រូវ ហើយការដែលលើកឡើងនោះគឺមិនត្រឹមត្រូវទេ។ យើង

មាននិយាយយ៉ាងច្បាស់លាស់ទាំងអង្គហេតុ ហើយនិងនៅក្នុងសេចក្ដីយោង។

[០៩:០៨:០២]

តុលាការជ្រាបហើយថា សហព្រះរាជអាជ្ញា ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអះអាងដោយមេធាវីការពារថាៗយើងមិនបានលើកឡើងពីភ័ស្ដុតាងមួយចំនួនអំពីស្ថានសម្រាល។ ប៉ុន្ដែ យើងមិនចាំបាច់ថាគេត្រូវតែដាក់នៅក្នុងសារណាគេទេ ពីព្រោះមិនមែនជាការងារគេនៅក្នុងរឿងនោះ។ ដូច្នេះ ជំហររបស់សហព្រះរាជអាជ្ញា គឺដូច្នេះ។ អ៊ីចឹង មេធាវីការពារពីម្សិលមិញនោះ គាត់បានបញ្ជាក់ដោយមិនឆ្លើយឆ្លងទៅតាមភ័ស្ដុតាងឯកសារដែលមាន។ នៅក្នុងការជំនុំជម្រះនៅក្នុងសេចក្ដីសន្និដ្ឋានទាំងនេះដែលបានទទួលស្គាល់ថាជនជាប់ចោទបានសារភាពពីពិរុទ្ធភាពរបស់គាត់ទៅនឹងការចោទប្រកាន់ហ្នឹង។

នៅក្នុងប្រព័ន្ធខំមិនឡូ គឺមានករណីបែបនេះ។ ប៉ុន្ដែ យើងឃើញថា អ្វីដែលយើងឃើញពីម្សិលមិញនោះ មេធាវីការពារ គាត់បានលើកឡើងឲ្យដោះលែង។ ថាបើសិនជាជនជាប់ចោទបានសហការជាមួយអាជ្ញាធរ ប៉ុន្ដែបើវាមានលក្ខណៈភាពច្បាស់ថា តើមានន័យដូចម្ដេច?

ចំណុចមួយដែលត្រូវលើកឡើងថ្ងៃនេះគឺត្រូវកែតម្រូវៗ ថាតើជនជាប់ចោទរូបនេះបានណែនាំឲ្យមេធាវីរបស់គាត់ដែរឬទេ? ដើម្បីសុំឲ្យអះអាងសុំការលើកលែង ឬក៏ដោះលែងនោះ។ មេធាវីការពារអាចធ្វើការការពារតាមការណែនាំរបស់កូនក្ដី។ ប្រសិនបើមេធាវីការពារអះអាង ឬក៏ស្នើសុំឲ្យមានការលើកលែងនោះៗមានន័យថា គាត់បានធ្វើហួសពីអ្វី ពីព្រោះជនជាប់ចោទគាត់បានសារភាពពីពិរុទ្ធភាពរបស់គាត់។ ដូច្នេះ គឺជាការការពារមួយដែលមិនផ្ទុះបញ្ចាំងពីគោលដៅពិតប្រាកដ។ ដូច្នេះ យើងធ្វើការងារផ្អែកទៅលើសេចក្ដីសន្និដ្ឋានមួយដែលថាជនជាប់ចោទបានណែនាំដល់មេធាវីការពារ ដើម្បីឲ្យសុំការលើកលែងការចោទប្រកាន់នេះ។

ដូច្នេះ គេត្រូវកត់ ត្រូវតែដឹង ហើយមិនមានស្ថានសម្រាលចំពោះការកាត់ទោសនោះទេ ប៉ុន្ដែគាត់ធ្វើបែបនេះមែន គឺមិនមានកិច្ចសហការនោះទាល់តែសោះពីជនជាប់ចោទ។ ប៉ុន្ដែ ខ្ញុំយល់ថាមិនមែនជាករណីបែបនេះទេ ខ្ញុំគិតឃើញថាមេធាវីការពារបានធ្វើការការពារដោយមិនមានការទទួលការណែនាំពីជនជាប់ចោទ។ ចំណុចនេះត្រូវតែដោះស្រាយឲ្យបានច្បាស់មុននឹងបញ្ចប់សំណុំរឿងនេះ។ ប៉ុន្ដែ បើយើងមិនដោះស្រាយទេនោះ ថាតើជនជាប់ចោទប្ដូរគំនិតរបស់គាត់ គាត់អាចនឹងបាត់បង់នូវស្ថានសម្រាលទាំងអស់ដែលគាត់បានលើកឡើង ហើយគាត់នឹងប្ដឹងឧទ្ធរណ៍រឿងក្ដីនេះ ហើយគាត់និយាយថាមេធាវីមិនបានធ្វើតាមការណែនាំរបស់ខ្ញុំទេ ខ្ញុំនឹងសូមប្ដឹងឧទ្ធរណ៍ពីរឿងនេះ។

[០៩:១១:១៣]

ផ្ទុយទៅវិញ ប្រសិនបើយើងចេះតែបន្តទៅ ហើយឬក៏យល់ថាមេធាវីមិនបានធ្វើតាមការណែនាំរបស់ជនជាប់ចោទ ដែលថាជនជាប់ចោទគាត់បានសារភាពពីពិរុទ្ធភាពហើយ។ ពេលនោះ អង្គជំនុំជម្រះគឺត្រូវតែផ្ដល់ការទទួលស្គាល់ថា តើគាត់បានណែនាំឲ្យមេធាវីការពារកុំនិយាយអ្វីផ្ទុយពីរឿងនេះ។ ដូច្នេះជាកត្តាសំខាន់ដែលទាក់ទងទៅនឹងការកាត់ទោស។

សំណើរបស់ខ្ញុំនោះគឺថា សូមអង្គជំនុំជម្រះ សូមសួរទៅជនជាប់ចោទមុន ថាតើគាត់បានណែនាំឲ្យមេធាវីឲ្យស្នើសុំលើកលែងការចោទប្រកាន់ឲ្យដោះលែងហ្នឹងដែរឬទេ? កត្តាមួយទៀត តើការសារភាពពិរុទ្ធភាពជាស្ថានសម្រាលរបស់គាត់ដែរឬអត់? ថាតើជាចំណុចមូលដ្ឋានហ្នឹងដូចម្ដេច?

ចំណុចទីពីរទាក់ទងទៅនឹងខ្លឹមសារនៃសារណាសូមលើកលែងនោះ លើកលែងការចោទប្រកាន់នោះគឺថា យើងមិនមាន ដែលថាគាត់ៗមិនមានអំណាចខ្ពស់ មិនមែនជាមេដឹកនាំជាន់ខ្ពស់នោះទេ ហើយគាត់ទទួលបានការលើកលែងទោស ហើយមិនមានយុត្តាធិការជាតិសម្រាប់កាត់ទោសគាត់ទេ ហើយមិនមានភ័ស្តុតាងអំពីការបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ។ មេធាវីក៏បាននិយាយដែរថា គឺការការពារទាំងស្រុងដែលមានសម្រាប់គាត់ ដែលថាគាត់បានធ្វើបទល្មើសហ្នឹងដោយសារតែគោរពបញ្ជាទេ។

ដូច្នេះ មេធាវីអន្តរជាតិបានគាំទ្រមេធាវីជាតិរបស់គាត់ និយាយថា បាទៗ គឺអ្វីៗមានការប្រែប្រួល ហើយកូនក្ដីរបស់ខ្ញុំមិនបានសារភាពពីពិរុទ្ធភាពទេ ហើយមេធាវីបានពន្យល់សេចក្ដីសន្និដ្ឋានដើម្បីនិយាយអំពីស្ថានសម្រាលនោះគឺវាមិនច្បាស់ទាល់តែសោះ មានតែចំណុចមួយច្បាស់ទេ។ ពីការការពារពីម្សិលមិញនោះ គេបានស្នើសុំឲ្យលើកលែងការចោទប្រកាន់ដោះលែងជនជាប់ចោទ ហើយសូមស្នើទៅអង្គជំនុំជម្រះឲ្យសួរទៅជនជាប់ចោទថា តើមេធាវីទាំងពីររូបបានធ្វើតាមការណែនាំរបស់ជនជាប់ចោទដែរឬអត់?

[០៩:១៣:៤៦]

តុលាការជាទីគោរព, ការប្ដូរយុត្តិសាស្ត្រដោយមេធាវីការពារបែបនេះ ក្នុងដំណាក់កាលចុងក្រោយគឺមិនអាចទទួលយកបាននៅក្នុងគ្រប់តុលាការទាំងអស់ ហើយក៏តុលាការនេះមិនគួរទទួលយកដែរ។ ទាក់ទងទៅនឹងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារ ហើយនិងសហព្រះរាជអាជ្ញាបានធ្វើឡើងនោះ គឺថាអង្គជំនុំជម្រះអាចនឹងធ្វើសេចក្ដីសម្រេចផ្អែកទៅលើភ័ស្តុតាងនិងអង្គហេតុអ្វីៗដែលមាន។

លោក លោកស្រីចៅក្រម ជាទីគោរព, មេធាវី សហការីរបស់ខ្ញុំនឹងលើកឡើងអំពីការទទួលខុសត្រូវថាជនជាប់ចោទជាអ្នកទទួលខុសត្រូវខ្ពស់មែន ឬមិនមែនទាក់ទងទៅនឹងច្បាប់ ហើយខ្ញុំនឹងលើកឡើងអំពីការលើកលែងទោស ថាតើអនុវត្តបានក្នុងកម្រិតណានៅក្នុងតុលាការយើងនៅក្នុងករណី អ.វ.ត.ក តើអនុវត្តបាន ឬមិនបាន? គឺមិនបានទេ។ អ៊ីចឹង គឺថាមិនអាចលើកឡើងមកទេ គឺថាគប្បីតែលើកឡើងមួយខែក្រោយពីមានដីកាចោទប្រកាន់ គឺថាបានលើកឡើងមួយឆ្នាំកន្លះជាងឯណោះ។ គឺវិធាន៨៩ ដែលនិយាយពីបញ្ហានេះនៅក្នុងវិធានផ្ទៃក្នុង។

ចំពោះបញ្ហាបទឧក្រិដ្ឋតាមច្បាប់ជាតិថា តើអនុវត្តបាន ឬមិនបាន ដែលមេធាវីការពារបានលើកឡើងនោះ? មេធាវីការពារបានថា ការការពារនឹងបានទាំងស្រុង ពីព្រោះគាត់ថាបានធ្វើតាមបញ្ជារបស់មេទេ។ ប៉ុន្តែ នៅក្នុងវិធានផ្ទៃក្នុងត្រង់មាត្រា៨៩ គឺមិនអនុញ្ញាតទេ គឺថាអនុវត្តតាមបញ្ជារបស់ថ្នាក់លើមិនអាចយកមកធ្វើជារបាំងការពារខ្លួនទេ ចំពោះបទឧក្រិដ្ឋអន្តរជាតិនោះ។

ឥឡូវនេះ ខ្ញុំនឹងជូនវេទិកាទៅសហការីតំណាងអយ្យការ ដើម្បីគាត់ជម្រាបទាក់ទងទៅនឹងបរិបទមួយចំនួន ឆ្លើយតបទៅនឹងមេធាវីការពារ។ បន្ទាប់មក ខ្ញុំនឹងនិយាយអំពីករណីនៃការលើកលែងទោសដែលថាជាករណីដែលត្រូវលើកពិចារណាក្នុងពេលនេះដែរ។

[០៩:១៦:០៣]

**លោក ការីម ខាន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអន្តរាគមន៍តិចតួចមួយ បើសិនជាខ្ញុំមានការអនុញ្ញាត។

លោកលោកស្រី ចៅក្រម អយ្យការបានលើកឡើង ជាពិសេសនៅក្នុងសារណារបស់ក្រុមទីមួយនៃដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យតុលាការស្នើសុំ ដើម្បីឱ្យជនជាប់ចោទបំភ្លឺ ខ្ញុំសូម-- ដើម្បីឱ្យត្រឹមត្រូវតាមនីតិវិធី គឺថាអំណាចហ្នឹង គឺវាស្ថិតនៅក្នុង គឺជាសារណាឆ្លើយតបរបស់អយ្យការ ដើម្បីបង្ហាញឱ្យរូបភាពហ្នឹង វាចេញច្បាស់ ដើម្បីឱ្យអង្គជំនុំជម្រះពិចារណាថា តើការលើកឡើងខាងដើមរបស់អយ្យការថាតើគាត់អាចនឹងចោទសួរទៅជនជាប់ចោទបាន ឬមិនបាន? គឺថាគាត់ត្រូវតែមានការបំភ្លឺ ដើម្បីឱ្យមានការផលផ្តែផ្កាល្អ ដែលឆ្លើយតបទៅតាមសំណើរបស់អយ្យការ។ ប្រសិនបើយើងមិនធ្វើដូច្នេះទេ គឺយើងមានការគ្រោះថ្នាក់ អាចនឹងមានក្រោយពីមានការសន្និដ្ឋានរបស់អយ្យការ គឺថាបើក្រោយទៅគឺអយ្យការមិនមានអ្វីដែលជាសេចក្តីសន្និដ្ឋានបន្ថែមទេ ពីព្រោះមេធាវីការពារគេមានសេចក្តីសន្និដ្ឋានចុងក្រោយ។ ដើម្បីធានានៅគោលការយុត្តិធម៌ត្រូវធ្វើការសម្រេចបញ្ហានេះជាដំបូងសិន មុននឹងបន្ត។ ហើយសូមអភ័យ

ដែលខ្ញុំឡើងមានមតិកាត់បែបនេះ។

[០៩:១៧:៤១]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាជាតិ។

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន សូមគោរពអង្គសវនាការ។ ខ្ញុំនិងសហការីរបស់ខ្ញុំនឹងឆ្លើយតបទៅលើការលើកឡើងរបស់មេធាវីការពារក្តីនៅចំណុចមួយចំនួនដែលពាក់ព័ន្ធនឹងមន្ទីរស-២១។ ដូចខ្ញុំលើកឡើងពីមុនហើយ តួនាទីរបស់យើងជាព្រះរាជអាជ្ញា គឺស្វែងរកយុត្តិធម៌ជូនជនរងគ្រោះទាំងមូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈច្បាប់ និងដោយផ្អែកលើអង្គហេតុនានា។

កាលពីម្សិលមិញ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងហើយដែលថា យើងមិនប្រើប្រាស់សវនាការនេះជាវេទិកាទេ តែយើងប្រឹងប្រែង ស្វះស្វែងតាមរយៈសវនាការនេះ ដើម្បីស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់។ យើងសួរថា តើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរស-២១ នោះ ពិតជាមានកើតមានទេ? ហើយបើសិនជាកើតមែននោះ តើអ្នកណាជាអ្នកទទួលខុសត្រូវ? យើងត្រូវស្វែងរកតាមរយៈភ័ស្តុតាងដើម្បីមកធ្វើការអំណះអំណាងទាំងនេះ។

យើងបានដឹងច្បាស់ហើយថា យើងត្រូវតែស្វែងរកភ័ស្តុតាងទាំងអស់ ដើម្បីស្វែងរកយុត្តិធម៌ទាំងអស់ ទាំងជនរងគ្រោះ ទាំងជនជាប់ចោទ ក៏ដូចជាប្រយោជន៍ជាសាធារណៈដែរ។ តែផ្ទុយទៅវិញ ការលើកឡើងរបស់មេធាវីការពារក្តី បានលើកឡើងតែភ័ស្តុតាងសម្រាប់ដោះបន្ទុកកូនក្តីខ្លួនតែប៉ុណ្ណោះ។ គួរឲ្យចាប់អារម្មណ៍ដែរ ក្រោយពីបានស្តាប់នូវសេចក្តីសន្និដ្ឋានបញ្ចប់ចុងក្រោយរបស់មេធាវីការពារក្តី យើងហាក់ដូចជាមានចម្ងល់ជាច្រើនដោយហេតុថា ជនជាប់ចោទបានទទួលស្គាល់នូវអង្គហេតុដែលកើតឡើងនៅឡើងនៅមន្ទីរស-២១ ព្រមទាំងទទួលខុសត្រូវនូវឧក្រិដ្ឋដែលបានកើតឡើងនៅទីនោះ។

យើងបានស្តាប់មេធាវីការពារក្តី មិនបានលើកឡើងអំពីឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ទាល់តែសោះហើយ ឌុច បានបញ្ជាក់ថា ឌុច មិនត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅមន្ទីរស-២១ នោះទេ។ ដូច្នេះវាមានការផ្ទុយគ្នារវាងជនជាប់ចោទនិងមេធាវីការពារក្តី។ យើងសួរទៀតថា តើ ឌុច សុំឲ្យមានការបន្ធូរបន្ថយទោសតាមហេតុផលណាមួយ? ឬក៏សុំឲ្យមានការលើកលែងបទចោទមកលើខ្លួន? ឬក៏ឲ្យរួចខ្លួននៅក្នុងសាលក្រមដែលអង្គជំនុំជម្រះនឹងសម្រេចនៅពេលខាងមុខ។

ដោយផ្អែកលើយុត្តាធិការ យើងនឹងបកស្រាយដូចខាងក្រោម មេធាវីការពារមិនបានតវ៉ាថា ឌុច ជាអ្នកទទួលខុសត្រូវ ឬក៏ជាមេដឹកនាំជាន់ខ្ពស់នោះទេ។ ពេលសវនាការបឋម គឺមានការតវ៉ាតែក្រម ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ប៉ុណ្ណោះ។ ដូច្នេះ បើយើងពិនិត្យទៅលើវិធាន៨៩.២ នៃវិធានផ្ទៃក្នុង ពុំមានសិទ្ធិតវ៉ា ឡើយ ព្រោះពេលវេលា៣០ថ្ងៃបានកន្លងផុត ហើយមានន័យថាអញ្ញត្រកម្មនោះ មិនអាចទទួលយកបាន ឡើយ។

[០៩:២១:១២]

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនឹងបញ្ជាក់បន្ថែមថា ហេតុអ្វីបានជាជនជាប់ចោទរូបនេះ ស្ថិតក្នុង យុត្តាធិការរបស់ អ.វ.ត.ក? ឬក៏ជាមេដឹកនាំជាន់ខ្ពស់? ឬក៏ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត? ខ្ញុំនឹងបក ស្រាយនូវចំណុចទីពីររបស់ខ្ញុំនៅពេលក្រោយនេះ។

ចំណុចទីមួយ នៅចំពោះមុខសវនាការនេះ ក៏ដូចជាកាលពីម្សិលមិញ និងម្សិលម៉្ងៃនេះ គឺមេធាវី ការពារក្តីបានលើកឡើងអំពីថា ការអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦នោះ ស្តីពីការធ្វើមនុស្សឃាត និង ការធ្វើទារុណកម្មហ្នឹង គឺមិនត្រឹមត្រូវ ឬក៏វាផុតអាជ្ញាយុកាលហើយ។ សវនាការនេះ លោកមេធាវី ការពារក្តី មានលើកឡើងមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានកំណត់អាជ្ញាយុកាលនៃបទ ឧក្រិដ្ឋមានរយៈពេលដប់ឆ្នាំ។

ដូច្នេះ តាមការគណនាអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មដែលបានកើតឡើងត្រឹមថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ រហូតមកដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៨០ គឺមានអាជ្ញាយុកាលដប់ឆ្នាំ។ ហើយលើសពីនេះទៀត បានបន្ថែមរយៈពេល២០ឆ្នាំបន្ថែមទៀត នៅក្នុងច្បាប់ អ.វ.ត.ក ដែលបានពិភាក្សាគ្នានៅក្នុងឆ្នាំ២០០១ ហើយការពិភាក្សាគ្នានេះ នៅក្នុងឆ្នាំ២០០៤ ត្រូវបានបន្ថែមអាយុកាលដប់ឆ្នាំទៀត។ ដូច្នេះសរុបមក ច្បាប់ អ.វ.ត.ក ត្រូវបន្ថែមអាជ្ញាយុកាល៣០ឆ្នាំ ដូចដែលមានចែងក្នុងមាត្រា៣ នៃច្បាប់អង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា។

នៅក្នុងករណីខាងលើនេះ មេធាវីការពារក្តី បានស្នើដល់អង្គជំនុំជម្រះសាលាដំបូងប្រកាសថា បទល្មើសមនុស្សឃាត និងការប្រព្រឹត្តិទារុណកម្ម ដូចមានចែងនៅក្នុងមាត្រា៥០០ មាត្រា៥០១ និង មាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវផុតអាជ្ញាយុកាល ប៉ុន្តែសហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គ ជំនុំជម្រះសាលាដំបូងទទួលស្គាល់នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រង់មាត្រា៥០០ មាត្រា៥០១ និងមាត្រា ៥០៦ ដែលមានចែងនៅក្នុងមាត្រា៣ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[០៩:២៣:៣៦]

ដោយសារច្បាប់នេះ វាមាននីត្យានុកូលភាពអនុវត្តបាន ចំពោះអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ ដែលបានកើតឡើងនៅក្នុងក្របខ័ណ្ឌមន្ទីរស-២១ ដោយសារមូលហេតុដូចខាងក្រោម៖

ការពន្យារពេលនៃអាជ្ញាយុកាលរហូតដល់៣០ឆ្នាំនេះ បទមនុស្សឃាត និងទារុណកម្មដែលបានចែងក្នុងមាត្រា៥០០, ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលចែងនៅក្នុងមាត្រា៣ នៃច្បាប់ អ.វ.ត.ក យើងនេះ មិនបានរំលោភលើគោលការណ៍នីត្យានុកូលភាព ដូចដែលមានចែងក្នុងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ។ ពីព្រោះថា ការពន្យារអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាចំពោះការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនបានកែប្រែធាតុផ្សំណាជាមូលដ្ឋាននៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ទេ។

តែផ្ទុយទៅវិញ ការពន្យារអាជ្ញាយុកាលនៃបណ្តឹងអាជ្ញានេះ បានផ្តល់អំណាចឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជំនុំជម្រះជនជាប់ចោទ ដែលជាមេដឹកនាំកំពូល និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានប្រព្រឹត្តអំពើមនុស្សឃាត និងទារុណកម្ម នៃក្រមព្រហ្ម-ទណ្ឌឆ្នាំ១៩៥៦ ដូចដែលបានចែងក្នុងមាត្រា៣ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើងនេះ។

ចំណុចមួយដែរ គិតថាវាមិនផ្ទុយនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហទណ្ឌ។ ប្រតិសកម្មមានន័យថា ច្បាប់ព្រហ្មទណ្ឌ អំពើដែលបានកើតឡើងមុនពេលមានច្បាប់ចែង ហើយគេបានតាក់តែងច្បាប់ជាក្រោយដើម្បីដាក់ទោសអំពើទាំងនោះ។ ផ្ទុយទៅវិញក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានតាក់តែងឡើងមុនពេលអំពើល្មើសបានកើតឡើង។ នេះមានន័យថា ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ ដែលជាពលរដ្ឋម្នាក់រស់នៅក្នុងសង្គមកម្ពុជា ហើយបានរៀនសូត្រជ្រៅជ្រះជាសាស្ត្រាចារ្យ ពិតជាបានដឹង អំពីដឹងអំពីអត្ថិភាពនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ម្យ៉ាងវិញទៀត នេះជាការច្បាស់ណាស់ថាជនជាប់ចោទពិតជាបានដឹងមុនអនុភាពនៃច្បាប់នេះ នៅពេលដែលឧក្រិដ្ឋកម្មបានទាក់ទងនឹងមនុស្សឃាត និងទារុណកម្ម ដែលខ្លួនបានប្រព្រឹត្តនោះ ត្រូវបានចោទប្រកាន់។

លើសពីនេះទៅទៀត ទំហំនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត រួមមានអំពើមនុស្សឃាត និងអំពើទារុណកម្ម ដែលមានលក្ខណៈជាប្រព័ន្ធទៅលើអ្នកទោសជាងមួយម៉ឺនពីរពាន់នាក់ នៅមន្ទីរស-២១ ច្បាស់ណាស់ ពិតជាអាចព្យាករណ៍បានថា នឹងមានការចោទប្រកាន់ចោទឡើងប្រឆាំងនឹងអំពើរបស់

ខ្លួន។ ជាក់ស្តែង ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជារឿយៗបានដឹងអំពីលក្ខណ:ឧក្រិដ្ឋនៃរបប កម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា មានលក្ខណ:ឧក្រិដ្ឋបន្តិចម្តងៗ តាមរយ: ការជម្លៀសប្រជាជន ការដកហូតនូវកម្មសិទ្ធិឯកជន និងការសម្លាប់មនុស្សទាំងឈុតៗ ជាពិសេស ការបោសសម្អាតភូមិភាគនានា។

[០៩:២៧:០៣]

យើងសន្និដ្ឋានថា ជនជាប់ចោទកាំង ហ្កេកអ៊ាវ ហៅ ឌុច នេះពិតជាបានដឹងមុនចំពោះបទឧក្រិដ្ឋ មនុស្សឃាត និងទារុណកម្មនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានចោទប្រកាន់ នាពេលបច្ចុប្បន្ន កាល ដោយអនុលោមតាមមាត្រា៣ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ដូច្នេះ ការចោទប្រកាន់ទៅលើជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ពីបទអំពើមនុស្សឃាត និងទារុណកម្មនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនប៉ះពាល់គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ទេ។ ប៉ុន្តែ ការចោទប្រកាន់នេះ ត្រូវបានបន្តអាជ្ញាយុកាល ហើយការបន្តអាជ្ញាយុកាលនេះ មិនប៉ះពាល់ ធាតុផ្សំបទល្មើសជាមូលដ្ឋាននៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឡើយ។

ការផ្តល់ធម្មនុញ្ញភាពដល់មាត្រា៣នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយក្រុម ប្រឹក្សាធម្មនុញ្ញ។ យោងតាមគោលបំណងនៃស្មារតីចរចារវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាល កម្ពុជា បានដាក់បញ្ចូលបទល្មើសជាតិ និងបទល្មើសអន្តរជាតិ។

ជាចុងក្រោយ រាជរដ្ឋាភិបាលកម្ពុជា បានច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើង មួយនេះ ដែលទទួលបានការអនុម័តិពីសភា និងព្រឹទ្ធសភាជាតិ ដែលក្នុងនោះមានមាត្រា៣ បានសម្រេច បន្តអាជ្ញាយុកាលរហូតដល់រយ:ពេល៣០ឆ្នាំថែមទៀត។

លោក លោកស្រីជាចៅក្រម សូមពិនិត្យទៅលើសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញក្នុងសំណុំរឿង ០៤២/០០៥ ឆ្នាំ២០០១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ និងសេចក្តីសម្រេចលេខ០៣/០០៥ ឆ្នាំ២០០១ ក.ប.ធ.ច ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ បានសម្រេច និងអនុម័តស្តីពីការពន្យាអាជ្ញាយុកាលក្រម ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដូចដែលមានចែងក្នុងមាត្រា៣ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយសេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចស្ថាពរ និងបិទការតវ៉ា។

ដូច្នេះ ហើយមាត្រានេះ បានបញ្ជាក់ពីគោលបំណងអ្នកតាក់តែងច្បាប់ ទាំងរាជរដ្ឋាភិបាល និងអង្គ ការសហជាជាតិ ចង់ឲ្យមានការចោទប្រកាន់បទល្មើសតាមច្បាប់ជាតិដែរ។ ក្រុមប្រឹក្សាធម្មនុញ្ញនៃ

ព្រះរាជាណាចក្រកម្ពុជា បានសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមានន័យថា ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។ ការពិនិត្យធម្មនុញ្ញភាពនេះ គឺជាសមត្ថកិច្ចតែមួយគត់របស់ក្រុមប្រឹក្សាធម្មនុញ្ញ។

[០៩:៣០:១៥]

ចំណុចមួយទៀតដែរ គឺការទទួលយករបស់អង្គបុរេជំនុំជម្រះ។ បន្ទាប់មកបានទទួលបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំឲ្យបញ្ចូលបទល្មើសមនុស្សឃាត និងទារុណកម្មនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងបានចែងនៅក្នុងមាត្រា៣ នៃច្បាប់ អ.វ.ត.ក យើងនេះ អង្គជំនុំជម្រះបានសម្រេចដោយសំឡេងប្រាំលើប្រាំ បានន័យថា សំឡេងលើសលប់ដោយសម្រេចឲ្យដាក់បញ្ចូលបទល្មើសមនុស្សឃាត និងទារុណកម្មនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងមានចែងនៅក្នុងមាត្រា៣ នៃច្បាប់អ.វ.ត.ក នៅក្នុងសាលដីការបស់ខ្លួន។

ក្រៅពីនេះទៅទៀត ដោយអនុលោមទៅតាមមាត្រា៨៩ អនុវិធានទីពីរ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬសាលដីការបស់អង្គបុរេជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរកំណត់បទចោទ ប៉ុន្តែមិនអាចបញ្ចូលធាតុផ្សំនៃបទចោទបានឡើយ។ តាមស្មារតីនៃវិធាននេះ បានតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមនូវខ្លឹមសារដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏សាលដីការបស់អង្គបុរេជំនុំជម្រះ។

ផ្ទុយទៅវិញ តាមខ្លឹមសារនៃវិធាននេះដែរ ក៏មិនបានចែងអំពីអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលនៅបទល្មើសថ្មី ដូចមានចែងក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះឡើយ។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូង មិនមានសមត្ថកិច្ចផ្ដល់ធម្មនុញ្ញភាពលើច្បាប់ណាមួយបានទេ។

[០៩:៣២:០១]

ជាចុងក្រោយ ចុងបញ្ចប់ដែរ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីការពារក្ដី អំពីអញ្ញត្រកម្ម ដែលទាក់ទងនឹងការបន្តអាជ្ញាយុកាលនៃបទព្រហ្មទណ្ឌជាតិដែលអំពីមនុស្សឃាត ទារុណកម្ម និងដែលមានចែងនៅក្នុងមាត្រា៣ នៃច្បាប់ អ.វ.ត.ក ចោលទាំងស្រុង។

ចំណុចទីពីរ ដែលជាចំណុចឆ្លើយតបទៅនឹងយុត្តាធិការរបស់បុគ្គលជនជាប់ចោទ។ លោកមេធាវីការ សាវុត្ថ បានលើកឡើងជាសំណួរថាហេតុអ្វីបាន ឌុច តែម្នាក់ឯងដែលត្រូវមកយកកាត់ទោស ហើយនិងប្រធានគុកផ្សេងទៀត មិនត្រូវបានយកមកកាត់ទោស? មេធាវីការពារក្ដីលើកឡើងថា កូនក្ដីរបស់ខ្លួន

កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានជ្រើសរើសជាគោលដៅសម្រាប់រងថ្នបាក់។ ការលើកឡើងនេះអាចមើលឃើញថា មិនបានឆ្លងកាត់ពិនិត្យពិច័យទៅលើអង្គហេតុនៃរឿងក្តីនេះទេ។ មិនតែប៉ុណ្ណោះ វាគ្មានការពាក់ព័ន្ធនឹងដំណើរការនីតិវិធីនេះទាល់តែសោះ។ វាមិនមែនជារឿងដែលភ្ញាក់ផ្អើលពេកនោះទេ។ ដូចគ្នាដែរ គឺមានជនជាប់ចោទមួយចំនួននៅចំពោះមុខតុលាការដទៃទៀត បានអះអាងថា ខ្លួនទទួលរងនូវថ្នបាក់ ប៉ុន្តែលេសទាំងនេះត្រូវបានបរាជ័យជាបន្តបន្ទាប់។

ជាឧទាហរណ៍ ក្នុងករណីលូប៉ាំងហ្គា នៅចំពោះមុខតុលាការអន្តរជាតិ *អាយស៊ីស៊ី* (ICC) ជនជាប់ចោទបានលើកឡើងថា ការប្រគល់ខ្លួនឲ្យតុលាការនោះ ជាយុត្តិសាស្ត្រនៃការបន្លំបោកប្រាស់ជាផ្នែកមួយនៃរដ្ឋាភិបាលកុងហ្គោ ដោយប៉ុនប៉ងបង្វែរចេញពីអំពើអយុត្តិធម៌ពិតប្រាកដដែលបានកើតឡើង។ ប៉ុន្តែយើងសូមពិចារណាអ្វីដែលបានចោទប្រកាន់នេះ តើជនជាប់ចោទជាអ្នកទទួលរងថ្នបាក់មែនឬ? ជាធម្មតាអ្នកទទួលថ្នបាក់ ជាជនគ្មានកំហុស ឬមិនគួរត្រូវបានកាត់ទោសទេ តែត្រូវបានដៅឲ្យទទួលទោសចំពោះបទឧក្រិដ្ឋកម្មមួយ។

[០៩:៣៤:១១]

សហព្រះរាជអាជ្ញា សូមឲ្យលោកលោកស្រីជាចៅក្រម និងអង្គសវនាការទាំងមូលបែរមកពិនិត្យឡើងវិញលើករណីជនជាប់ចោទនៅចំពោះមុខយើងទាំងអស់គ្នាវិញ។ សវនាការនេះ អង្គជំនុំជម្រះពិនិត្យតែអង្គហេតុឧក្រិដ្ឋកម្មនៅមន្ទីរស-២១ មិនមែនពិនិត្យទៅលើឧក្រិដ្ឋកម្មទាំងអស់ដែលប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យនោះទេ។

សហចៅក្រមស៊ើបអង្កេតបានធ្វើបំបែកសំណុំរឿងស្តីពីឧក្រិដ្ឋកម្មនានា ដែលប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យទាំងមូល ចេញពីឧក្រិដ្ឋកម្មដែលកើតឡើងពីមន្ទីរស-២១ រួចហើយ។ ម្យ៉ាងទៀតតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត និងតាមសាលដីការបស់អង្គបុរេជំនុំជម្រះ គឺបញ្ជូនបទឧក្រិដ្ឋដែលទាក់ទិននឹងស-២១ ទៅជំនុំជម្រះនៅសាលាដំបូងតែប៉ុណ្ណោះ។

បើយើងពិនិត្យទៅលើអង្គហេតុស្តីពីឧក្រិដ្ឋកម្មមន្ទីរស-២១ មានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា មានជនរងគ្រោះជាងមួយម៉ឺនពីរពាន់នាក់ មានចាស់ មានក្មេង មានប្រុស មានស្រី មានជនបរទេស មានជនជាតិខ្មែរ ត្រូវបានចាប់មកឃុំឃាំងនៅទីនោះ ហើយមុននឹងយកទៅកម្ទេចចោលភាគច្រើនសុទ្ធតែទទួលរងនូវទារុណកម្មយ៉ាងព្រៃផ្សៃ អមនុស្សធម៌ជាទីបំផុត។

[០៩:៣៥:៣៩]

អង្គហេតុទាំងនេះ ត្រូវបានជនជាប់ចោទទទួលស្គាល់ថាពិតជាបានកើតមាននៅមន្ទីរស-២១ ហើយខ្លួនពិតជាមានកំហុសនូវការទទួលខុសត្រូវចំពោះជនរងគ្រោះទាំងនោះពិតប្រាកដមែន។ ដោយហេតុថា ខ្លួនដំបូងជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ ព្រមទាំងបានសុំធ្វើអភ័យទោស សុំធ្វើការអភ័យទោសពីក្រុមគ្រួសារនៃជនរងគ្រោះ នូវទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមក។

ផ្ទុយពីការលើកឡើងដោយលោកមេធាវី ការ សាវុត្ថ អង្គហេតុនៃរឿងក្តីនេះ បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ជនជាប់ចោទគឺជាមនុស្សម្នាក់ក្នុងជំពូកជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តអំឡុងរបបខ្មែរក្រហម ហើយគាត់ពិតជាធ្លាក់ចូលក្នុងយុត្តាធិការនេះ។ គាត់ជាជនដែលបង្កើតនូវឧក្រិដ្ឋកម្មដ៏សែនរន្ធត់នេះ តាមរយៈការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់។ ចំពោះមនុស្សដែលមនុស្សត្រូវបានគិតថា ជាសត្រូវនៅទូទាំងប្រទេស និងពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។

ដូចដែលយើងបានកត់សម្គាល់ក្នុងផ្នែកស្តីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយមន្ទីរសន្តិសុខប្រតិបត្តិការទូទាំងប្រទេស។ រចនាសម្ព័ន្ធសន្តិសុខ គឺជាបេះដូងនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបោសសម្អាតជាក់ស្តែង អ្នកដែលគេគិតថាជាខ្មាំង។ មន្ទីរស-២១ គឺជាមន្ទីរសំខាន់បំផុតក្នុងរចនាសម្ព័ន្ធនេះ ទោះបីជាភ័ស្តុតាងមិនបានបង្ហាញថាមន្ទីរនេះមិនមានតួនាទីត្រួតត្រាទៅលើមន្ទីរសន្តិសុខផ្សេងៗក៏ដោយ វាច្បាស់ណាស់ថា មន្ទីរនេះវាស្ថិតនៅលើគេបង្អស់នៃរចនាសម្ព័ន្ធសន្តិសុខ និងពិសេសតែមួយគត់ក្នុងចំណុចដូចខាងក្រោម៖

មន្ទីរនេះគឺជាមន្ទីរសន្តិសុខតែមួយគត់នៅក្នុងប្រទេស ដែលទំនាក់ទំនងផ្ទាល់ជាមួយនឹងគណៈអចិន្ត្រៃយ៍ ដែលមន្ទីរនេះបានផ្តល់យោបល់ និងអនុសាសន៍ដោយផ្ទាល់អំពីការបោសសម្អាតខ្មាំង។

សូមពិនិត្យទៅលើឯកសារដែលមានអក្សរ D លេខ 16។ មន្ទីរនេះ ក៏ជាមន្ទីរសន្តិសុខតែមួយគត់ដែលមានភារកិច្ចក្នុងការចាប់ខ្លួនសួរចម្លើយ ប្រហារជីវិតកម្មាភិបាលដឹកនាំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ និងស្ថាប័នរដ្ឋបាលនានា និងកងទ័ពបដិវត្តន៍កម្ពុជា និងការិយាល័យស្រុក តំបន់ និងភូមិភាគនានា។

ហើយនៅក្នុងនេះ ក៏មាននៅក្នុងប្រតិចារឹកនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៤៥។ តាមពិតវាក៏ប្រតិបត្តិការមួយ សម្រាប់ឧបករណ៍មួយបោសសម្អាតរចនាសម្ព័ន្ធខ្លួនឯងផងដែរ។ នេះជាចម្លើយជនជាប់ចោទ ដែលមាននៅក្នុងឯកសារ E3/41។ ឌុច បានផ្តួចផ្តើមជ្រោមជ្រែងឲ្យមានការចាប់ខ្លួន និង

កម្មេចខ្លួនអ្នកនៅក្រោមបង្គាប់របស់ខ្លួនជាច្រើនរយនាក់នៅមន្ទីរស-២១ និងបង្កើតកន្លែងថ្មីមួយទៀតសម្រាប់សម្លាប់ជនរងគ្រោះដែលហៅថា ជើងឯក។ មនុស្សទាំងនេះ បើសិនគ្មានការជ្រោមជ្រែងពី ឌុច ទេ នោះថ្នាក់លើមិនដឹងពីទោសកំហុសរបស់បុគ្គលទាំងនោះឡើយ ហើយក៏គ្មានការចាប់ខ្លួន និងសម្លាប់អ្នកទាំងនោះដែរ។ ករណីនេះ ឌុច ក៏បានទទួលស្គាល់ដែរថា រាល់ការស្នើសុំរបស់គាត់ទៅថ្នាក់លើមិនដែលមានការបដិសេធទេ។ ការណ៍នេះបង្ហាញឲ្យឃើញថា ឌុច ជាអ្នកមានអំណាចដ៏ធំធេងក្នុងការសម្រេចលើវាសនាកូនចៅរបស់ខ្លួន ដោយមិនអាចប្រកែកបានឡើយ។

[០៩:៣៩:៣១]

វាផ្ទុយទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី ដែលអះអាងថា កូនក្តីរបស់ខ្លួនគ្មានអំណាចក្នុងការចាប់ជនណាម្នាក់ឡើយ។ តាមចម្លើយសាក្សីរបស់ ហ៊ឹម ហ៊ុយ ដែលមានឯកសារ D19/4 បានឆ្លើយថា ជនជាប់ចោទមានពេលខ្លះ ឌុច បានទៅចាប់អ្នកទោសដោយផ្ទាល់តែម្តង។

មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខតែគត់ ក្នុងកម្ពុជាប្រជាធិបតេយ្យដែលមានវិសាលភាពប្រតិបត្តិការទូទាំងប្រទេស និងមានការជ្រៀតចូលគ្រប់ថ្នាក់ទាំងអស់នៃរបបនេះ។ មន្ទីរនេះបានផ្តល់យោបល់និងសម្របសម្រួលការបោសសម្អាតយ៉ាងទូលំទូលាយជាមួយនឹងរដ្ឋអំណាចផ្នែករដ្ឋបាល និងយោធាទូទាំងប្រទេសកម្ពុជា។ មន្ទីរនេះ ទទួលអ្នកទោសពីគ្រប់ក្រសួងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ រួមទាំងក្រសួងសាធារណការ ក្រសួងពាណិជ្ជកម្ម ក្រសួងថាមពល ក្រសួងការពារជាតិ ក្រសួងការបរទេស និងក្រសួងសង្គមកិច្ច។ មន្ទីរនេះ បានប្រើប្រាស់ធនធានយ៉ាងទូលំទូលាយនិងបានបង្កើតនូវទម្រង់ការដ៏ប៉ិនប្រសប់បំផុតសម្រាប់ដំណើរការ និងការសួរចម្លើយអ្នកទោស ក្នុងចំណោមមន្ទីរបែបនេះទាំងអស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

មន្ទីរស-២១ ក៏ជាមន្ទីរសន្តិសុខរបស់របបកម្ពុជាប្រជាធិបតេយ្យដ៏ធំបំផុតដែរ។ បើនិយាយអំពីចំនួនបុគ្គលិកដែលមានរហូតដល់ជាងពីរពាន់នាក់ដែលគ្មានមន្ទីរសន្តិសុខណាមួយ ឬគុកណាមួយនៅទូទាំងប្រទេស មានបុគ្គលិកច្រើនដូច្នេះទេ។ មន្ទីរស-២១ ទទួលអ្នកទោសឈ្លើយសឹក អ្នកទោសជាជនបរទេសដែលចាប់បានផ្ទាល់។

ឧទាហរណ៍ ជនបស្ចិមបរទេសមួយចំនួនដែលបានចាប់មកពីសមុទ្រកំពង់សោម នៅខេត្តកំពង់សោម ក៏ត្រូវបញ្ជូនត្រង់មកមន្ទីរស-២១ ដែរ។ នេះមិនមែនបញ្ជូនទៅតំបន់ ឬក៏គុកស្វយ័ត នៅក្នុងកំពង់សោមជាមុននោះទេ។ ដូច្នេះ វាច្បាស់ណាស់ថា មន្ទីរស-២១ ពិតមានសិទ្ធិអំណាចធំជាងគេ ជាងមន្ទីរ

សន្តិសុខដទៃទៀត និងលាតសន្ធឹងទូទាំងប្រទេស។

លក្ខណៈពិសេសរបស់មមន្ទីរស-២១ ផ្ទុះបញ្ចាំងអំពីសារសំខាន់ដែលរបបនេះយល់ឃើញ ជាពិសេស មន្ទីរនេះត្រូវបានគេបង្កើតឡើងដើម្បីផ្តោតទៅលើខ្មាំង ដែលក្តីបារម្ភដ៏ធំបំផុតនៅក្នុងក្រខ្សែភ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរបំផុត ចំពោះការរស់រានរបស់បក្សកុម្មុយនីស្តកម្ពុជា។ ស្របតាមរបៀបអនុវត្តប្រតិបត្តិការនៃកម្ពុជាប្រជាធិបតេយ្យ មន្ទីរស-២១ បានប្រតិបត្តិការដោយរក្សាភាពសម្ងាត់កម្រិតខ្ពស់បំផុត។ ដូច្នេះ សូម្បីតែឆ្មាំគុកដែលនៅក្នុងបរិវេណធំក៏មិនបានអនុញ្ញាតឲ្យដើរចេញទៅក្រៅបរិវេណនោះដែរ។ តាមពិតភាពសម្ងាត់នៅមន្ទីរស-២១ បានក្លាយទៅជាមូលហេតុបន្ថែមមួយទៀត សម្រាប់ការសម្លាប់បុគ្គលគ្រប់រូបដែលត្រូវបានឃុំឃាំងនៅមន្ទីរស-២១ ពីព្រោះតម្រូវការរក្សាភាពសម្ងាត់ត្រូវបានអនុវត្តន៍យ៉ាងយកចិត្តទុកដាក់។

[០៩:៤២:៥៧]

ជនជាប់ចោទបានជួយបង្កើត និងបន្ទាប់មកបានគ្រប់គ្រងមន្ទីរស-២១ ឲ្យដំណើរការបានយ៉ាងរលូន ដោយមានការបង្កឲ្យមានឧក្រិដ្ឋកម្មដ៏សែនរន្ធត់នៅទីនោះ។ ដូច្នេះហើយ មានចម្ងល់ថា តើមេធាវីការពារក្តី លោក ការ សាវុត្ថ អាចធ្វើរបៀបណាដើម្បីឲ្យអង្គជំនុំជម្រះជឿថា កូនក្តីរបស់ខ្លួនមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនោះ? លោក ការ សាវុត្ថ បានអះអាងថា កូនក្តីរបស់ខ្លួនពុំត្រូវទទួលខុសត្រូវចំពោះជនរងគ្រោះ ដោយហេតុថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ ព្រោះកូនក្តីរបស់ខ្លួនធ្វើតាមបញ្ជារបស់បក្ស។ បើអនុវត្តតាមបញ្ជារបស់បក្សទេ គឺត្រូវរងគ្រោះខ្លួនឯងជាពុំខាន។ ហើយបានលើកឡើងទៀតថា កូនក្តីរបស់ខ្លួនមិនមែនជាអ្នកដឹកនាំជាន់ខ្ពស់ ឬក៏ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ ចំពោះឧក្រិដ្ឋកម្មនោះឡើយ។ ការលើកឡើងនេះគ្រាន់តែជាលេសមួយដើម្បីឲ្យកូនក្តីខ្លួនរួចពីខុសត្រូវតែប៉ុណ្ណោះ។ ការពិតជនជាប់ចោទរូបនេះ ពិតជាមេដឹកនាំ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនូវឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងមន្ទីរស-២១។

តួនាទីរបស់ជនជាប់ចោទ ជាលេខានៅមន្ទីរស-២១ ដែលត្រូវបំពេញការងារចាត់ចែង និងការគ្រប់គ្រង ការចាប់ខ្លួន ការធ្វើទារុណកម្ម និងមនុស្សឃាតរាប់ពាន់នាក់ដែលបានចាត់ទុកថាជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ដែលបង្ហាញឲ្យឃើញថា ជនជាប់ចោទគឺមេដឹកនាំជាន់ខ្ពស់មួយរូប និងជាមនុស្សម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវបំផុត ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុង

អំឡុងពេលនៃយុត្តាធិការរបស់ អ.វ.ត.ក។

[០៩:៤៩:៥៥]

ជាចុងក្រោយនេះដែលជាចំណុចដែលខ្ញុំចង់លើកឡើង គឺអំពីការលើកឡើងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ។ មេធាវីបានលើកឡើងថា កូនក្តីខ្លួនមិនបានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធនៅមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ទេ។ នេះជាការលើកឡើងមិនត្រឹមត្រូវឡើយ ព្រោះថាជនជាប់ចោទចាំបានថា សុន សេន បាននិយាយអំពីជម្លោះប្រដាប់អាវុធព្រំដែនរវាងកម្ពុជា-វៀតណាមនៅខេត្តមណ្ឌលគីរី គាត់ក៏មានការសារភាពថា សុន សេន បានចេញពីភ្នំពេញនៅក្នុងខែសីហា ទី១៥ សីហា ឆ្នាំ១៩៧៧ ដើម្បីជួយធ្វើសង្គ្រាមប្រឆាំងវៀតណាម ដោយ នួន ជា ជាអ្នកមកជំនួស សុន សេន លើការពិនិត្យរាល់ចម្លើយសារភាពនៅមន្ទីរស-២១ វិញ។

ដូច្នេះ សូមលោក លោកស្រីជាចៅក្រមពិនិត្យទៅលើឯកសារ E1/30.1 ឬក៏ ERN 003398 30។ សុន សេន បានចេញទៅសមរភូមិមុនថ្ងៃ១៥ សីហា ឆ្នាំ១៩៧៧ ព្រោះថា នួន ជា បានកោះហៅឌុច នៅថ្ងៃទី១៥ ខែសីហា ១៩៧៧។ ដូច្នេះ សុន សេន ពិតជាបានចេញមុននៅពេលថ្ងៃដែលបានកោះហៅនេះ។

អំឡុងពេលសវនាការ សហការីរបស់ខ្ញុំលោក វាលៀម ស្មីត ក៏បានសួរបញ្ជាក់ផងដែរទៅលើជាប់ចោទពីបញ្ហានេះផងដែរ ហើយជនជាប់ចោទនៅតែយល់ស្របទៅនឹងចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ បើទោះជាជនជាប់ចោទហាក់ដូចជាពុំបានចាំពេលណាគាត់បានដឹងអំពីជម្លោះប្រដាប់អាវុធក្តី ក៏ការដឹងរបស់គាត់អំពីជម្លោះនេះក្នុងពេលនោះ អាចត្រូវបានសន្និដ្ឋានតាមរយៈការចាប់ខ្លួន និងការឃុំខ្លួនឈ្លើយសឹកវៀតណាមនៅមន្ទីរស-២១ ចាប់តាំងពីដើមឆ្នាំ១៩៧៦។

អ្នកទោសចំនួន៩នាក់ត្រូវបានចាប់ខ្លួននៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ ក្រោយពីការប្រទះឃើញនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យនៅតំបន់២៥។ ដូចបានបង្ហាញតាមរយៈហត្ថលេខារបស់ជនជាប់ចោទរួចស្រេចហើយ ជនជាប់ចោទពុំត្រឹមតែបានទទួលយកអ្នកទោសក្នុងខែមេសា ឆ្នាំ១៩៧៦ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានសង្ខេបនូវចម្លើយសារភាពរបស់អ្នកទោសនៅទីនោះទៀតផង។ អំពើខុសច្បាប់របស់ពួកគាត់ទាក់ទិននឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមទៀតផង។ ក្នុងការសង្ខេបចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាមពីរនាក់។ ជនជាប់ចោទបានរៀបរាប់អំពីផែនការ

របស់អ្នកដែលបានចូល ហើយនិងត្រូវបានចាប់ខ្លួនចូលមកប្រទេសកម្ពុជា។

អង្គសវនាការបានស្តាប់រួចមកហើយនូវអ្វីដែលជនជាប់ចោទលើកឡើង។ នៅពេលសវនាការពីម្សិលមិញ ម្សិលម៉្ងៃយើងឃើញថា នៅចុងបញ្ចប់ជនជាប់ចោទបានថ្លែងនូវវិប្បដិសារី និងទទួលកំហុសរបស់ខ្លួនចំពោះជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ តែផ្ទុយទៅវិញត្រង់ចំណុចនេះ និងព្រឹត្តការណ៍ទាំងឡាយដែលគាត់បានលើកឡើងខាងដើមនេះគឺសុទ្ធតែខ្លឹមសារដើម្បីដោះបន្ទុកនូវអំពើឧក្រិដ្ឋរបស់គាត់។

[០៩:៤៨:៣១]

គាត់មិនបានបង្ហាញនូវការសហការដោយទូលំទូលាយនោះទេ។ ប៉ុន្តែ យើងទទួលស្គាល់នូវការសហការមួយផ្នែកដែលជាផលប្រយោជន៍នៅសំណុំរឿងក្រោយ។ គាត់កំពុងតែព្យាយាមបង្ហាញថាខ្លួនគាត់ គឺជាមនុស្សដែលគ្មានពិរុទ្ធភាពចំពោះបទល្មើសទាំងឡាយដែលបានចោទប្រកាន់ទៅលើរូបគាត់។ បើទោះជាគាត់និយាយហើយនិយាយទៀតថា គាត់ទទួលខុសត្រូវទាំងផ្លូវច្បាប់ ទាំងផ្លូវចិត្តចំពោះវិញ្ញាណក្ខន្ធជនរងគ្រោះ និងក្រុមគ្រួសារនៃជនរងគ្រោះក៏ដោយ។ បើសិនជាជនជាប់ចោទនៅតែមិនកែប្រែនៅការសារភាពរបស់ខ្លួន ហើយបានផ្តល់នូវការសហការមួយចំពោះតុលាការដោយស្មោះត្រង់នោះទេ។ យើងជឿថា ជនជាប់ចោទមិនអាចទទួលបាននូវការអត់ឱនទោសពីជនរងគ្រោះ និងក្រុមគ្រួសារជនរងគ្រោះបានឡើយ។

ជាចុងក្រោយនេះ នាងខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះពិចារណាលើអ្វី ដែលយើងខ្ញុំបានដាក់ជូននេះ ហើយធ្វើការសម្រេចសេចក្តីដ៏យុត្តិធម៌ដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ជនរងគ្រោះដោយសារអំពើដ៏អមនុស្សធម៌របស់ជនជាប់ចោទ។ ហើយជាបន្តទៅទៀតនេះ សហការីរបស់ខ្ញុំនឹងធ្វើការសន្និដ្ឋានបន្ថែមទៅលើចំណុចមួយចំនួនទៀត។ សូមអរគុណ។

**លោក វាឡៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តីបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានដោយលើកឡើងដោយប្រយោលថា ជនជាប់ចោទរូបនេះគួរតែកាត់ឲ្យរួចខ្លួន។ ទីពីរ ប្រសិនបើមិនកាត់ឲ្យរួចខ្លួនទេនោះ មេធាវីការពារក្តីបានដាក់ជូនថា គាត់សុំឲ្យការដាក់ទោសត្រឹមតែ១៧ឆ្នាំ ទៅ២០ឆ្នាំបានហើយដោយពិចារណាទៅលើជនជាប់ចោទរូបនេះ។ ប៉ុន្តែ នៅពេលដែលយើងពិចារណា អំពីភាពធ្ងន់ធ្ងរ និងទំហំធំធេងនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង ហើយនិងការរៀបចំបង្កការឈឺចាប់ធ្ងន់ធ្ងរទៅដល់ជនរងគ្រោះចំណុចនេះគឺជាការមិនទទួលខុសត្រូវគ្រប់គ្រាន់ទេ បើសិនជាយើងសុំឲ្យមានការដាក់ទោសបែបនោះ

តាមយុត្តិសាស្ត្រអន្តរជាតិ ដែលចែងអំពីជនជាប់ចោទប្រព្រឹត្តទៅលើឧក្រិដ្ឋកម្មដែលមានទំហំធំបែបនេះ។

លោក លោកស្រីចៅក្រម, ជាការគាំទ្រទៅលើសំណើ មេធាវីការពារក្តីលើកឡើងរឿងក្តី អុប្រេិណូវិច និង អាល់បឺត ស្ពៀរ។ ខ្ញុំធ្វើការនៅតុលាការអតីតប្រទេសយូហ្គោស្លាវី ខ្ញុំយល់ច្បាស់ណាស់អំពីរឿងក្តីទាំងពីរនេះ គឺ អុប្រេិណូវិច វាជារឿងក្តីខុសគ្នាតែម្តង ទៅនឹងរឿងក្តីរបស់ជនជាប់ចោទរូបនេះ។

[០៩:៥១:៣៩]

នៅក្នុងរឿងក្តីនោះ អុប្រេិណូវិច គឺជាមន្ត្រីយោធាដែលមានអត្តចរិតដ៏ល្អមុនពេលសង្គ្រាម ប៉ុន្តែខុសពីជនជាប់ចោទរូបនេះ ដែលគាត់បានប្រព្រឹត្តអំពើទារុណកម្មអស់រយៈពេលបួនឆ្នាំជាង នៅមន្ទីរម-១៣។ ដូចដែលអស់លោក លោកស្រីចៅក្រមជ្រាបហើយនូវអ្វីដែល ហ្វ្រង់ស្វ័រ ប៊ីហ្សូ គាត់បានលើកឡើងថា ជនជាប់ចោទគាត់បានលើកឡើងថា គាត់មិនអាចទ្រាំបានទេៗ គាត់វ៉ែវហួតដល់គាត់ដង្ហក់ខ្យល់។ ហើយ អុប្រេិណូវិច មិនមែនជាជនដូចជនជាប់ចោទរូបនេះទេ។ គាត់មិនបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មមុនពេលសង្គ្រាមឡើយ។ ហើយឧក្រិដ្ឋកម្មដែល អុប្រេិណូវិច ចោទប្រកាន់នោះគឺទាក់ទងនឹងឧក្រិដ្ឋកម្មនៅ ស្រ៊ុប្រេនីហ្សា នៅក្នុងប្រតិបត្តិការយោធាដែលវាកើតឡើងរយៈពេលជាងបីថ្ងៃ។ ហើយ អុប្រេិណូវិច មិនបានចូលរួមនៅក្នុងប្រតិបត្តិការនោះដោយសកម្មទេ គាត់គ្រាន់តែមានភាពអសកម្ម ហើយឲ្យកូនចៅរបស់គាត់ប្រព្រឹត្តទៅលើអំពើទាំងអស់នោះនៅពេលសង្គ្រាម។ ហើយបន្ថែមទៅលើចំណុចនេះ អុប្រេិណូវិច គាត់អនុញ្ញាតឲ្យចៅក្រមស៊ើបអង្កេតចូលទៅដល់ការិយាល័យរបស់គាត់ហើយធ្វើការស៊ើបអង្កេតរឿងក្តីដាក់បន្ទុកទៅលើគាត់ ដែលវាខុសពីរឿងក្តីរបស់ជនជាប់ចោទរូបនេះ។

លោក លោកស្រីចៅក្រម, ជនជាប់ចោទរូបនេះ យើងឃើញថា ឧក្រិដ្ឋកម្មមានការកើតឡើងជាងបីឆ្នាំ លើជនរងគ្រោះជាងដប់ពីរពាន់នាក់ ប្រហែលជាដប់បីពាន់ទៅដប់បួនពាន់។ ហើយយើងមិនអាចប្រៀបធៀបតែម្តងទៅនឹងរឿងក្តី អុប្រេិណូវិច គឺវាខុសគ្នា។ ហើយប្រសិនបើយើងមើលរឿងក្តី អុប្រេិណូវិច គឺយើងគួរតែដាក់ទោសបីបួនដងលើសពីទោសដែលគេបានដាក់ទៅលើ អុប្រេិណូវិច។

ហើយទីពីរ ហើយមេធាវីការពារក្តីបានលើកឡើងប្រៀបធៀបទៅនឹង អាល់បឺត ស្ពៀរ ភាពខុសគ្នានេះគឺថា ជនជាប់ចោទរូបនេះគឺជាអ្នកដែលមានស្វាមីភក្តិ ហើយនិងមានឆន្ទៈនៅក្នុងរបបនោះដែលគាត់ចង់ធ្វើ ប៉ុន្តែ អាល់បឺត ស្ពៀរ គឺជាបុគ្គលមួយខុសពីជនជាប់ចោទរូបនេះ។ ហើយជនជាប់ចោទគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មទៅលើប្រជាជនសាមញ្ញ។ ប៉ុន្តែ យើងដឹងហើយប្រជាជនសាមញ្ញមិនប្រព្រឹត្ត

ឧក្រិដ្ឋកម្មបែបនេះទេ ហើយ អាល់បឺត ស្ពៀរ គឺគាត់ជាមនុស្សមានមនសិការ ហើយគេបានលើកឡើងនៅក្នុងសាលក្រមដែលខ្ញុំសូមដកស្រង់សម្ដី៖ "ស្ថានសម្រាលត្រូវទទួលស្គាល់ ដោយសារតែ អាល់បឺត ស្ពៀរ គាត់បានរក្សាអ្នកអ្នកធ្វើពលកម្មនៅក្នុងផ្ទះរបស់គាត់។ ដូច្នេះហើយវាជាចំណុចមួយ-- ជាចំណុចមនុស្សធម៌ទៅលើគាត់ដែលគាត់បានបង្កការរារាំងទៅលើការឈឺចាប់ទៅលើអ្នកទាំងអស់នោះ។ នេះជាអ្វីដែលកើតឡើងនៅអាល្លឺម៉ង់។ ហើយគាត់បានប្រតិបត្តិបេសកកម្មរបស់គាត់នៅក្នុងប្រទេសភាគខាងលិចនៃប្រទេសអាល្លឺម៉ង់ ហើយគាត់ធ្វើការប្រថុយប្រថានទៅលើកាលៈទេសៈជាច្រើន"។ ហើយយើងឃើញថា វាខុសគ្នាទៅនឹងករណីរបស់ជនជាប់ចោទរូបនេះ។

[០៩:៥៥:០៧]

ហើយយើងនៅរក្សាជំហររបស់យើងស្របជាមួយនឹងអ្នកជំនាញថាជនរូបនេះបង្កភាពភ័យខ្លាចនៅក្នុងប្រទេសកម្ពុជា ហើយបង្កឲ្យមានការចង្អុលដាក់ទៅលើអ្នកទោសទៅលើជនដទៃទៀត។ ហើយយើងដឹងហើយជាង៩០ភាគរយនៃជនជាប់ចោទនោះ-- នៃអ្នកទោសនោះគាត់ទទួលរងទៅលើអំពើហ្នឹងទាំងអស់។ មេធាវីការពារក្ដី គាត់បានបង្ហាញអំពីការផ្សះផ្សាជាតិ ដែលវាអាចមានផលចេញពីការដាក់ទោសរបស់លោក លោកស្រីចៅក្រម។

នៅក្នុងករណីជនជាប់ចោទរូបនេះ យើងត្រូវតែរកយុត្តិធម៌ឲ្យបានសមរម្យ មុនពេលដែលយើងពិចារណាទៅលើការផ្សះផ្សាជាតិ។ ខ្ញុំសូមលើកឡើងសម្ដីសម្ដី ស្ដេហ្វិន ហាសល៖ "ចំណុចទាក់ទងទៅនឹង អាល់បឺត ស្ពៀរ គឺជាចំណុចមួយខ្ញុំចាប់អារម្មណ៍ដែលវាកើតឡើងចំពោះអ្នកអកុសលនៅក្នុងជំរំដែលឃុំឃាំង ដែលខ្ញុំជាប់នៅទីនោះដែរ។ លោកអាល់បឺត ស្ពៀរ គាត់បង្ហាញថា គាត់ជាមនុស្សសំខាន់ដែលគាត់មិនអាចទ្រាំបានទៅលើលក្ខខណ្ឌអមនុស្សធម៌ទាំងអស់នោះ។ ហើយលោក អាល់បឺត ស្ពៀរ គាត់រក្សាជំហររបស់គាត់ធ្វើការរក្សាបន្ថយទៅលើភាពឈឺចាប់ទាំងឡាយ។ ហើយខ្ញុំគិតថា វាមិនត្រូវអនុវត្តចំពោះបុគ្គលដូចគ្នានេះទេ បើសិនជាគាត់មិនបានផ្ដល់សម្ភារៈព័ត៌មានផ្សេងៗដើម្បីគាំទ្រទៅលើរឿងក្ដីនេះ នៅពេលដែលគេប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវនោះ"។

ដូច្នេះ អាល់បឺត ស្ពៀរ រឿងក្ដីនេះគឺវាខុសគ្នាទៅនឹងរឿងក្ដីរបស់ជនជាប់ចោទរូបនេះ។ ហើយលោក អាល់បឺត ស្ពៀរ គាត់បដិសេធគោលនយោបាយនៃរបបនោះ ហើយគាត់បានទទួលស្គាល់ទៅលើកំហុសរបស់គាត់ ហើយចំពោះជនជាប់ចោទរូបនេះយើងត្រូវពិចារណាអំពីការសារភាពរបស់គាត់ដែលយើងលើកដោយមានការលើកឡើងកាលពីម្សិលមិញ ដែលយើងត្រូវយកមកពិចារណាទាំងអស់ថាតើ

គាត់ទទួលខុសត្រូវជាក់ស្តែង និងពិតប្រាកដដែរឬទេ? ប៉ុន្តែយើងឮស្តាប់សម្រាលពីខាងមេធាវីការពារក្តី គាត់លើកឡើងថា គាត់គឺជាបុគ្គលម្នាក់ ដូចស្ពឺជាប់ក្នុងម៉ាស៊ីនដែលគាត់មិនអាចរើរួច ហើយគាត់បានព្យាយាមក្នុងការបន្ថយការឈឺចាប់របស់ជនរងគ្រោះ នេះជាសម្តីរបស់មេធាវីការពារក្តី។

[០៩:៥៧:៥៤]

លោក លោកស្រីចៅក្រមបានស្តាប់ អានមេធាវីការពារក្តី ដែលគាត់អានទៅកាន់លោក ប្រាក់ ខន ហើយនៅក្នុងសៀវភៅនោះ គឺបានលើកឡើងថា ឌុច បានធ្វើទារុណកម្មគ្រប់ពេលទាំងអស់ ហើយប្រសិនបើមិនធ្វើទារុណកម្មទេ យើងមិនអាចរកការពិតនោះទេ ហើយយើងត្រូវរកឲ្យឃើញនូវការពិតដែលមានសរសេរនៅក្នុងសៀវភៅនោះ។ ដូច្នេះហើយ ជាការពិតវានាំឲ្យមានការឆ្លើយដាក់ទៅលើអ្នកដទៃ ។ ហើយយើងអាចយល់ឃើញថា ជនជាប់ចោទរូបនេះ គឺគាត់ចង់បន្ថយទៅលើការស្លាប់ និងការឈឺចាប់របស់ជនរងគ្រោះ ហើយវាផ្ទុយគ្នាទៅនឹងសក្ខីកម្មរបស់ជនជាប់ចោទ។ ជនជាប់ចោទ គាត់បានលើកឡើងថា គាត់ទៅយកអ្នកបុគ្គលិកមកធ្វើការបណ្តុះបណ្តាល ជាអ្នកសួរចម្លើយ និងអ្នកធ្វើទារុណកម្ម នេះជាចម្លើយរបស់គាត់។ ហើយជនជាប់ចោទក៏បានលើកឡើងផងដែរថា ដំណើរការប្រមូលព័ត៌មាន និងការធ្វើទារុណកម្មអនុញ្ញាតឲ្យមានការបង្ហាញឈ្មោះអ្នកដទៃទៀតជាង៩០ភាគរយ ហើយគាត់បានបញ្ជូនឈ្មោះទាំងអស់នោះទៅខាងលើ។ ដូច្នេះហើយ វាមានឲ្យការភ័យខ្លាចនេះកាន់តែកើតឡើងនៅមន្ទីរស-២១។

លោក លោកស្រីចៅក្រម, នៅពេលដែលយើងបញ្ចប់ការបិទការពិភាក្សាដេញដោល ភាគីទាំងឡាយបានបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះសំណួរដែលបានលើកឡើងដោយ រ៉ូប៊ឺត ពេទីត។ គាត់បានលើកឡើងកាន់ជនជាប់ចោទ ថាតើលោកគឺជាបុគ្គលដែលពេញចិត្តទៅនឹងការទុកចិត្តពីមេរបស់លោក ហើយមានការពេញចិត្តនិងស្វាមីភក្តិចំពោះបក្សកុម្មុយនីស្តកម្ពុជា ឬយ៉ាងម៉េច? នេះជាសំណួររបស់លោក រ៉ូប៊ឺត ពេទីត ហើយជនជាប់ចោទនិយាយថា ពិតជាដូច្នោះមែន។

[០៩:៥៩:៤២]

ហើយនៅក្នុងដើមសប្តាហ៍នេះ នៅក្នុងសេចក្តីសន្និដ្ឋានយើងមានការសង្ស័យ ថាតើគាត់មានន័យយ៉ាងម៉េចជនជាប់ចោទរូបនេះ? ប្រសិនបើគាត់មានន័យដូច្នោះមែន ថាគាត់មានជនមានឆន្ទៈជឿទៅលើបក្សកុម្មុយនីស្តកម្ពុជា អនុវត្តនិងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះមិនក្រោមការបង្ខិតបង្ខំ ឬក៏មិនក្រោមហេតុផលនៃការទទួលបញ្ជា ហើយគាត់ជឿទៅលើបញ្ជានោះ។ គាត់ ជនជាប់ចោទរូបនេះ គួរតែ

បញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើចំណុចទាំងអស់នេះ។

មេធាវីការពារក្តី គាត់បានតវ៉ាអំពីការប្រើប្រាស់សំណួរនាំមុខ ដោយសារវាជាគោលការណ៍នៃច្បាប់ខំមិនឡនៅក្នុងការសួរដេញដោយ។ វាជាចំណុចមួយគួរឲ្យភ្ញាក់ផ្អើល។ សំណួរនាំមុខ គឺថាយើងមិនអាចឲ្យមានការរំលោភទៅលើគោលការណ៍នោះទេ ហើយមេធាវីការពារក្តី គាត់បានតវ៉ាទៅលើការប្រមូលព័ត៌មានទាក់ទងទៅនឹងយុទ្ធសាស្ត្រនេះ។ ពេលខ្លះទៅសំណួរនាំមុខ វាអាចនាំឲ្យមានចម្លើយមិនពិតប្រាកដ ហើយជាការស្នើចម្លើយ ស្នើសំណួរដើម្បីយកចម្លើយជាក់លាក់ពីជនជាប់ចោទ ប៉ុន្តែក្នុងន័យដើម្បីសួរសំណួរបញ្ជាប់បន្ថែមនៅពេលក្រោយ។

លោក លោកស្រី ចៅក្រមជាទីគោរព, យើងបានផ្តល់ឱកាសឲ្យជនជាប់ចោទរូបនេះ រយៈពេលពីរថ្ងៃមុន ដើម្បីឲ្យគាត់ជម្រាបតុលាការនេះ ពលរដ្ឋកម្ពុជាថា ខ្ញុំពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មហ្នឹងមែន ខ្ញុំប្រព្រឹត្តដោយឆន្ទៈ ខ្ញុំប្រព្រឹត្តដោយសារតែខ្ញុំជឿទៅលើបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំសូមអភ័យទោសទៅលើអំពើទាំងអស់នេះ។ ប៉ុន្តែ អ្វីដែលជនរូបនេះបានធ្វើ ក្រៅពីការបដិសេធពិរុទ្ធភាពរបស់គាត់តាមមេធាវីរបស់គាត់ដោយលើកឡើងថា គួរតែកាត់ទោសគាត់ឲ្យរួចខ្លួន ហើយខ្ញុំសង្ស័យថាគាត់ប្រហែលជានិយាយដូច្នោះ ប៉ុន្តែខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមបញ្ជាក់ទៅលើចំណុចហ្នឹង។

មេធាវីការពារក្តីអន្តរជាតិលើកឡើងថា ជននេះគឺជាស្ពឺមួយនៅក្នុងម៉ាស៊ីន។ លោក លោកស្រីចៅក្រម ឃើញហើយ នៅក្នុងចំណារទាំងឡាយដែលមានការជំរុញឲ្យមានការធ្វើទារុណកម្ម ហើយនាំឲ្យមានការចាប់ខ្លួនកម្មាភិបាល។ ហើយគាត់លើកឡើងថា តើខ្ញុំអាចចាប់កម្មាភិបាលមួយនេះមួយនោះដែរឬទេ? ហើយមេធាវីការពារក្តីអន្តរជាតិបានបង្ហាញថា យើងគួរតែបំភ្លេចទៅលើភ័ស្តុតាងទាំងអស់នេះ។ ហើយវាទាក់ទងទៅនឹងគុណភាពនៃរូបថតដែលវាមិនមានលក្ខណៈល្អនៅក្នុងឆ្នាំ៧៥ ដល់៧៩ ហើយគាត់មិនបានធ្វើការទទួលខុសត្រូវដោយពេញលេញរបស់គាត់នោះទេ ហើយគាត់មិនបានបញ្ជាក់ទៅលើការដែលគាត់មិនបានបង្កឲ្យមានការភ័យខ្លាច។

ហើយសំណួរចុងក្រោយដែលសួរទៅកាន់ជនជាប់ចោទ ខ្ញុំគិតថាវាធ្វើឲ្យរឿងក្តីនេះមិនកាន់តែមានភាពមិនច្បាស់លាស់។ ថាតើទំនាក់ទំនងលោកជាមួយ សុន សេន យ៉ាងម៉េច? មេធាវីអន្តរជាតិបានសួរទៅកាន់ជនជាប់ចោទ គាត់លើកឡើងថា គាត់មិនមានទំនាក់ទំនង ឬមានទំនាក់ទំនងយ៉ាងម៉េចទៅនឹងមេរបស់លោក? ជនជាប់ចោទ គាត់លើកឡើងថា ខ្ញុំរង់ចាំសំណួរនេះហើយ ខ្ញុំរង់ចាំសំណួរនេះដើម្បីជម្រាបទៅដល់ពិភពលោកថា ខ្ញុំគឺជាបុគ្គលដែលមានស្វាមីភក្តិនិងគោរពទៅលើ សុន សេន។

[១០:០៣:៣៥]

មេធាវីការពារក្តីអន្តរជាតិលើកឡើងថា សុន សេន នៅក្នុងចំណោម១៣នាក់ នៃបុគ្គលដែលប្រព្រឹត្តការកាប់សម្លាប់នៅក្នុងប្រទេស។ សុន សេន គឺជាបុគ្គលដែលបានបង្រៀន និងណែនាំជនជាប់ចោទនៅមន្ទីរ ម-១៣, មន្ទីរ ស-២១។ សុន សេន រស់នៅជាមួយជនជាប់ចោទរយៈពេល១៥ឆ្នាំ បន្ទាប់ពីមន្ទីរស-២១ ហើយថាតើយើងយល់យ៉ាងម៉េចចំពោះស្វាមីភក្តិរបស់ជនជាប់ចោទរូបនេះទៅកាន់ សុន សេន នោះ? ដូច្នេះបើសិនជាគាត់និយាយថាវាមិនពិត មិនមានទំនាក់ទំនងវាហាក់ដូចជាការលេងសើច។ យើងមិនគួរនិយាយថាវាជាការលេងសើចទេ។

ហើយចំណុចនេះវាបង្ហាញស៊ីសង្វាក់ទៅនឹងភ័ស្តុតាងដទៃៗទៀត ហើយវាស្របគ្នា។ ដូច្នេះ នៅពេលនេះ គឺគាត់មកទីនេះដើម្បីគ្រាន់តែទទួលខុសត្រូវបញ្ជាទូទៅ និងបញ្ជានយោបាយតែប៉ុណ្ណោះឬយ៉ាងម៉េច? ហើយគាត់មិនទទួលស្គាល់ថា អ្វីដែលគាត់បានធ្វើគឺកើតឡើងនៅក្នុងឆ្នាំ៧៥ ដល់៧៩ ឬក៏យ៉ាងម៉េច?

លោក លោកស្រី ចៅក្រម, នៅក្នុងសេចក្តីបញ្ចប់របស់គាត់ ប្រហែលជាគាត់បានលើកឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅចំណុចចុងក្រោយ គាត់អាចនិយាយជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី។ គាត់លើកឡើងថា ការពិតខ្ញុំប្រហែលជា ខ្ញុំពិតជាធ្វើការងារជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំប្រព្រឹត្តអំពើទាំងអស់នេះ ហើយនេះជាគោលបំណងរបស់យើង។ គាត់គួរតែនិយាយដូច្នេះ។ យើងមានភ័ស្តុតាងច្រើនណាស់បញ្ជាក់ទៅលើចំណុចទាំងអស់នេះ។ វាបានបង្ហាញការពិត ថាតើជនជាប់ចោទមានមោទនភាពយ៉ាងម៉េចទៅនឹងមេរបស់ខ្លួនដែលបានណែនាំខ្លួនឲ្យប្រព្រឹត្តអំពើនោះរយៈពេលជាច្រើនឆ្នាំ រហូតមកដល់ដំណាក់កាលចុងក្រោយ?

ដូច្នេះ វាហាក់ដូច វាបើកឲ្យមានការសង្ស័យទៅលើជនជាប់ចោទរូបនេះ ហើយគាត់បានបិទទ្វារមិនឲ្យមានទៅលើការទទួលស្គាល់របស់គាត់ ហើយគាត់បានលើកឡើងថាគាត់បើកចំហ ប៉ុន្តែនៅហាក់ដូចជានៅពេលនេះ គាត់បិទទ្វារទៅវិញទេ។ ដូច្នេះ ចាំបាច់យើងត្រូវយល់ទៅលើចំណុចនេះយ៉ាងម៉េច?

យើងដឹងហើយមនុស្សជាងដប់ពីរពាន់នាក់ត្រូវបានគេធ្វើទារុណកម្មហើយសម្លាប់ចោល។ យើងត្រូវពិចារណា និងគិត អំពីភាពឆ្លងកាត់ដែលពួកគេទាំងអស់គ្នាបានទទួលរង ដែលអ្នកទាំងអស់នោះមានភាពរីករាយ និងមានភាពរីករាយដែលគាត់ចង់បាន។ ប៉ុន្តែគាត់ទទួលរងនូវឧក្រិដ្ឋកម្ម និងទារុណកម្មដែលជននេះបានប្រព្រឹត្ត។ ជននេះមិនគួរទទួលខុសត្រូវ ឬក៏មិនត្រូវទទួលទោសមួយជីវិតទេ ប៉ុន្តែខ្ញុំសូម

ឲ្យដាក់តែ៤០ឆ្នាំតែប៉ុណ្ណោះ។ ខ្ញុំដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីមានការតវ៉ាទៅលើចំណុចហ្នឹង ដោយសារគេបាត់បង់សមាជិកគ្រួសារ ហើយគេលើកឡើងថា គាត់ជាប់តែ៤០ឆ្នាំ។ យើងយល់ទៅលើចំណុចទាំងអស់នេះ ប៉ុន្តែយ៉ាងណាក៏ដោយដូចដែលយើងបានលើកឡើង យើងមិនមែនមកទីនេះដើម្បីសងសឹកនោះទេ យើងគោរពទៅលើគោលការណ៍មនុស្សធម៌ គឺគោលការណ៍មនុស្សធម៌របស់ជននេះផងដែរ។ គោលការណ៍មនុស្សធម៌របស់ជនរងគ្រោះនៅមន្ទីរស-២១។ ដូច្នេះ ច្បាប់តម្រូវឲ្យយើងធ្វើដូច្នេះ ដោយសារតែមានការឃុំខ្លួនលើជនរូបនេះ យើងត្រូវតែមានការបន្ថយទោសទៅលើជនរូបនេះដោយផ្អែកទៅលើច្បាប់។

[១០:០៧:៣៣]

ដូច្នេះ យើងធ្វើយ៉ាងណាចេញសាលក្រមមួយដែលវាល្អបំផុត ជាជាងការដែលយើងចេញសាលក្រមមួយដែលលើជនជាប់ចោទរូបនេះ ឬក៏អ្នកផ្សេងដូចដែលយើងបានធ្លាប់ចេញមកជាច្រើនឆ្នាំ។ ដូច្នេះ យើងបានគោរពទៅលើគោលការណ៍ថាគ្មាន បើសិនជាគ្មានយុត្តិធម៌នឹងមិនមានសន្តិភាពនោះទេ។ យើងត្រូវចាំទៅលើចំណុចនេះ។ ហើយដូចដែលយើងបានលើកឡើងរួចមកហើយ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម ចេញសាលក្រមមួយដែលវាជាសញ្ញាមួយដ៏ភ្លឺស្វាងសម្រាប់ប្រជាជនកម្ពុជា និងពលរដ្ឋកម្ពុជានាពេលអនាគត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដោយសារពេលវេលាបន្ទាប់ត្រូវ អង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅមេធាវីការពារក្តី និងជនជាប់ចោទដើម្បីឆ្លើយតបជាចុងក្រោយនោះ ដើម្បីឲ្យពេលវេលាសម្រាប់គាត់ អាចប្រព្រឹត្តទៅបានជាប់ ដោយមិនអាក់ មិនចាំបាច់ផ្តាច់នូវពាក់កណ្តាលទី អង្គជំនុំជម្រះសម្រេចសម្រាកចាប់ពីពេលនេះតទៅម្ភៃនាទីរហូតដល់ម៉ោងដប់និងសាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:១០នាទី ដល់ម៉ោង ១០:៣៧នាទី]*

[១០:៣៧:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាកិច្ចបន្តនេះ គឺជាវេទិកានៃមេធាវីការពារក្តីនិងជនជាប់ចោទឡើងធ្វើសេចក្តីសន្និដ្ឋានតបបញ្ចប់ចុងក្រោយ។ ហើយនៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្តីសន្និដ្ឋានតបចុងក្រោយរបស់មេធាវីការពារក្តីរួមទាំងជនជាប់គឺមានរយៈពេលមួយម៉ោង។ អង្គជំនុំជម្រះក៏សូមជម្រាបដល់ជនជាប់ចោទផងដែរថា នៅក្នុងអំឡុងពេលចុងក្រោយនេះ អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាដ៏សមស្របសម្រាប់ជនជាប់ចោទមានឱកាសក្នុងការនិយាយសម្តីចុងក្រោយបង្អស់ ប្រសិនបើជនជាប់ចោទមានបំណង។ ក៏ប៉ុន្តែ ដោយអង្គជំនុំជម្រះយល់មិនទាន់ច្បាស់លាស់អំពីវិធីសាស្ត្រនៃការធ្វើសេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីក្តីទាំងពីររូបទាំងមេធាវីជាតិ និងមេធាវីអន្តរជាតិដែលមានលក្ខណៈមិនស៊ីសង្វាក់គ្នា ហេតុដូច្នេះអង្គជំនុំជម្រះសង្ឃឹមថា មេធាវីការពារក្តីនឹងបញ្ជាក់ជំហររបស់ខ្លួនឲ្យបានច្បាស់លាស់ក្នុងការធ្វើសេចក្តីសន្និដ្ឋានការពាររបស់ខ្លួន។

តទៅនេះ សូមអញ្ជើញមេធាវីការពារក្តីឡើងធ្វើសេចក្តីសន្និដ្ឋានតបចុងក្រោយ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ សូមគោរពអង្គសវនាការទាំងមូល។

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានយកចិត្តទុកដាក់ ហើយបានមានប្រសាសន៍ថា ភាគីរបស់លោកចូលមកនេះមិនមែនដើម្បីសងសឹកទេ គឺដើម្បីស្វែងរកយុត្តិធម៌តាមច្បាប់។ ឯសហព្រះរាជអាជ្ញាក៏បានបញ្ជាក់បន្ថែមទៀតដែរថា សហព្រះរាជអាជ្ញាលើកឡើងទាំងប៉ុន្មាននេះគឺដើម្បីស្វែងរកយុត្តិធម៌។ មេធាវីក៏សូមថ្លែងអំណរគុណទាំងពីរភាគី ព្រោះមេធាវីការពារក្តី ដែលខំលើកឡើងនេះ ក៏ដើម្បីស្វែងរកយុត្តិធម៌ដូចគ្នា ក្នុងទិសដៅតែមួយដូចគ្នា។

[១០:៤០:៤៤]

អង្គសវនាការជាទីគោរព, ពីចំណុចទីមួយ ខ្ញុំបាទសូមលើកឡើងអំពីការពន្យារពេលអាជ្ញាយុកាល៣០ឆ្នាំ។ ក្នុងការពន្យារពេលអាជ្ញាយុកាល៣០ឆ្នាំនេះ មេធាវីការពារក្តីមិនបានជំទាស់ទេ ក៏ប៉ុន្តែមេធាវីតុលាការក្តី សូមឲ្យតុលាការមេត្តាពិចារណាថា ចាប់ពីថ្ងៃ៦ មករា ១៩៧៩ ហើយវាផុតអាជ្ញាយុកាលនៅថ្ងៃ៦ មករា ១៩៨៩ ក្នុងចន្លោះហ្នឹង បើចង់ពន្យារម៉េចមកពន្យារក្នុងចន្លោះហ្នឹង មេធាវីអត់ជំទាស់ទេ។ តែនេះដល់ឆ្នាំពីរពាន់ជាងទៅហើយបានមកពន្យារ ប្រៀបដូចជាខ្មោចដែលវាស្លាប់បាត់ជាង១០ឆ្នាំទៅហើយទៅនាំគ្នាប្រោះឲ្យរស់ឡើងវិញ នេះជាការពិបាកនឹងទទួលយក។ នេះជាចំណុចទីមួយ។

ចំណុចទីពីរ ខ្ញុំបាទសូមលើកឡើងអំពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាជាតិដែរ។ បើតាមមាត្រា៣ វាក្យខណ្ឌទី១ នៃច្បាប់ អ.វ.ត.ក បានយោងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺមាន ១០មាត្រា មាត្រា២០៩ មាត្រា២១០ មាត្រា៥០០ មាត្រា៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង៥០៨។ អ៊ីចឹងក្នុងចំណោម ១០មាត្រាហ្នឹង គឺបានចង្អុលច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌនឹងគឺថាមានបួនមាត្រា គឺមាត្រា២០៩ មាត្រា៥០០ មាត្រា៥០៦ និងមាត្រា៥០៧--

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធានឲ្យលោក ការ សាវុត្ថ មេត្តាអានមាត្រាចុងក្រោយឡើងវិញតិចទាន ព្រោះអ្នកបកប្រែតាមមិនទាន់។

**លោក ការ សាវុត្ថ៖**

ខ្ញុំសូមបញ្ជាក់ឡើងវិញ ក្នុងច្បាប់ អ.វ.ត.ក ក្នុងមាត្រា៣ វាក្យខណ្ឌទី១ នៃច្បាប់ អ.វ.ត.ក បានយោងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងចង្អុលមាត្រានៃក្រមព្រហ្មទណ្ឌនេះចំនួនដប់មាត្រា៖ មាត្រា២០៩ មាត្រា២១០ មាត្រា៥០០ មាត្រា៥០១ មាត្រា៥០៣ មាត្រា៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨។ ដែលក្នុងចំណោមដប់មាត្រានេះបានគូសបញ្ជាក់បួនមាត្រា គឺមាត្រា២០៩ មាត្រា៥០០, ៥០៦ និង៥០៧ បានចែងថាត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី៣។ អ៊ីចឹង ក្នុងព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដដែល ត្រង់មាត្រា២១ បានបញ្ជាក់ថា ទោសឧក្រិដ្ឋថ្នាក់ទី៣ គឺជាទោសសម្លាប់។ អ៊ីចឹង ខ្លឹមសារនៃមាត្រា៣ វាក្យខណ្ឌទី១ នៃច្បាប់ អ.វ.ត.ក មានន័យផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលមាត្រា៣២ វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣-១៩៩៨ បានចែងថា ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ។ អ៊ីចឹង មេធាវីការពារយល់ឃើញថាមាត្រា៣ វាក្យខណ្ឌទី២ នៃច្បាប់ អ.វ.ត.ក បានពន្យារពេលបន្ថែម៣០ឆ្នាំទៀតទៅលើអជ្ញាយុកាល នៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្ម ដែលមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានកំណត់ត្រឹមតែដប់ឆ្នាំ។

[១០:៤៥:៥៤]

អ៊ីចឹង អនុភាពនៃមាត្រា៣ នៃវាក្យខណ្ឌទី២នេះ នៃច្បាប់ អ.វ.ត.ក បានធ្វើឲ្យប៉ះពាល់ដល់គោលការណ៍ជាសារវន្ត មួយគឺអប្រតិសកម្មភាពនៃច្បាប់ថ្មី គឺច្បាប់ អ.វ.ត.ក លើបទល្មើសដែលបានកើតឡើងក្នុងអតីតកាល។ កន្លែងនេះ ខ្ញុំសូមបើកវង្វង់ក្រចកជម្រាបជូនថា នៅលើពិភពលោកយើងទាំងមូលទោះបីច្បាប់នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រព័ន្ធអង់គ្លូស្សាក់សុងក្តី ប្រព័ន្ធច្បាប់អ៊ីស្លាមក្តី

ប្រព័ន្ធច្បាប់សង្គមនិយមក្តី ក្នុងប្រព័ន្ធច្បាប់ស៊ីវិលក្តី គឺត្រូវគោរពគោលកាណ៍គ្រឹះ ឬក៏គោលការណ៍ជាសារវន្ត ដែលជាបទប្បញ្ញត្តិត្រូវតែគោរពតាម តម្រូវឲ្យយើងគោរពតាម បើយើងមិនគោរពតាមគឺវាខុសគោលការណ៍។

អ៊ីចឹង មេធាវីការពារក្តី សូមអនុញ្ញាតជម្រាបបញ្ជាក់ថា ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា មិនបានបញ្ជាក់ថា គោលការណ៍ជាសារវន្តនេះមានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញឡើយ។ ក្រុមប្រឹក្សាធម្មនុញ្ញអត់បានបញ្ជាក់ទេ ហើយសភាធម្មនុញ្ញក៏មិនបានចែងពីគោលការណ៍នេះ នៅក្នុងរដ្ឋធម្មនុញ្ញដែរ។ គោលការណ៍ជាសារវន្តនេះ មិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញថ្មី ១៩៩៣-១៩៩៨ មែន ប៉ុន្តែឧបសម្ព័ន្ធទី៥១ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ១៩៩១ ក៏សភាធម្មនុញ្ញយោងលើកិច្ចព្រមព្រៀងនេះដែរ កិច្ចព្រមព្រៀងប៉ារីសនេះដែរ។ អ៊ីចឹង ទោះមិនចែងក្នុងរដ្ឋធម្មនុញ្ញក៏ត្រូវគោរពតាមឧបសម្ព័ន្ធលេខ៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានចែងថា-- ឧបសម្ព័ន្ធទី៥ហ្នឹងចែងថា "រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តច្បាប់ឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល"។ អ៊ីចឹង ការពន្យារអាជ្ញាយុកាលបន្ថែម៣០ឆ្នាំ ក៏ត្រូវគោរពគោលការណ៍ជាសារវន្តនេះដែរ ប្រទេសណាក៏គេត្រូវតែគោរពដែរ។ គឺអប្រតិសកម្មភាពនៃច្បាប់ អ.វ.ត.ក លើបទល្មើសដែលបានកើតឡើងក្នុងអតីតកាល។ នេះបញ្ជាក់ថាមិនអាចចោទប្រកាន់តាម ឌុច តាមច្បាប់ជាតិបានទេ។

ម្យ៉ាងទៀត អប្រតិសកម្មមិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញមែន ប៉ុន្តែ នៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ សូមមើលក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺគោលការណ៍គ្រឹះនៃក្រមព្រហ្មទណ្ឌ១៩៥៦ វាមានករណីលាលែង គឺអញ្ញត្រកម្ម។ ជាក់ស្តែងមាត្រា៦ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានចែងយ៉ាងច្បាស់ក្រឡែតថា ប៉ុន្តែបើច្បាប់ថ្មីៗ គឺច្បាប់ អ.វ.ត.ក បើយើងចែង បើយើងបង្កើតច្បាប់ថ្មីឡើងនេះ បើច្បាប់ថ្មីនេះ លុបចោលបទល្មើសណាមួយ បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់នេះ ត្រូវបានរួចផុតពីទោស។ អ៊ីចឹង អាគោលការណ៍គ្រឹះគេចែងអ៊ីចឹង។ គេផ្តន្ទាទោសបាន ចាប់ពីច្បាប់ហ្នឹងតទៅ បើមុនច្បាប់ហ្នឹងត្រូវផុតទោស។ គោលការណ៍គ្រឹះដែលត្រូវគោរព។

[១០:៥០:២១]

អ៊ីចឹង ច្បាប់ថ្មីរបស់ អ.វ.ត.ក បានបំពេញលក្ខខណ្ឌនៃមាត្រា៦ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដោយពេញលេញ ដោយបរិបូរ ដោយគ្រប់គ្រាន់។ ជាក់ស្តែងនៅក្នុងជំពូកទី១១ ទោសបញ្ញត្តិ មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ អ.វ.ត.ក នេះ ថាដាក់ពន្ធនាគារប្រាំឆ្នាំរហូតអស់មួយជីវិត។

ឃើញទេ! ដោយលុបចោលបាត់នូវទោសប្រហារជីវិត។ បើច្បាប់ថ្មីនេះ បានលុបចោលបទល្មើសណាមួយ បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់នេះ វាត្រូវតែបានរួចផុតពីទោស។

ដូច្នេះ វាមិនមែនតែ ឌុច ម្នាក់ទេ ដែលត្រូវផុតពីការចោទប្រកាន់ ពីបទឧក្រិដ្ឋតាមច្បាប់ជាតិ។ ខ្មែរក្រហមទាំងប៉ុន្មានប្រហែលជាអាចផុតចោទដូចគ្នា។ ខ្ញុំសូមបញ្ជាក់ថា ប្រហែលសហចៅក្រមស៊ើបអង្កេតលោកយល់អំពីបញ្ហានេះ បានជាសហចៅក្រមស៊ើបអង្កេតពុំបានចោទប្រកាន់បទឧក្រិដ្ឋតាមច្បាប់ជាតិ។ បញ្ហានេះ ខ្ញុំបាទសំណូមពរតុលាការមេត្តាពិចារណាបន្ថែមទៅលើសេចក្តីសម្រេចលេខ 040/002/2001 ក.ប.ធ. (ក្រុមប្រឹក្សាធម្មនុញ្ញ) ច. ចុះថ្ងៃទី១២ កុម្ភៈ ឆ្នាំ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ គឺសំណូមពរតុលាការមុននឹងសម្រេចសេចក្តី សូមមេត្តាពិនិត្យទៅលើសេចក្តីសម្រេចលេខដូចខ្ញុំបានបញ្ជាក់ជូនអម្បាញ់មិញ។ នេះជាបញ្ហាទីពីរដែលខ្ញុំបាទបានលើកឡើង។

បញ្ហាទីបី នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាក៏ដូចជាការលើកឡើងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងដែលក្នុងន័យថាស-២១ ជាមន្ទីរសំខាន់បំផុត។ អ៊ីចឹង គេយកមកកាត់តែស-២១ ទេ។ ១៩៥ មន្ទីរទៀតគេអត់យកកាត់ទេ ពីព្រោះវាសំខាន់ក្នុងចំណោមគុក១៩៦ គុកហ្នឹងគឺមន្ទីរស-១២ វាសំខាន់ជាងគេ។ អ៊ីចឹង ខ្ញុំឆ្ងល់ មេធាវីការពារឆ្ងល់ ព្រោះយើងជាអ្នករកយុត្តិធម៌ដូចគ្នា។ ឆ្ងល់យ៉ាងម៉េច? ថាមន្ទីរដទៃទៀតនេះ គុកដទៃទៀតនេះដែលសម្លាប់មនុស្សវាច្រើនជាងស-២១ គុកខ្លះសម្លាប់ ២ម៉ឺននាក់ ៣ម៉ឺននាក់ ៤ម៉ឺននាក់ ៥ម៉ឺននាក់ ១០ម៉ឺននាក់ ១៥ម៉ឺននាក់។ នៅលោចន៍ពោធិ៍សាត់ឮថាដល់២០ម៉ឺន អីផង ប៉ុន្តែវាអត់មានតួលេខ ម្លោះហើយឯកសារច្បាស់លាស់ ខ្ញុំមិននិយាយទេ និយាយត្រឹមតែ ១៥ម៉ឺននាក់ហ្នឹង។ ម៉េចបានវាមិនសំខាន់? ខ្ញុំឆ្ងល់អ៊ីចឹង ម៉េចបានវាមិនសំខាន់? ខ្ញុំឆ្ងល់ថា ជីវិតប្រជាជនរាប់សែននាក់ រាប់លាននាក់នៅគុកដទៃទៀត ហេតុអីបានវាមិនសំខាន់? ជីវិតហ្នឹងនុំងម៉េចវាថោកម្លេះ? ខ្ញុំឆ្ងល់អ៊ីចឹង។ ហើយខ្ញុំបានសូមឲ្យសហព្រះរាជអាជ្ញាលើកឡើង ដើម្បីឲ្យជនរួមជាតិគេបានយល់ ពិសេសជនជាប់ចោទមុននឹងផ្តន្ទាទោសគេដាក់គុកក៏ត្រូវឲ្យគេយល់ ឲ្យត្រូវគេយល់ពីព្រោះបើគេអត់យល់ផង គេអត់ទទួលស្គាល់ថា អាហ្នឹង វាស-២១ វាសំខាន់ផង។ ឃើញទេ! ត្រូវព្រះរាជអាជ្ញាពន្យល់ ប៉ុន្តែព្រះរាជអាជ្ញា ប៉ុន្តែព្រះរាជអាជ្ញាអត់បានពន្យល់ទេ ចំណុចនេះ។

[១០:៥៤:២៣]

ទីពីរ ថាមន្ទីរនេះនៅលើគេបង្អស់នៃបរិធានសន្តិសុខ និងពិសេសតែមួយគត់នៅក្នុងចំណុចជាច្រើន។ ថាអាស-២១ គេយកមកកាត់ទោស ពីព្រោះគាត់ហ្នឹងវាពិសេសជាងគេ។ អ៊ីចឹងពិសេសលើ

ចំណុចអីខ្លះ? ចំណុចទីមួយ គាត់ថាជាមន្ទីរសន្តិសុខតែមួយគត់នៅក្នុងប្រទេសដែលទំនាក់ទំនងផ្ទាល់ជាមួយគណៈអចិន្ត្រៃយ៍ ដែលមន្ទីរនេះបានផ្តល់យោបល់អីអ៊ីចឹង...។ល។

ខ្ញុំសូមជម្រាបថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គុកទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យនោះ គឺថាវាជារបស់បក្ស គ្មានជារបស់អ្នកណាទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គុកទាំងអស់ជារបស់បក្ស។ អ៊ីចឹងយើងឃើញថា សុន សេន បុគ្គលទី៧ ក្នុងបក្សកុម្មុយនីស្តកម្ពុជាក្តោបក្តាប់ គ្រប់គ្រងគុកស-២១ នៅក្នុងក្រុងភ្នំពេញ។ ប៉ុល ពត លេខាបក្សបុគ្គលទីមួយ ក្នុងបក្សកុម្មុយនីស្ត គ្រប់គ្រងគុកទាំងអស់ដោយប្រយោល តែគ្រប់គ្រងផ្ទាល់ក្តោបក្តាប់ផ្ទាល់គុកទាំងអស់ក្នុងតំបន់ឯករាជ្យ កំពង់សោម សៀមរាប ព្រះវិហារ ឧត្តរមានជ័យ។ អាហ្នឹងវាពិសេស ព្រោះមេជាអចិន្ត្រៃយ៍ គេកាន់ផ្ទាល់។

ទីបីយើងពិនិត្យឃើញថាឧបមានៅបូព៌ា សោ យ៉ាន់ ហៅ ភឹម ជាបុគ្គលទីបីក្នុងបក្សកុម្មុយនីស្តកម្ពុជា គ្រប់គ្រងគុកទាំងអស់នៅភូមិភាគបូព៌ា ជាបុគ្គលទីបីក្នុងអចិន្ត្រៃយ៍។ ទីបួន ឈិត ជឿន ហៅ ម៉ុក ឬក៏អ៊ុង ជឿន ហៅ ម៉ុក ជាបុគ្គលទីបួនក្នុងបក្សកុម្មុយនីស្តកម្ពុជា គ្រប់គ្រងគុកទាំងអស់នៅនិរតី ជាបុគ្គលទីបួនក្នុងអចិន្ត្រៃយ៍។

អ៊ីចឹងស-២១ ជាមន្ទីរសន្តិសុខតែមួយគាត់នៅក្នុងប្រទេស ដែលទំនាក់ទំនងផ្ទាល់ជាមួយនឹងអចិន្ត្រៃយ៍ គឺជាការភាន់ច្រឡំ ខ្ញុំយល់ថា សហព្រះរាជអាជ្ញាភាន់ច្រឡំ ព្រោះមន្ទីរស-២១ ធ្វើការជាមួយ សុន សេន ជាបុគ្គលទីប្រាំពីរក្នុងអចិន្ត្រៃយ៍។ ក្នុងតំបន់ឯករាជ្យ ធ្វើការជាមួយ ប៉ុល ពត ជាបុគ្គលទីមួយក្នុងអចិន្ត្រៃយ៍ អាហ្នឹងបានវាពិសេស។ មិនមែនបុគ្គលទីប្រាំពីរហ្នឹង វាពិសេសជាងបុគ្គលទីមួយទេ។ នៅបូព៌ាធ្វើការជាមួយ សោ យ៉ាន់ ហៅ ភឹម ជាបុគ្គលទីបីក្នុងអចិន្ត្រៃយ៍ អាហ្នឹងបានវាពិសេសជាងបុគ្គលទីប្រាំពីរ ពីព្រោះទីប្រាំពីរ វានៅក្រោយអាទីបី។ នៅនិរតី អ៊ុង ជឿន ហៅ ម៉ុក ហ្នឹង គុកទាំងអស់នេះ គេធ្វើការជាមួយ តា ម៉ុក ជាបុគ្គលទីបួនក្នុងអចិន្ត្រៃយ៍។ នេះបានវាពិសេសជាងបុគ្គលទីប្រាំពីរ។

[១០:៥៧:២៩]

ជារួមការកំណត់ថា មន្ទីរស-២១ ជាមន្ទីរសន្តិសុខតែមួយគត់ក្នុងប្រទេស ដែលទំនាក់ទំនងផ្ទាល់ជាមួយគណៈអចិន្ត្រៃយ៍ គឺជាការភាន់ច្រឡំ ព្រោះមន្ទីរសន្តិសុខដទៃទៀត ក៏មានទំនាក់ទំនងផ្ទាល់ជាមួយគណៈអចិន្ត្រៃយ៍ ដែលជាបុគ្គលមានឥទ្ធិពលជាងបុគ្គលទីប្រាំពីរទៅទៀត។ ចំណុច “ខ” ថា ស-២១ នេះ វាសំខាន់ វាពិសេសត្រង់ថា ស-២១ នេះ វាជាមន្ទីរសន្តិសុខតែមួយគត់ ដែលមានភារកិច្ចក្នុងការចាប់ខ្លួន សួរចម្លើយ និងប្រហារជីវិតកម្មាភិបាលដឹកនាំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬនៅក្រសួង

ស្ថាប័ននានា...។ល។ នេះមេធាវីការពារមិនយល់ស្របនឹងការលើកឡើងនេះទេ ព្រោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បង្កើតឡើងដើម្បីរកយុត្តិធម៌ជូនវិញ្ញាណក្ខន្ធដល់ប្រជាជនកម្ពុជា ដែលបានបាត់បង់ជីវិត ដោយអយុត្តិធម៌ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលនៅរស់ ហើយធ្លាប់រងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយបើកំណត់ថា ស-២១ វាសំខាន់ វាពិសេសត្រង់ថាមានភារកិច្ចចាប់ខ្លួន សួរចម្លើយ ប្រហារជីវិតកម្មាភិបាលដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្រសួងនានា អ៊ីចឹងមានតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ.វ.ត.ក នេះបង្កើតឡើង ដើម្បីរកយុត្តិធម៌ជូនកម្មាភិបាលកុម្មុយនីស្តកម្ពុជា ដែលមានបាតដៃប្រលាក់ឈាម ហើយគេយកមកសម្លាប់នៅស-២១។ ឧទាហរណ៍ កុយ ធួន មុននឹងចូល ស-២១ សួរថាតើ កុយ ធួន សម្រេចសម្លាប់អស់ប៉ុន្មាននាក់? ម៉ែន សាន ហៅ យ៉ា មុននឹងចូលស-២១ តើគេ ម៉ែន សាន ហៅ យ៉ា ហ្នឹងសម្រេចសម្លាប់មនុស្សអស់ប៉ុន្មាននាក់? ជូ ជេត ហៅ ស៊ី មុនចូលស-២១ អស់ប៉ុន្មាននាក់? វស់ ញឹម, កង ចាប ហៅ សែ...។ល។ មុនចូល ស-២១ តើសម្រេចសម្លាប់អស់ប៉ុន្មាននាក់?

មេធាវីការពារយល់ថា អ.វ.ត.ក បង្កើតឡើងសម្រាប់រកយុត្តិធម៌ជូនប្រជាជនកម្ពុជារាប់លាននាក់ ដែលបាត់បង់ជីវិតដោយអយុត្តិធម៌ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់យកយុត្តិធម៌ ដល់អ្នកដែលនៅរស់សល់ពីការកាប់សម្លាប់ មិនមែន អ.វ.ត.ក បង្កើតឡើងសម្រាប់រកយុត្តិធម៌ឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលគេយកមកកម្ទេចនៅស-២១ នេះទេ។ ចំណុចនេះមេធាវីទទួលយកមិនបានទេ។

ចំណុច “គ” ថា ស-២១ ហ្នឹង វាសំខាន់ វាពិសេសត្រង់ថា មន្ទីរនេះប្រើប្រាស់ធនធានធំទូលំទូលាយ ពិសេសគឺថា បើនិយាយពីចំនួនបុគ្គលិក វាថាច្រើនជាងគេ។ ខ្ញុំសូមអនុញ្ញាតជម្រាបតុលាការថា សហព្រះរាជអាជ្ញា គ្មានបញ្ជីបុគ្គលិកនៅគុកនីមួយៗឲ្យគ្រប់ទាំង១៩៦គុកទេ។ ម៉េចក៏ប៉ានសន្និដ្ឋានថា អាហ្នឹងវាបុគ្គលិកច្រើនជាងគេ ពីព្រោះខ្ញុំមេធាវីការពារ ខ្ញុំវិភាគមើលទៅស-២១ សម្លាប់១២.៣៨០នាក់ មានបុគ្គលិក ២.៣០០នាក់ ហើយចុះអាសម្លាប់ដប់ម៉ឺននាក់ វាបុគ្គលិកប៉ុន្មាន? អត់មានអ្នកណាដឹងទេ បុគ្គលិកប៉ុន្មាន? ព្រោះគ្មានបញ្ជី អា១៥ម៉ឺននាក់នោះ វាប៉ុន្មាន? ខ្ញុំមិននិយាយពីរឿងគុកនៅតំបន់ឯករាជ្យ ដែល ប៉ុល ពត កាន់កាប់ទេ ពីព្រោះខ្ញុំវាគ្មានឯកសារ គ្រាន់តែឮថាមានជាងបួនពាន់នាក់ហ្នឹង។ ដូច្នេះការលើកឡើងថា អាហ្នឹងសំខាន់ព្រោះបុគ្គលិកច្រើនជាងគេ អាហ្នឹងត្រូវយកមកកាត់ទោស។ ខ្ញុំទទួលយកមិនបានទេ សូមជម្រាប។

[១១:០១:៤៥]

ចំណុចទីបួន ខ្ញុំសូមបញ្ជាក់ឡើងវិញ។ មេធាវីការពារទទួលស្គាល់ថា ឧក្រិដ្ឋកម្មនៅស-២១ វាមានពិតប្រាកដមែន នៅក្នុងសេចក្តីសន្និដ្ឋានថ្ងៃមុន ក៏ទទួលស្គាល់ដែរ ជនជាប់ចោទក៏ទទួលស្គាល់ដែរ ប៉ុន្តែខ្ញុំមេធាវី ខ្ញុំពិនិត្យផ្លូវច្បាប់ ថាតើអ្នកណាជាអ្នកទទួលខុសត្រូវ? ខ្ញុំឆ្លើយថា បក្សកុម្មុយនីស្តកម្ពុជាជាអ្នកទទួលខុសត្រូវ។ ព្រោះដូចខាងសហព្រះរាជអាជ្ញាលើកឡើងអម្បាញ់មិញអ៊ីចឹង ថាអង្គជំនុំជម្រះយើងសាលាដំបូងនេះ មិនអាចជំនុំជម្រះអ្វីក្រៅអំពីសេចក្តីសន្និដ្ឋានបញ្ជូនរឿងទៅជម្រះរបស់សហចៅក្រមសង្កេតទេ។ នេះបក្សកុម្មុយនីស្តកម្ពុជាជាអ្នកទទួលខុសត្រូវ ពីព្រោះមិននៅក្នុងសេចក្តីសន្និដ្ឋានហ្នឹង នៅក្នុងកថាខណ្ឌទី១០ និងទី១១ នៃដីកាបញ្ជូនរឿងទៅជម្រះនេះ បានកំណត់យ៉ាងច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជាជាអ្នកបញ្ជា បក្សជាអ្នកបញ្ជា។ អ៊ីចឹងយោងលើមាត្រា៣៨ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អ្នកណាបញ្ជា អ្នកហ្នឹងអ្នកទទួលទោស។ តា ឌុច ត្រូវបានរួចខ្លួន ព្រោះ តាឌុច ជាអ្នកអនុវត្តតាមបញ្ជា មិនមែន តា ឌុច បញ្ជាទេ។ វាក្យខណ្ឌទី១០ ទី១១ បញ្ជាក់ច្បាស់ហើយថា បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកបញ្ជា រួចចុះបក្សកុម្មុយនីស្តកម្ពុជាប៉ុន្មាននាក់ គេនៅរស់តើ សុទ្ធតែមេបក្សហ្នឹង អាហ្នឹង នុំងទៅផ្តន្ទាទោសអ្នកហ្នឹងទៅ អាហ្នឹងវាចប់រឿងហើយ។

ជាចុងក្រោយ សូមតុលាការមេត្តាពិចារណា សហព្រះរាជអាជ្ញា បានស្នើសុំឲ្យដាក់ជនជាប់ចោទហ្នឹង ដាក់ពន្ធនាគារ៤០ឆ្នាំ ទៅលើបទល្មើស ទៅលើបទល្មើសទាំងពីរជំពូក។ ដោយសហព្រះរាជអាជ្ញាយល់ថា ជនជាប់ចោទនេះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យផង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មផង។ អ៊ីចឹងគាត់ទារគាត់ជាពីរជំពូក។ អ៊ីចឹងសហព្រះរាជអាជ្ញាស្នើដាក់៤០ឆ្នាំ ក៏ប៉ុន្តែនៅវាក្យខណ្ឌទី១២៩ នៃដីកាបញ្ជូនរឿងទៅជម្រះ សហចៅក្រមស៊ើបអង្កេតបានកំណត់ច្បាស់ថា តាមការស៊ើបអង្កេតឃើញថា ឌុច នេះមិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យទេ។ អ៊ីចឹងចោទព្រះរាជអាជ្ញាចោទថា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យហ្នឹង ឌុច អត់មែនទេ។ ហ្នឹងស៊ើបអង្កេតឃើញរួចហើយ។ អ៊ីចឹង៤០ឆ្នាំ វាអស់អាហ្នឹងមួយ នៅសល់តែ២០ឆ្នាំទេៗ ព្រោះមិនមែនមេដឹកនាំជាន់ខ្ពស់ផង រួចទៅផ្តន្ទាទោស វាខុស។ ចៅក្រមស៊ើបអង្កេតបានសម្រេចរួចហើយ បានបញ្ជាក់រួចហើយ។ អ៊ីចឹងវានៅសល់ថា៤០ឆ្នាំ វានៅសល់២០ឆ្នាំទៀត។

[១១:០៥:០៧]

បើនៅសល់២០ឆ្នាំទៀត គឺថាគាត់ជាជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ អ៊ីចឹងជន

ទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនេះ ត្រូវផ្តន្ទាទោសគាត់ពីរ។ ទីមួយ ទៅលើច្បាប់ជាតិ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ទីពីរ ទៅលើឧក្រិដ្ឋកម្មសង្គ្រាម។ អ៊ីចឹង អាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ សួរថាតើអនុវត្តទៅលើជនជាប់ចោទបានទេ? ថាអត់បានទេ ពីព្រោះអប្រតិសកម្មទៅហើយ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹង។ អ៊ីចឹងអា២០ឆ្នាំហ្នឹង អស់១០ឆ្នាំទៅទៀតហើយ នៅសល់តែ១០ទេ។ បើនៅសល់តែ១០ទេ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាមនេះឯង។ ក៏ប៉ុន្តែឧក្រិដ្ឋកម្មសង្គ្រាមហ្នឹង ខ្ញុំបាទបានជម្រាបជូនពីក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំបាទរួចហើយ ថាកាលដែលធ្វើសង្គ្រាមជាមួយនឹងវៀតណាមនោះ វាមិនមានជារឿងរបស់ប្រធានស-២១ បង្កើតឡើងទេ។ អារឿងច្បាំងគ្នារវាងវៀតណាមនិងកម្ពុជា វាជារឿងរបស់បក្សកុម្មុយនីស្តកម្ពុជា ជាមួយនឹងបក្សសង្គមវៀតណាម។ វាជារឿងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាមួយនឹងរដ្ឋាភិបាលវៀតណាម វាមិនមែនរបស់រឿងតា ឌុច ទេ។ រួចអាហ្នឹងថា ដែលថាយក តា ឌុច មកទទួលថ្នូបាក់ហ្នឹង។ រួចចុះអ្នកមេបក្ស មេរដ្ឋាភិបាល គេនៅរស់តើ បីបួននាក់នៅឯណោះ គេនៅរស់តើ ម៉េចមិនទៅប្តឹងគេនុ៎ងទៅ រួចមកចោទលើ តា ឌុច។

ដូច្នេះ អាហ្នឹងក៏ តា ឌុច ទទួលអត់បានទៀត។ អ៊ីចឹងដប់ឆ្នាំចុងក្រោយនេះ ក៏ត្រូវរលាយទៀត អស់រលីង ឌុច អត់មានស្អីទេ អត់ចោទប្រកាន់បានទេ។

ជាចុងក្រោយ ខ្ញុំមើលឃើញថា ឌុច បានឃុំខ្លួនដប់ឆ្នាំហើយៗ ហើយមេគុកដទៃទៀត ១៩៥ មេគុក ក៏តុលាការមិនអាចចាប់យកមកជំនុំជម្រះបានដែរ។ អ៊ីចឹងទេ ជាពេលវេលាមួយសមស្របដែលតុលាការអាចអនុញ្ញាតដោះលែង ឌុច ឲ្យមានសេរីភាព ឲ្យឌុចទៅផ្ទះវិញបានហើយ។ សូមអរគុណ។

សូមតុលាការអនុញ្ញាតឲ្យលោកមេធាវីអន្តរជាតិមេត្តាធ្វើសេចក្តីសន្និដ្ឋានបន្ត។ សូមអរគុណ។

[១១:០៧:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

អរគុណលោកប្រធាន។ ឥឡូវនេះយើងសូមបើកពន្លឺទៅលើសំណួរដែលបានលើកឡើង ក៏ដូចជាសំណួររបស់សហការីរបស់ខ្ញុំបានលើកឡើង។

ទីមួយ ទាក់ទងទៅនឹងបញ្ហាបច្ចេកទេសមួយចំនួនដែលសហព្រះរាជអាជ្ញាអន្តរជាតិជំទាស់តវ៉ាទៅនឹងអ្វីខ្ញុំដែលបានលើកឡើងកាលម្សិលមិញ។ ហើយលោកបានលើកជាឧទាហរណ៍ ចំពោះកំហុស

ដែលខ្ញុំបានលើកឡើង ដែលខ្ញុំបាននិយាយថាសារណាចុងក្រោយរបស់លោក ដែលជាសារណាចុងក្រោយរបស់លោក មិនអ៊ីចឹង គឺមិនបានលើកឡើងសូម្បីតែកន្លះឃ្លាផង ទាក់ទងទៅនឹងការទទួលខុសត្រូវការទទួលសារភាពទៅលើការទទួលខុសត្រូវនេះ។

ហើយពីព្រឹកមិញនេះ សូមមើលទៅលើទំព័រទី៦ ទំព័រទី៦ លើអត្ថបទអីដែលលោកនិយាយយោងហ្នឹង។ ទំព័រទី៦ នៃសារណាចុងក្រោយរបស់លោកដែលបានដាក់ជូនដប់ប្រាំថ្ងៃមុននេះ មានកថាខណ្ឌមួយ គឺកថាខណ្ឌ៨ ដែលសហព្រះរាជអាជ្ញាសរសេរនៅក្នុងកថាខណ្ឌមួយទទួលស្គាល់ថា ជនជាប់ចោទបានទទួលយកនូវអង្គហេតុ។ អង្គហេតុដែលទាក់ទងទៅនឹងបទល្មើសដែលបានលើកឡើងសំខាន់ៗ ហើយដែលមានការសហការជាមួយនឹងអាជ្ញាធរ ហើយក៏បានមានការស្នើសុំឲ្យការអភ័យទោសពីជនរងគ្រោះ ក៏ដូចពីសំណាក់ក្រុមគ្រួសាររបស់គាត់។ លោកបានលើកឡើងថា នេះគឺជាការបរិច្ចាគមួយដ៏ធំដែលគួរតែត្រូវបានយកមកពិចារណា ជាស្ពានសម្រាលមួយ ទាក់ទងទៅនឹងការកាត់ទោស។

លោក សហព្រះរាជអាជ្ញា, ដែលខ្ញុំជឿថាកថាខណ្ឌគឺលោកបានលើកឡើងនៅក្នុងសារណាចុងក្រោយរបស់លោកដែលបានទទួលស្គាល់ថាកថាខណ្ឌនេះ មិន-- ដូចខ្ញុំលើកឡើងកាលពីម្សិលមិញ ថាវាមិនមានទេ មិនបានកើតឡើង មិននូវនៅក្នុងសារណាចុងក្រោយ គឺសារណាមួយដែលលោកបានបញ្ជូនមកសហចៅក្រមស៊ើបអង្កេតដើម្បីឲ្យធ្វើការស៊ើបអង្កេត។ សម្រាប់រយៈពេលស៊ើបអង្កេតក្នុងមួយឆ្នាំ ជនជាប់ចោទទទួលស្គាល់នូវអង្គហេតុ គាត់សុំឲ្យមានការអភ័យទោស។ គាត់បានធ្វើគ្រាប់សាឡើងវិញ ហើយនៅក្នុងសារណាសង្ខេបរបស់លោក គឺលោកមានតែកន្លះឃ្លាតែប៉ុណ្ណឹង ដែលនិយាយទៅលើការពិត ហើយខ្ញុំសូមលើកចំណុចហ្នឹងឡើងនៅថ្ងៃនៅនេះ។

[១១:១១:៣៨]

ពាក្យពេចន៍របស់ខ្ញុំទាក់ទងទៅនឹងភ័ស្តុតាងដែលខ្ញុំនិយាយនោះ នៅក្នុងសារណាសង្ខេបរបស់លោក។ សារណាដែលមាន១៦ទំព័រ ដែលលោករិះគន់ទាក់ទងថាវាមានការលក្ខណៈទូលំទូលាយឲ្យបានគ្រប់គ្រាន់។ ជាទូទៅមុននឹងខ្ញុំនឹងឆ្លើយ ខ្ញុំសូមអានអ្វីដែលបានចោទ ដែលខ្ញុំបានតវ៉ា។ ខ្ញុំមិនបានឃើញ-- ខ្ញុំមិនអាច-- ខ្ញុំមិនដឹងទឡ្ហីករណ៍របស់លោកនៅក្នុងអត្ថបទ១១៦ទំព័រ នោះយ៉ាងណានោះទេ។ ខ្ញុំ ដូច្នេះខ្ញុំសរសេរតែ១៦ទំព័រ ដើម្បីទាក់ទងថាតើទឡ្ហីករណ៍របស់លោកអាចហ្នឹងលើកឡើងពីចំណុចណាខ្លះដែលលោកនឹងដាក់ជូនអង្គជំនុំជម្រះ? ដូច្នេះក្នុងនាមជាមេធាវី គឺខ្ញុំអត់បានដឹងអំពីទឡ្ហីករណ៍ដែលលោកបានដាក់ជូនមកអង្គជំនុំជម្រះទេ ដើម្បីធ្វើការឆ្លើយនៅក្នុងសវនាការនេះ។

លោកប្រធាន លោកស្រីចៅក្រមជាទីគោរព, ខ្ញុំចង់ដឹងឲ្យច្បាស់ ហើយចង់ឲ្យម្នាក់ៗដឹងឲ្យបានច្បាស់ទាំងអ្នកនៅក្នុងបន្ទប់សវនាការនេះ ក៏ដូចនៅក្រៅបន្ទប់សវនាការ ដែលថាមេធាវីការពារក្តីមិនស្វែងរកនូវយុទ្ធសាស្ត្រណាមួយ។ នេះពាក្យនេះ ខ្ញុំអត់ចូលចិត្តប្រើទេ ពាក្យ "យុទ្ធសាស្ត្រ" ខ្ញុំមិនដឹងថាពាក្យនេះ វាអាចអនុវត្តបាននៅក្នុងប្រព័ន្ធច្បាប់របស់ខ្ញុំ ឬក៏អត់ទេ។ វាជាកាតព្វកិច្ចរបស់មេធាវីការពារក្តី ហើយដែលត្រូវមានបំណងដើម្បីធ្វើឲ្យវាទាក់ទងទៅនឹងក្របខ័ណ្ឌផ្លូវច្បាប់នូវអ្វីដែលជនជាប់ចោទបានលើកឡើងតាំងពីឆ្នាំ១៩៩៩ នៅពេលដែលគាត់ចាប់ខ្លួនពីលើកដំបូង។

ចាប់តាំងពីឆ្នាំ១៩៩៩ មក នៅពេលដែលជនជាប់ចោទត្រូវបានចាប់ខ្លួន គាត់បាននិយាយថា "ខ្ញុំទទួលស្គាល់ឧក្រិដ្ឋកម្មដែលខ្ញុំបានប្រព្រឹត្ត"។ នៅពេលដែលជនជាប់ចោទនាំខ្លួនមក ចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញនេះ គាត់ថា ខ្ញុំទទួលស្គាល់ឧក្រិដ្ឋកម្មទាំងអស់ដែលខ្ញុំបានប្រព្រឹត្ត។ ខ្ញុំសូមឲ្យមានការអភ័យទោសពីជនរងគ្រោះ ហើយគាត់ក៏បានបន្ថែមផងដែរ គាត់បាន-- "ខ្ញុំក៏ទទួលខុសត្រូវតាមផ្លូវសីលធម៌ ចំពោះគ្រប់ឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបនៃបក្សកុម្មុយនីស្តកម្ពុជា ដោយសារតែខ្ញុំជាសមាជិកមួយនៃបក្សនេះ"។

ហេតុដូច្នេះហើយ មេធាវីការពារក្តី គឺចង់ប្រែក្លាយចំណុចនោះឲ្យវាចូលទៅក្នុងទម្លើករណ៍តាមច្បាប់ដើម្បីឆ្លើយតបទៅនឹងអ្វីដែលជនជាប់ចោទគាត់បានឆ្លើយតបអស់ពីពោះពីពុងរបស់គាត់។ លោកក៏មានបំណងជំទាស់តវ៉ាទៅនឹងការនិយាយយោងទៅលើច្បាប់អន្តរជាតិទាក់ទងទៅនឹងការផ្តន្ទាទោសដែលនឹងត្រូវដាក់ចេញនូវ-- ប្រៀបធៀបទៅនឹងករណីប្រហាក់ប្រហែលគ្នា។

[១១:១៥:៤២]

លោកប្រហែលក៏អាចមានបំណងផងដែរ គឺថាលើកឡើងអំពីរឿងក្តីរបស់ អុប្រ៊ែណូវិច ដើម្បីឲ្យស្ថិតនៅក្នុងកម្រិតអប្បបរមា។ ដោយសារលោកធ្លាប់នៅក្នុង ធ្វើការនៅក្នុងអតីតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី លោកប្រហែលជាដឹងច្បាស់ហើយ និយាយអំពីសារសំខាន់ លោកដឹងអំពីយុទ្ធសាស្ត្រនៅ ស្រ៊ិប្រេនីសា។ លោកដឹងអំពីសហគមន៍ទាំងមូលគាត់មានអារម្មណ៍យ៉ាងណាទាក់ទងទៅនឹងចំណុចនោះ?

មនុស្សទាំងនេះ ដែលស្ថិតនៅក្រោមការការពាររបស់អង្គការសហប្រជាជាតិ នៅក្នុងរយៈពេលបីថ្ងៃ គឺត្រូវបានសម្លាប់ទាំងឈុតៗ ដោយសារតែ អុប្រ៊ែណូវិច នេះឯង។ ក្នុងរយៈពេលតែបីថ្ងៃ មនុស្សប្រាំពីរពាន់នាក់ ត្រូវបានគេសម្លាប់ ដែលយើងទាំងអស់គ្នាគួរតែការការពារពួកគេ។ ស្រ៊ិប្រេនីសា ជាទី

កន្លែងមួយ គឺថាដែលត្រូវទទួលរងបញ្ហានេះ។

ចៅក្រមដែលលោកបានឃើញកាលពីម្សិលមិញ តាមរយៈការបញ្ចាំងវីដេអូ-- អង្គជំនុំជម្រះជាទីគោរព, ដើម្បីពិចារណាទៅលើវិប្បដិសារីប្រកបដោយភាពស្មោះត្រង់របស់ អុប្រើណូវិច គឺថាគេបានយកការវិប្បដិសារីមកធ្វើការពិចារណាទាក់ទងកិច្ចសហប្រតិបត្តិការដែលជាកិច្ច ជាចំណុចមួយសំខាន់ ហើយគេក៏បានផ្តន្ទាទោសដាក់ពន្ធនាគារ គាត់តែ១៧ឆ្នាំទេ។

ខ្ញុំសូមបន្តនៅរឿងក្តី អាល់ប៊ឺត ស្ពៀរ នៅចុងបញ្ចប់ លោកនិយាយថា គាត់បានការពារអ៊ីត្លែរនៅក្នុងផ្នែកណាមួយ ដោយគាត់អនុវត្តនូវគោលនយោបាយដែរថា គាត់មានមធ្យោបាយដែល-- គាត់ជារដ្ឋមន្ត្រីក្រសួងការពារជាតិ កុំភ្លេចឲ្យសោះថា គាត់ជារដ្ឋមន្ត្រីក្រសួងការពារជាតិ។ គាត់មានការទទួលខុសត្រូវខ្ពស់ជាងជនជាប់ចោទដែលកំពុងឈរនៅក្នុងមុខក្រចកសេះ នៅចំពោះមុខយើងនេះណាស់ គឺថាឧក្រិដ្ឋកម្មនោះធ្ងន់ធ្ងរជាងការចូលរួមក្នុងការជម្លៀសប្រជាជនរាប់លាននាក់ ប្រហែលជាលោកជម្រាបបញ្ហានេះហើយ។ ប៉ុន្តែ តុលាការនៅ នូរ៉ឹមប៊ឺក ទាក់ទងទៅនឹងគតិរបស់ខ្លួននោះ នៅក្នុងការយកមកពិចារណា ចំពោះការសារភាពទោសកំហុសពិរុទ្ធភាព រួមទាំងកិច្ចសហការជាមួយនឹងតុលាការផង។ នេះគឺថាមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

[១១:១៨:៥៦]

ថ្ងៃនេះទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានតបរបស់លោក លោកសហព្រះរាជអាជ្ញា ថាតើលោកអាចនិយាយថា ជនជាប់ចោទញុះញង់បង្កើតឲ្យមានសំណាញ់នៃការភ័យខ្លាចទូទាំងប្រទេសកម្ពុជាតែម្តង? មិនមានស្អីលើក-- ចំណុចនេះមិនបានលើកឡើងនៅក្នុងសំណុំរឿងទេ។ ប៉ុន្តែ នេះជាចំណុចមួយ គេហៅថាជាការលើកឡើងដោយបញ្ញាស្មារតីរបស់លោក ដែលខ្ញុំសុំជំទាស់តវ៉ា ដែលខ្ញុំបាននិយាយហើយថា ជនជាប់ចោទស្លាប់បាត់ទៅហើយ នៅស-២១ ហើយយើងមិនអាចប្រោសជីវិត ឬក៏យើងមិនអាចដាក់អ្វីចូលនៅក្នុងសំណុំរឿងដើម្បីនិយាយថា ដោយសារតែភាពភ័យខ្លាចនេះ នៅទូទាំងប្រទេសកម្ពុជាៗ។ លោកបាននិយាយអ៊ីចឹង។ តើលោកអាចជំទាស់តវ៉ាទៅលើអង្គហេតុ ឬក៏សំណួរបិទមុខដែលបានចោទសួរទៅលើជនជាប់ចោទ?

ដូចដែលខ្ញុំបានប្រាប់គាត់ហើយថា នេះអ្វីដែលគេចោទអ្នកឯងតាមរយៈលោក រ៉ូប៊ឺត ពេទីត។ យើងនឹងជម្រាបជូនតុលាការក្នុងតុលាការ ថាតើលោកទទួល ឬក៏បដិសេធនូវអ្វីដែលលោក រ៉ូប៊ឺត ពេទីត លើកឡើង? ក្នុងករណីនេះគាត់ឆ្លើយថា បាទៗ។ នៅពេលដែលលោកសួរជនជាប់ចោទថាអ្នកឯងទទួល

ខុសត្រូវឬក៏មិនទទួលខុសត្រូវ? នេះជាគេហៅថា សំណួរបិទមុខមួយ។ ចំណុចនេះមិនបានហាមឃាត់នៅក្នុងប្រព័ន្ធខំមិនឡទេ។ មានសំណួរជាច្រើនដូចដែលខ្ញុំត្រូវនិយាយនេះ ដែលយើងបានធ្វើទៅតាមការគិតរបស់យើង នេះមិនមែនជាគំនិតរបស់ខ្ញុំទេ នេះគឺជា-- សហព្រះរាជអាជ្ញានៅក្នុងការិយាល័យរបស់លោក។ ដូចខ្ញុំចោទអ្នកឯងពីបទល្មើសនេះ ខ្ញុំចោទសួរអ្នកឯងអ្នកយល់ស្របទេ? ហើយ ឌុច ឆ្លើយថា "យល់ព្រម"។

ដូច្នេះ លោកបានសួរទៅគាត់ ដែលគាត់បានជម្រាបជូនអង្គជំនុំជម្រះថា គាត់ជឿទៅលើ សុន សេន ទុកចិត្ត សុន សេន តើ ស្ដៀវ និយាយថាម៉េចដែរ អាល់បឺត ស្ដៀវ គាត់បានិយាយថាម៉េចដែរ? ស្ដៀវ និយាយថា ខ្ញុំពេញចិត្តពេញថ្លើមធ្វើតាមអ៊ីត្លែរ។ ចំណុចដែលខ្ញុំទុកចិត្តទៅលើ សុន សេន នេះមិនមានន័យថា ថ្ងៃនេះ គាត់មិនចាត់ទុកថា សុន សេន ជាមនុស្សរបៀបណាកាលពីពេលនោះទេ។ សុន សេន ជាអ្នកដឹកនាំជាន់ខ្ពស់មួយនៅក្នុងប្រទេសនេះ ដែលគួរតែនាំខ្លួនមកចំពោះមុខតុលាការនេះ ជំនួសឲ្យជាជាងនាំជនជាប់ចោទមក។

ដូច្នេះកុំឲ្យជនជាប់ចោទទទួលខុសត្រូវនូវអ្វីដែលគាត់ធ្វើ។ យើងដឹងច្បាស់ហើយដែលចំណុចនេះឯងដែលយើងចោទប្រកាន់ទៅលើគាត់ គាត់ជឿបក្សកុម្មុយនីស្ដកម្ពុជា គាត់ធ្វើតាមដើរតាមបក្សកុម្មុយនីស្ដកម្ពុជា គាត់អនុវត្តតាមបញ្ជារបស់បក្សកុម្មុយនីស្ដកម្ពុជា។ នេះ ហេតុផលនេះឯងបានជាគាត់មានវត្តមាននៅទីនេះនៅថ្ងៃនេះ។

កាលណាខ្ញុំនិយាយពីសោកនាដកម្មនេះ ជាការពិតណាស់ ខ្ញុំមានសំណួរដែលត្រូវចោទសួរទៅលោក លោកសហព្រះរាជអាជ្ញាលោកជឿថា ប្រសិនណាបើ ឌុច លាលែងពីតួនាទីរបស់គាត់ជាប្រធាន ស-២១ លោកជឿថាស-២១ ឈប់ដំណើរការទេបើសិនជា ឌុច លាលែងនៅពេលណាមួយហ្នឹង? តើបើសិនជាមាន ឌុច ឬមិនមាន ឌុច ហ្នឹង តើ ស-២១ វានឹងតមានដំណើរប្រតិបត្តិការតទៅ ឬក៏មិនមានប្រតិបត្តិការតទៅទៀតទេ? ដែលយើងចាត់ទុកថា ជាម៉ាស៊ីនសម្លាប់មនុស្សមួយដែលស្ថិតនៅក្នុងកណ្ដាប់ដៃរបស់ សុន សេន។ ឥឡូវនេះ យើងកំពុងតែវិនិច្ឆ័យទៅលើ ឌុច ដែល ឌុច កំពុងតែវង្វេងវង្វាន់ហើយ ដែលយើងទាំងអស់គ្នាជឿថា គាត់វង្វេងវង្វាន់នៅក្នុងចលនាបដិវត្តនេះ។ មុនពេលគាត់ចាត់ផ្ដើមគាត់ចលនាបដិវត្តនេះវាល្អណាស់សម្រាប់គាត់។ ដោយសារតែវាជាការចាំបាច់ ដើម្បីត្រលប់មកលើបញ្ហាអនុវត្តជាក់ស្ដែង អង្គជំនុំជម្រះជាទីគោរព ហើយក៏ជាមួយគ្នានេះដែរក៏នឹងពាក់ព័ន្ធនឹងបញ្ហាផ្លូវច្បាប់ផងដែរ។

[១១:២៣:៥៣]

ដូចដែលយើងទើបតែនឹងបានឃើញនៅក្នុងកថាខណ្ឌនៃទំព័រ៦ និងកថាខណ្ឌ៨ ដែលទទួលស្គាល់ថា ប្រាកដជាមានស្ថានសម្រាលទោស។ ហេតុដូច្នេះ យើងខ្ញុំជាមេធាវីការពារក្តី សូមចោទសួរដោយស្មោះត្រង់ទៅអង្គជំនុំជម្រះដើម្បីឲ្យដឹងថា ជនជាប់ចោទនេះត្រូវតែទទួលបានប្រយោជន៍ពីស្ថានសម្រាលទោសនេះ។ ខ្ញុំនឹងមិននិយាយលំអិតទៅលើចំណុចនេះទេ ពីព្រោះខ្ញុំបានស្តាប់លម្អិតកាលពីម្សិលមិញហើយ។ ស្ថានសម្រាលទោសដែលជនជាប់ចោទត្រូវតែទទួលបាន ដោយសារតែគាត់ធ្វើតាមបញ្ជារបស់មេគាត់ គ្មានអ្នកណានិយាយបានថា ឌុច ជាគ្រាន់តែជាដុំស្ពឺមួយនៅក្នុងម៉ាស៊ីន ស្ថិតនៅក្នុងខ្សែសង្វាក់នៃការបញ្ជាចាប់ពី ប៉ុល ពត មករហូតមកដល់អ្នកដែលមានឋានៈតូចនៅស-២១។ បើសិនម្នាក់ៗត្រូវតែគោរពបញ្ជា បើសិនណាទទួលបានបញ្ជាពីមេនៅក្នុងខ្សែសង្វាក់នៃការទទួលបញ្ជានេះ។ ដោយសារមេដឹកនាំទាំងអស់នោះជាមេដឹកនាំដែលមានអំណាចនិងមានសភាពឃោរឃៅ ដូច្នេះ ឌុច មិនអាចរត់ចេញពីក្នុងខ្សែសង្វាក់នៃការបញ្ជានេះបានទេ មិនដូច ម៉ម ណៃ នោះទេ។ កាលណាមេគាត់ដាក់មក គឺថាម្នាក់ៗដែលជាកូនចៅ គឺថាត្រូវតែអនុវត្តនូវការបញ្ជារបស់ថ្នាក់លើនេះ។

ដូច្នេះ ខ្ញុំសូមអង្វរកទៅដល់អង្គជំនុំជម្រះ មេត្តាគិតគូរពិចារណាគ្រប់ពេលវេលានៅក្នុងដំណើរការនីតិវិធីនេះ នូវសេចក្តីសម្រេចថ្ងៃទី១៣ ខែមីនា ១៩៧៦ ទាក់ទងទៅនឹងការសម្រេច ការកម្ចាត់មនុស្សចោលនៅក្នុងចលនាបដិវត្តន៍នោះ។ កុំភ្លេចទៅលើសេចក្តីសម្រេចថ្ងៃទី៣០ មីនា ១៩៧៦។ នៅក្នុងសេចក្តីសម្រេចនេះ ឌុច មិនបានចូលនោះទេ គឺថាសេចក្តីសម្រេចនេះចេញឡើងដោយគណៈអចិន្ត្រៃយ៍ ប៉ុន្តែគាត់បានទទួលការណែនាំការបញ្ជាតាមរយៈសេចក្តីសម្រេចដ៏សោកនាដកម្មនេះ ដ៏បង្ខិតបង្ខំនេះ។

ដូច្នេះ ក្នុងនាមកូនចៅដែលគោរពទៅតាមមេ ដូចដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញ គឺថាគាត់មិនអាចរត់ចេញ ឬក៏គេចចេញបានទេ។ ឌុច ដែលបានលើកឡើងក៏ចំណុចដែល ឌុច លើកឡើងក៏ដូចជាកម្មាភិបាលមួយចំនួនទៀតបានរៀបរាប់ ដូចសហការីរបស់ខ្ញុំ ការ សាវុត្ថ គឺថាយើងកំពុងតែប្រឈមនឹងបញ្ហានៃស្ថានសម្រាលទោសនេះ។

[១១:២៦:៥៥]

ចំណុចទីពីរ គឺទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការ។ យើងមិនទាន់បាននិយាយឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ ហើយមិនមានកិច្ចជំទាស់ណាទាក់ទងនឹងនេះ វិប្បដិសារី ការចូលរួម និងសេចក្តីស្មោះត្រង់ ការសោកស្តាយសេចក្តីស្មោះត្រង់។ ខ្ញុំលើកឡើងពីចំណុចទាំងអស់នេះ។ ទឹកភ្នែកដែល

សម្រក់ ទឹកភ្នែដែលសម្រក់នៅជើងឯក នៅស-២១ ទឹកភ្នែកដែលសម្រក់នៅទីនេះ ខ្ញុំគិតថា អង្គជំនុំជម្រះប្រាកដជាបានជ្រាបថា ជនជាប់ចោទនេះបានបញ្ជាក់ នូវការសោកស្តាយរបស់គាត់ជាច្រើនលើកច្រើនសា ហើយសុំជនរងគ្រោះមេត្តាឲ្យអភ័យទោសឲ្យគាត់។ “នៅពេលជាមួយគ្នានេះ ខ្ញុំមិនស្នើសុំឲ្យអង្គជំនុំជម្រះអភ័យទោសឲ្យខ្ញុំទេ។ ខ្ញុំសូមគ្រាន់ថា បើកទ្វារចំហរដើម្បីទទួលយកនូវបញ្ហានេះ”។

ទាក់ទងទៅនឹងអត្តចរិត នេះក៏ជាចំណុចមួយឆ្លើយតបទៅនឹងស្ថានសម្រាលទោសដែលគួរតែត្រូវបានយកមកពិចារណាផងដែរ ការកែប្រែ។

ខ្ញុំសូមលើកជូនអង្គជំនុំជម្រះជាថ្មីម្តងទៀត នូវអ្នកទាំងឡាយណាដែលបានវិភាគយ៉ាងស៊ីជម្រៅទៅលើការ-- នេះខ្ញុំនិយាយសំដៅទៅលើខាងផ្នែកចិត្តសាស្ត្រដែលសហព្រះរាជអាជ្ញាបានចាត់តាំងហើយអង្គជំនុំជម្រះក៏បានទទួលយកនូវការចាត់តាំងគ្រូពេទ្យជំនាញនេះដែរ ហើយបានមកនិយាយគ្នាជាមួយនឹង ឌុច ដែលយើងបានចងក្រងឯកសារនៃការវាយតម្លៃរបស់គ្រូពេទ្យនោះហើយ។ ហើយយើងមានចំណុចនេះគឺថា យើងចងចាំនៅក្នុងចិត្តក្នុងខ្លួនរបស់យើង។ គាត់បានរៀបរាប់ជូនអង្គជំនុំជម្រះថា ក្នុងអំឡុងពេលនេះយើងមានសាក្សីៗ ដែលពាក់ព័ន្ធទៅនឹងការវិវត្តន៍ខាងផ្នែកចិត្តសាស្ត្រ។

[១១:២៩:០៥]

ខ្ញុំសូមជាសំណួរៈ ថាតើ ឌុច នេះអាចមានសភាពមកជាមនុស្សម្នាមកវិញឡើងវិញតាំងពីគាត់-- ក្នុងផ្នែកអ្នកជំនាញទាំងអស់ដែលគេបានចងក្រងឯកសារដែលយើងបានយកមកសំអាង ដែលចាត់ទុកថាគាត់នេះជាឃាតកសម្លាប់មនុស្សនោះ ថាតើគាត់ធ្វើឲ្យបាត់បង់ភាពតម្លៃជាមនុស្សរបស់គាត់ដែរឬក៏យ៉ាងណា?

លោកស្រី ស៊ីរ៉ូនី បានរៀបរាប់ទៅលើធាតុផ្សំជាច្រើនដែលគាត់បានវិភាគ ទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ ហើយយើងនិយាយអំពីជនជាប់ចោទ។ ហើយទាក់ទងទៅនឹងការបង្កើតអត្តសញ្ញាណសមូហភាពដែលវាមាននៅក្នុងជនជាប់ចោទ ហើយនៅក្នុងនោះក៏បានវិភាគអំពីចិត្តសាស្ត្ររបស់ជនជាប់ចោទ ចាប់តាំងពីពេលដំណើរការនីតិវិធី ហើយយើងអាចនិយាយឆ្លើយតបថា វាពិតជាមានករណីទាំងអស់នេះ។ មិនមាននរណាម្នាក់កើតមកជាពេជ្ឈឃាដនោះទេ។ មនុស្សទាំងឡាយនឹងក្លាយទៅជាពេជ្ឈឃាដ ហើយយើងក៏អាចក្លាយទៅជាមនុស្សម្នានឹងគេវិញផងដែរ។ នៅពេលដែលនេះ ខ្ញុំនិយាយអំពី ស៊ីរ៉ូនី ឡើងវិញ ខ្ញុំសួរសំណួរគាត់មួយសំណួរ។ នៅពេលដែលខ្ញុំសួរគាត់ “ថាតើមានការពិបាកក្នុងការសារភាពរបស់ជនជាប់ចោទដែរឬទេ?” គាត់បាននិយាយថា “ជាការពិតការទទួលស្គាល់

ទៅលើបញ្ហាដ៏ធ្ងន់ធ្ងរនេះ គឺវាកើតមាននៅក្នុងចិត្ត” គឺគាត់បានបន្ថែមថា “គាត់ពិតជាមានភាពស្មោះត្រង់ វាកើតឡើងនៅក្នុងដំណើរការនេះ”។

លោក លោកស្រីចៅក្រមជាទីគោរព, យើងពិតជាកំពុងតែប្រឈមនឹងបញ្ហានៃស្ថានសម្រាលទោសដែលយុទ្ធសាស្ត្រជាតិ និងអន្តរជាតិទាមទារឲ្យមាន ឲ្យផ្តល់ជូននូវស្ថានសម្រាលទោសនេះ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតដកស្រង់នូវសម្តីច្បាប់ស្តីពីការកាត់ទោសនៅប្រទេសញូវហ្សេឡែន នៅឆ្នាំ ២០០២ ដែលចែងថា “ទោសត្រូវតែពិចារណាទៅលើទិដ្ឋភាពនៃយុត្តិធម៌ ដែលរួមទាំងការផ្តល់ជូន ឬក៏ការផ្តល់ការសារភាពការសោកស្តាយ និងការសារភាពទៅលើអង្គហេតុនានាផងដែរ ហើយរួមទាំងអត្តចរិតរបស់ជនជាប់ចោទ”។ ដូច្នេះយើងត្រូវពិចារណាទៅលើទាំងគំនិតទាំងអស់នេះ។ បុគ្គលម្នាក់ដែលគាត់ប្រព្រឹត្តឧក្រិដ្ឋកម្ម រួមទាំងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផងនោះ គាត់អាចកែប្រែខ្លួនគាត់បានផងដែរ។ ដូច្នេះហើយវា ប្រសិនបើយើងមិនគិតពិចារណាលើចំណុចនេះទេ នឹងមិនមានភាពយុត្តិធម៌ឡើយ។

[១១:៣២:៤៧]

ខ្ញុំសូមគោរព លោកស្រីចៅក្រមជាទីគោរព, ព្រះរាជាណាចក្រកម្ពុជា នៅក្នុងគម្រោងរៀបចំក្រមព្រហ្មទណ្ឌរបស់ខ្លួន ប្រសិនបើខ្ញុំទទួលព័ត៌មាននេះបានត្រឹមត្រូវនោះ ក្រមនេះនឹងចូលជាធរមាននាពេលឆាប់ៗនេះ។ នៅក្នុងមាត្រា១២២២ គឺមានចែងថា ទោសជាប់ពន្ធនាគារមួយជីវិត និងស្ថានសម្រាលទោស គឺមានចែងទៅលើចំណុចទាំងអស់នេះ។ អ្នកច្បាប់ប្រទេសកម្ពុជា នៅក្នុងក្រមព្រហ្មទណ្ឌនោះបានបញ្ចូលនូវមាត្រាថា នៅពេលដែលមានការរំលោភណាមួយទៅលើការដាក់ទោស-- នៅពេលដែលមានការរំលោភណាមួយ ការដាក់ទោសជាប់ពន្ធនាគារមួយជីវិត ត្រូវតែបន្ថយមកត្រឹម១៥ឆ្នាំ ទៅ៣០ ឆ្នាំ ។

លោក លោកស្រីជាទីគោរព, យើងមិនខ្វល់ថា តើទោសបែបណាដែលលោក លោកស្រីចៅក្រម និងផ្តល់ជូន ឬក៏កំណត់ទៅលើជនជាប់ចោទនោះទេ វាមិនអាចជួយស្រោចស្រង់ទៅលើជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ គេនឹងលើកឡើងថា វាមិនគ្រប់គ្រាន់។ ហើយយើងត្រូវតែគោរពច្បាប់ឲ្យបានច្បាស់លាស់។ ច្បាប់ព្រហ្មទណ្ឌថ្ងៃនេះ គឺវាមានលក្ខណ:រឹងប៉ឹង និងដែលយើងត្រូវយកមកពិចារណា។

ដូច្នេះហើយយើងខ្ញុំដាក់ជូននូវចំណុចទាំងអស់នេះ ហើយយើងខ្ញុំសង្ឃឹមថា នៅពេលដែលលោក លោកស្រីចៅក្រម ពិចារណាទៅលើច្បាប់នេះដែលកំពុងតែរៀបចំនៅក្នុងប្រទេសកម្ពុជា ហើយប្រសិន

បើលោក លោកស្រីចៅក្រមពិចារណាទៅលើសំណាងដែលជនជាប់ចោទ គាត់ទទួលបានដោយសារតែមានការរំលោភសិទ្ធិរបស់គាត់ ដោយសារតែគេដាក់ឃុំខ្លួនគាត់អស់រយៈពេលប្រាំបីឆ្នាំនៅក្នុងទម្រង់ខុសច្បាប់ បានន័យថាគាត់ជាប់ឃុំខុសច្បាប់រយៈពេលប្រាំឆ្នាំ គឺគាត់ជាប់អស់រយៈពេលសរុបប្រាំឆ្នាំ ដែលក្នុងនោះប្រាំឆ្នាំខុសច្បាប់។

ដូច្នេះ សិទ្ធិរបស់គាត់ គឺគេបានរំលោភរយៈពេលជាប់ឃុំចំនួនប្រាំឆ្នាំ។ ហើយប្រសិនបើយើងពិចារណាទៅលើកត្តានេះ ហើយយើងពិចារណាទៅលើស្ថានសម្រាលទោស ហើយយើងត្រូវពិចារណាថា យើងយល់ច្បាស់ទៅលើចំណុចទាំងអស់នេះ។ នៅក្នុងប្រទេសនេះ យើងឃើញថាមានប្រជាជន និងពលរដ្ឋជាច្រើនដែលគាត់ទទួលរងទៅលើបញ្ហានេះជាង ឌុច ទៅទៀត ហើយអ្នកទាំងអស់នោះ គឺគាត់មិនត្រូវបានគេយកមកផ្តន្ទាទោសឡើយ។

ជនជាប់ចោទ គាត់បានជាប់ឃុំស្ទើរតែដប់ឆ្នាំមកហើយ។ យើងដឹងទៅលើបញ្ហានេះ។ ដូច្នេះ យើងមិនអាចធ្វើការប្រៀបធៀបផងទៅលើមេដឹកនាំ ឬក៏ប្រធានសន្តិសុខដទៃទៀត ហើយយើងក៏មិនអាចទាញការសន្និដ្ឋានថាអ្នកណាខ្លះដែលនៅពីលើគាត់ ហើយដែលត្រូវយកមកធ្វើការជំនុំជម្រះនោះ។ ខ្ញុំអាចយល់ទៅលើចំណុចទាំងអស់នេះ ច្បាប់នៃការអត់ឱនទោស លើកលែងទោសជាទូទៅ ខ្ញុំយល់នៅពេលដែលនាយករដ្ឋមន្ត្រីនៃប្រទេសនេះ គឺដើម្បីជាគោលការណ៍សន្តិភាព។ ខ្ញុំយល់ស្របទទួលស្គាល់ទៅលើចំណុចនេះ។ ខ្ញុំចង់បញ្ចប់សង្គ្រាមស៊ីវិល ហើយចង់ឲ្យសន្តិភាពជាមួយនឹងខ្មាំង ឬក៏សត្រូវទាំងឡាយ។ ហើយខ្ញុំយល់ទៅលើចំណុចទាំងអស់នេះ។ ប៉ុន្តែយើងត្រូវតែមានភាពយុត្តិធម៌ទៅលើចំណុចទាំងអស់នេះ ហើយយើងត្រូវឲ្យមានភាពយុត្តិធម៌ចំពោះបុគ្គលទាំងឡាយ ដែលគាត់បាតដៃប្រឡាក់សុទ្ធតែឈាម ជាងជនជាប់ចោទទៅទៀត ដែលអ្នកទាំងអស់នោះបានចូលរួមនៅក្នុងកងកម្លាំងយោធានៅក្នុងប្រទេសនេះ ដែលគេថាជាបដិវត្តន៍ក្នុងការឈានទៅដល់ការស្វែងរកសន្តិភាព។ ខ្ញុំយល់ស្របទៅលើចំណុចទាំងអស់នេះ។

[១១:៣៨:០២]

ដូច្នេះលោក លោកស្រីចៅក្រមត្រូវពិចារណាទៅលើកត្តាទាំងអស់នេះ នៅក្នុងសាលក្រមលោក លោកស្រីចៅក្រម។ ហើយយើងមិនអាចប្រែក្លាយជនជាប់ចោទ ឌុច នេះឲ្យក្លាយទៅជាអ្នកទទួលរងនូវថ្នបាក់នោះទេ។ ដូចដែលលោក លោកស្រីចៅក្រមបានចងចាំហើយ កាលពីម្សិលមិញ ខ្ញុំបានជម្រាបហើយថា ឌុច បានស្លាប់បាត់ទៅហើយ។ ហើយលោក លោកស្រីចៅក្រមចាំហើយនៅថ្ងៃទី២៥ ខែមិ

ចុនា ឆ្នាំ២០០៩ ឌុច បានពន្យល់អង្គសវនាការ និងលោក លោកស្រីចៅក្រមថា ថាតើគាត់ចូលរួមបដិវត្តន៍ក្នុងរបៀបណា ដែលគាត់មានជំនឿយ៉ាងជឿជាក់ទៅលើបដិវត្តន៍នេះ?

“ខ្ញុំមានបំណងក្នុងការផ្លាស់ប្តូរនៅខ្លួនខ្ញុំឱ្យក្លាយទៅជាមនុស្សសាមញ្ញ ទៅជាជនកុម្មុយនីស្ត។ នៅក្នុងឆ្នាំ១៩៦៤ ដែលខ្ញុំបានចាប់ផ្តើមធ្វើការងារនេះ ធ្វើការងារផ្លាស់ប្តូរខ្លួនរបស់ខ្ញុំទៅជាជនកុម្មុយនីស្ត។ ដូច្នេះតាមរយៈបក្ស ខ្ញុំក្លាយទៅជា ឌុច”។ ដូច្នេះ ពីឈ្មោះ កាំង ហ្គេកអ៊ាវ ដែលគាត់ជាគ្រូ គណិតវិទ្យានៅស្គន់។ ហើយគាត់ប្រែក្លាយខ្លួនគាត់ទៅជា ឌុច។ ដូច្នេះហើយខ្ញុំសង្ឃឹមថា លោក លោកស្រីចៅក្រមស្វែងយល់យ៉ាងច្បាប់ទៅលើសំណុំរឿងទាំងឡាយដែលមាន ហើយ ឌុច បានស្លាប់ទៅហើយ ដែលនៅសល់តែ កាំង ហ្គេកអ៊ាវ ដែលជាអតីតគ្រូគណិតវិទ្យាតែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំបញ្ចប់នូវសេចក្តីសន្និដ្ឋានតបរបស់ខ្ញុំរួចហើយ។ ខ្ញុំមានសំណើចុងក្រោយមួយជូនអង្គសវនាការ ខ្ញុំចង់ដឹងថាតើនៅពេលណាដែលអង្គសវនាការ លោក លោកស្រីចៅក្រមនឹងចេញសាលក្រមមកលើជនជាប់ចោទនោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក វីលៀម ស្មីត៖**

លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំមិនដឹងថាតើបញ្ជាក់ជាការបត់បែនឡើងវិញយ៉ាងម៉េច? មេធាវីការពារក្តីហាក់ដូចជាបត់បែន ឬក៏មិនបញ្ជាក់ច្បាស់លាស់ទៅនឹងសំណួររបស់ក្រុមប្រឹក្សាជំនុំជម្រះថាតើហេតុអ្វីបានជាមិនទទួលស្គាល់ទៅលើអង្គហេតុនេះ? ហើយហេតុអ្វីបានជាចង់ឱ្យមានការកាត់ឱ្យរួចខ្លួន? ដូច្នេះចំណុចនេះ គឺជាចំណុចមួយសំខាន់ដែលយើងត្រូវយល់ឱ្យច្បាស់។ ហេតុអ្វីបានមេធាវីការពារក្តីហ្នឹងគាត់មានជំហរពីរខុសគ្នាដូច្នេះ? ហើយប្រសិនបើគេចង់ឱ្យមានការសម្រាលទោសសម្រាប់ជនជាប់ចោទនោះ ហេតុអ្វីបានជាជនជាប់ចោទសុំឱ្យមានការកាត់ឱ្យគាត់រួចខ្លួន?

ជនរងគ្រោះនៃប្រទេសកម្ពុជាហាក់ដូចជាមិនមានអារម្មណ៍ធូរស្រាលសោះ ប្រសិនបើជនជាប់ចោទ គាត់និយាយថាគាត់ទទួលខុសត្រូវជាទូទៅ ប៉ុន្តែមិនត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់នោះទេ។ យើងខ្ញុំថាមេធាវីការពារក្តីទាំងពីរមិនបានឆ្លើយតបទៅនឹងសំណួររបស់ក្រុមប្រឹក្សាជំនុំជម្រះនោះទេ។ ដូច្នេះដោយសារតែការគេចចេញពីការឆ្លើយតបដូច្នេះ ខ្ញុំគិតថា ខ្ញុំស្នើសុំអង្គសវនាការឱ្យសួរទៅកាន់ជនជាប់ចោទ ថាតើជនជាប់ចោទបានផ្តោតការណែនាំណាមួយទៅដល់មេធាវីការពារក្តី ដើម្បីសុំឱ្យគាត់រួចខ្លួន

ដែរឬទេ? ប្រសិនបើមិនដូច្នោះទេ យើងហាក់ដូចជាទុកឲ្យសវនាការនេះលើកឡើងនៅជំហរពីរពីខាងមេធាវីការពារក្តី។

[១១:៤២:២៧]

"ទីមួយ ខ្ញុំមិនមានពិរុទ្ធភាព។ ខ្ញុំមិនទទួលស្គាល់ឡើយ" ហើយមិនមានការសម្តែងនូវការវិប្បដិសារីដោយស្មោះត្រង់ទេ តាមរយៈចំណុចនេះ។ ដូច្នេះយើងត្រូវតែដោះស្រាយទៅលើបញ្ហានេះទាំងអស់គ្នា។ ហើយប្រសិនបើអង្គសវនាការយល់ឃើញថានឹងរកឃើញថា គាត់ពិតជាសុំឲ្យមានការកាត់ឲ្យរួចខ្លួនមែននោះ។ ដូច្នេះបើសិនជាមានករណីហ្នឹងមែននោះ គឺអង្គសវនាការត្រូវតែធ្វើការសម្រេចទោសឲ្យបានធ្ងន់ទៅលើចំណុចនេះ។ ហើយប្រសិនបើជនជាប់ចោទនិយាយថា មេធាវីការពារក្តីមិនធ្វើការ មិនធ្វើតាមការណែនាំរបស់គាត់ ឬក៏ធ្វើតាមការណែនាំរបស់គាត់ផ្ទុយទៅវិញ។ ដូច្នេះហើយយើងត្រូវគិតទៅលើចំណុចទាំងអស់នេះ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព, មិនមាន ខ បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលទទួលស្គាល់ថាសហព្រះរាជអាជ្ញាអាចនឹងផ្តល់ការអនុញ្ញាតឲ្យទទួលវេទិកានេះបន្ទាប់ពីសេចក្តីសន្និដ្ឋានតបរបស់មេធាវីការពារទេ ប៉ុន្តែប្រសិនបើយើងមិនទាន់ច្បាស់នៅក្នុងចំណុចនេះទេ សូមអភ័យទោស។ ខ្ញុំសូមអភ័យទោស ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានស្តាប់ខ្ញុំឲ្យបានច្បាស់លាស់នោះទេ ឲ្យបានប្រុងប្រយ័ត្នទេ។ ពាក្យដែលថាសុំឲ្យលើកលែងការចោទប្រកាន់មិនបានប្រើទេ គឺយើងបានបញ្ជាក់ថាការកាត់ទោសជនជាប់ចោទ ប្រសិនបើរកឃើញពិរុទ្ធភាពនោះ គឺត្រូវបន្ថយចំនួនការកាត់ទោស គឺមេធាវីការពារក្តីខ្មែរមិនបានថាស្នើឲ្យលើកលែងនោះទេ បើសិនជាច្បាស់ចំណុចនេះទេ ខ្ញុំសូមទោសបើលោកស្តាប់មិនបាន។ គាត់នឹងត្រូវរួចខ្លួនបន្ទាប់ពីជាប់ពន្ធនាគារដប់ឆ្នាំ ហើយគាត់បានទទួលខុសត្រូវរបស់គាត់នៅស-២១ នោះ គាត់ទទួលស្គាល់មិនមានអ្វីកែប្រែទេ។

**លោក ការីម ខាន៖**

លោកប្រធាន សូមការអនុញ្ញាត--។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យនិយាយអ្វីទៀតទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៨:១៣]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដំណើរការនីតិវិធីនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គូរភាគីស្ទើរតែដល់ទីបញ្ចប់ហើយ ហើយនៅតែអ្នកចុងក្រោយបង្អស់ គឺជនជាប់ចោទ។ ហើយអង្គជំនុំជម្រះបានជម្រាបជូនជនជាប់ចោទអស់អម្បាញ់មិញអំពីសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានតបចុងក្រោយទៅនឹងការធ្វើសេចក្តីសន្និដ្ឋានតបរបស់ភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាដែលបានធ្វើការតបចុងក្រោយ ហើយនិងសិទ្ធិមួយដែលអង្គជំនុំជម្រះផ្តល់ជូនទៅជនជាប់ចោទគឺនិយាយសម្តីចុងក្រោយបង្អស់ ប្រសិនបើជនជាប់ចោទមានបំណង។ ប៉ុន្តែ ដូចជាមានការកត់សម្គាល់ជាច្រើនទាំងភាគីទាំងអង្គជំនុំជម្រះ គឺភាពយល់មិនច្បាស់លាស់រវាងសេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីទាំងពីររូប មេធាវីជាតិនិងអន្តរជាតិ ដែលអង្គជំនុំជម្រះបានរំឭកបញ្ជាក់មេធាវីទាំងពីរមុននឹងអនុញ្ញាតឲ្យមេធាវីទាំងពីររូប ឡើងធ្វើសេចក្តីសន្និដ្ឋានតបបញ្ចប់ចុងក្រោយ ប៉ុន្តែលទ្ធផលនៃការធ្វើសេចក្តីសន្និដ្ឋាននោះក៏នៅតែមានភាពមិនច្បាស់លាស់ មិនស៊ីសង្វាក់គ្នារវាងសេចក្តីសន្និដ្ឋានមេធាវីការពារក្តីទាំងពីរដែរ។

អ៊ីចឹងទេជាចុងក្រោយនេះ អង្គជំនុំជម្រះចង់ស្តាប់ផ្ទាល់ពីសម្តី ឬក៏ជំហររបស់ជនជាប់ចោទខ្លួនឯងផ្ទាល់នាពេលនេះ ដោយហេតុថា ទាំងអង្គជំនុំជម្រះ ទាំងមនុស្សសាធារណជនជាច្រើនបានកត់សម្គាល់ឃើញអំពីភាពចងចាំ អំពីភាពឈ្លាសវៃរបស់ជនជាប់ចោទនៅក្នុងដំណើរការនីតិវិធីកន្លងមកនេះ។ អង្គជំនុំជម្រះចង់ដឹងអំពីជំហរផ្ទាល់ខ្លួនរបស់ជនជាប់ចោទវិញថា តើលោកមានជំហរជាក់លាក់យ៉ាងម៉េចនៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយ ឬក៏ពាក្យសម្តីចុងក្រោយនេះ? ប្រសិនបើអាចធ្វើបាន គឺសូមជនជាប់ចោទ ឬក៏បង្ហាញនូវជំហរច្បាស់លាស់នៅក្នុងពេលដែលលោកធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ និងនិយាយសម្តីចុងក្រោយនេះ។ សូមអញ្ជើញ!

[១១:៥១:៣១]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន, ខ្ញុំសូមអរគុណក្នុងការដែលលោកប្រធានអនុញ្ញាតឲ្យខ្ញុំមានមតិជាចុងក្រោយបំផុតនេះ។

ដំបូងខ្ញុំសូមនិយាយអំពីស្មារតីសហការរបស់ខ្ញុំជាមួយតុលាការ។ ខ្ញុំត្រូវចាប់មកចូលដល់ពន្ធនាគារ តុលាការយោធានៅថ្ងៃ៨ ខែឧសភា ១៩៩៩។ ចាប់តាំងពីពេលមក ខ្ញុំតាំងចិត្តថា ដាច់ខាតរាយ-

ការណ៍ជូនតុលាការដោយស្មោះត្រង់គ្រប់បញ្ហាដែលតុលាការចង់ដឹង។ ហើយជាក់ស្តែងមែន។ នៅតុលាការយោធា ភ័ស្តុតាងជាឯកសារដែលខាងតុលាការយោធាប្រគល់ជូនអង្គជំនុំជម្រះមាននៅសល់ជាភ័ស្តុតាងស្រាប់នូវស្មារតីសហការរបស់ខ្ញុំ។ មកដល់ទីនេះ ខ្ញុំបានឆ្លើយទាំងអស់នឹងសំណួររបស់សហចៅក្រមស៊ើបសួរ ក៏ដូចជាសំណួរបន្ថែមរបស់ខាងសហព្រះរាជអាជ្ញាដែរ។ កំណត់ហេតុសួរចម្លើយនៅ អ.វ.ត.ក នេះជាភ័ស្តុតាងស្រាប់។

មកដល់អង្គសវនាការយើងនេះ មានការដេញដោលយ៉ាងពេញសមត្ថភាពរវាងភាគីទាំងអស់រួមទាំងរូបខ្ញុំបាទផង។ ប្រតិចារឹករាប់ម៉ឺនសន្លឹកជាភ័ស្តុតាងស្រាប់។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្ញុំដែលគោរពជូនលោកប្រធាន កាលពីថ្ងៃ២៥ ខ្ញុំសរសេរយ៉ាងខ្លីនៅក្នុងកថាខណ្ឌទី៨៦ ថាទិដ្ឋភាពរូបភាពទាំងឡាយនៃឧក្រិដ្ឋកម្មដែលឆ្លងកាត់មន្ទីរស-២១ ខ្ញុំគោរពជូនអង្គសវនាការ លោកវិភាគ និងសម្រេច។

[១១:៥៣:៥១]

បញ្ហានេះវាសឲ្យឃើញ ទីមួយស្មារតីរបស់ខ្ញុំក្នុងការគោរពសច្ចធម៌ ទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ខ្លួន ហើយនិងគោរពអង្គជំនុំជម្រះដោយឥតលក្ខខណ្ឌ។ ខ្ញុំមិននិយាយវែងទេ តែកាលណានិយាយវែង គឺចូលតថ្លៃ។ ដូច្នេះ ខ្ញុំគោរពជូនរឿងដែលកើតមាននៅក្នុងអង្គសវនាការនេះ ជូនអង្គសវនាការជំនុំជម្រះនេះខ្លី បីៗបន្ទាត់ទេ។ ខ្ញុំសរសេរតែបីបន្ទាត់ទេ នៅទំព័រទី៣០របស់ខ្ញុំ។

បើប្រៀបធៀបបីបន្ទាត់នេះទៅនឹងអត្ថបទដែលខ្ញុំសរសេរ៣៣ទំព័រ វាបានប្រហែលជា១ភាគ៣៤០ នៃអត្ថបទ ក៏ប៉ុន្តែបីបន្ទាត់នេះ វាតំណាងឲ្យឯកសាររាប់ម៉ឺនសន្លឹក ដែលនៅ អ.វ.ត.ក នេះ។ ដូច្នេះ ខ្ញុំរំឭករឿងនេះ ដើម្បីបង្ហាញថា ខ្ញុំពិតជាបានសហការជាមួយនឹងតុលាការគ្រប់ជាន់ថ្នាក់ ដែលជាតុលាការផ្លូវការរបស់ជាតិ។ តាំងពីតុលាការយោធារហូតដល់ អ.វ.ត.ក ដែលជាតុលាការរួមគ្នារវាងអង្គសហប្រជាជាតិហើយនិងជាតិ។

ទីពីរ ខ្ញុំសូមថ្លែងអំពីការសារភាពរបស់ខ្ញុំ។ ដំបូង កាលនៅជាមួយនឹងសហចៅក្រមស៊ើបសួរទាំងអស់គ្នាបានគិតថា និយាយត្រឹមតែក្របខ័ណ្ឌយុត្តាធិការ គឺពីថ្ងៃ១៥ មេសា ១៩៧៥ រហូតដល់ ៦ មករា ១៩៧៩។ ក៏ប៉ុន្តែមកដល់ទីនេះ មានបញ្ហាមួយចោទឡើងគឺត្រូវនិយាយអំពីបញ្ហានៅម-១៣ ក្នុងឋានៈជាយុត្តិសាស្ត្រ។ បើតាមខ្ញុំស្មាន យុត្តិសាស្ត្រហ្នឹង ប្រែមកពាក្យបារាំង *ស៊ីរីប្រ៊ីដង់* ខ្ញុំបំពេញតាមសំណូមពររបស់តុលាការទៀត។ ហើយដល់ក្រោយមក នៅក្នុងអង្គជំនុំជម្រះនេះសួរខ្ញុំតទៅទៀត អំពីរឿងក្រោយ៧ មករា ១៩៧៩ ខ្ញុំបានរាយការណ៍ទៀត។

ដូចនេះ ឯកសារដែលខ្ញុំបានដាក់ជូនអង្គជំនុំជម្រះនេះ គឺជាសំយោគមតិ រឿងដែលបានឆ្លងកាត់ហើយនៅក្នុងតុលាការនេះ ដើម្បីបង្ហាញជូនអំពីទិដ្ឋភាពរួមនៃឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តទៅជាតិប្រជាជនខ្ញុំ។

បើគិតពីអាយុជីវិតមនុស្សមួយលានជាងនាក់ ខ្ញុំអត់ភ្លេចទេ រួមទាំងបងប្អូនខ្ញុំខ្លះផង ប៉ុន្តែខ្ញុំមិននិយាយដល់រឿងនោះទេ។ អាយុជីវិតប្រជាជន តើវាទុក្ខវេទនាយ៉ាងម៉េច? វារងកម្មយ៉ាងម៉េច ដោយសារមាគ៌ាឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា? ខ្ញុំទទួលស្គាល់ទាំងអស់។

[១១:៥៦:៥១]

ក្នុងនេះ នៅអង្គសវនាការនេះ ខ្ញុំប្រើពាក្យមួយថ្មីទៀត ឧក្រិដ្ឋកម្មទាំងអស់របស់បក្សកុម្មុយនីស្ត ខ្ញុំសូមទោសជាតិប្រជាជនខ្ញុំ ក្នុងឋានៈខ្ញុំជាសមាជិកបក្សម្នាក់ មួយរូប។ ក្នុងឋានៈជាសមាជិកមួយរូប ប៉ុល ពត សង្ឃឹមលើបក្ខជនរបស់ខ្លួនរាប់ម៉ឺននាក់ បានប៉ានលើកមាគ៌ានេះ។ ដូច្នេះ វាក្នុងអាប៉ុន្មានម៉ឺននាក់ ពិតជាមានរូបខ្ញុំបាទមួយ ដែលខ្ញុំត្រូវតែទទួលសូមទោសជាតិប្រជាជនខ្ញុំ ត្រូវតែទទួលខុសត្រូវខាងចិត្ត ចំពោះជាតិ ប្រជាជនខ្ញុំ។

ដោយឡែក នៅមន្ទីរម-១៣ ខ្ញុំសរសេរនៅក្នុងកថាខណ្ឌទី៨៥ របស់ខ្ញុំ ចំនួនមនុស្សដែលបានស្លាប់បាត់បង់ជីវិតទៅយ៉ាងតិច១២.៣៨០នាក់។ ទោះបីម្សិលមិញ ម្សិលម្ង៉ៃប៉ុន្មានថ្ងៃមុននេះ លោកជំទាវព្រះរាជអាជ្ញាខ្មែរលោកមានប្រសាសន៍ថា ១២.២៧៣នាក់ ខ្ញុំអត់ទាមទារចុះលេខនេះទេ បើឡើងមាន។ ពិតជាមានឯកសារខ្លះសម្រាប់ឲ្យឃើញថា ចំនួនប៉ុណ្ណឹងមិនគ្រប់គ្រាន់ទេ ដូចនេះខ្ញុំនៅតែរក្សាពាក្យថា ១២.៣៨០នាក់យ៉ាងតិច។ ឧក្រិដ្ឋកម្មទៅលើមនុស្សទាំងអស់នោះ ខ្ញុំទទួលស្គាល់ អត់កែប្រែទេជារៀងរហូត។ កថាខណ្ឌទី៨៥ របស់ខ្ញុំ ខ្ញុំបញ្ជាក់ទទួលស្គាល់ជីវិតមនុស្សនៅក្នុងនោះ រួមក្នុងនោះវាមានខ្មែរ វាមានបរទេស។ បរទេសនេះ មានបស្ចិមប្រទេសប្អូននាក់ ហើយនិងវៀតណាមមួយចំនួន។ រួចស្រេចទៅហើយ ខ្ញុំទទួលស្គាល់ឧក្រិដ្ឋកម្មនេះ អត់ប្រកែក។

កថាខណ្ឌទី៨៦ ដដែលទេ ខ្ញុំថារឿងដែលបានឆ្លងកាត់សវនាការនេះ ខ្ញុំទុកជូនអង្គសវនាការជំនុំជម្រះ ឬវិភាគ។ ដល់ចុងបញ្ចប់ ខ្ញុំចែកអត្ថបទរបស់ខ្ញុំដែលសរសេរបីទំព័រចុងក្រោយជាបីចំណែក។ ចំណែកទីមួយ ខ្ញុំនិយាយពីខ្លួនខ្ញុំចំពោះជាតិប្រជាជនខ្ញុំទាំងមូល។ ខ្ញុំនៅតែរក្សាគោលជំហរទទួលខុសត្រូវចំពោះជាតិ ប្រជាជនខ្ញុំ ក្នុងឋានៈខ្ញុំជាបក្ខជនមួយរូប ដែលបក្សឧក្រិដ្ឋ។ ពីលើកមុន ខ្ញុំស្មានថាជាបក្សរំដោះជាតិប្រជាជាតិ រួចឥឡូវឃើញធាតុពិតជាបក្សឧក្រិដ្ឋ ខ្ញុំទទួលស្គាល់ ក្នុងឋានៈជាខ្ញុំបក្ខជន

មួយរូប ខ្ញុំអត់គេចពីសេចក្ដីទទួលខុសត្រូវនេះទេ។

ទីពីរ នៅក្នុងមន្ទីរស-២១ ខ្ញុំនិយាយច្បាស់ ចំពោះអាយុជីវិតមនុស្ស១២.៣៨0នាក់ យ៉ាងតិចនេះ ខ្ញុំនៅតែទទួលស្គាល់ថា ខ្ញុំបានប្រព្រឹត្តបទឧក្រិដ្ឋ។ មនុស្សទាំងអស់នេះស្លាប់នៅក្នុងមន្ទីរស-២១ ចៀសមិនរួច។ ក្នុងឋានៈខ្ញុំជាប្រធានស-២១ ខ្ញុំសូមទទួលខុសត្រូវតែម្នាក់ឯង សូម្បីមិត្ត ហ៊ី ដែលជាអនុប្រធានខ្ញុំគេរស់នៅក៏ខ្ញុំមិនទាមទារឲ្យគេមកប្រឈមនឹងតុលាការជាមួយនឹងខ្ញុំដែរ។ ហើយសូមបញ្ជាក់ជាឱឡារិកថា ម៉ម ណៃ មិនមែនជាសមាជិកគណៈកម្មាធិការមន្ទីរស-២១ ទេ។ ដូច្នេះ ទោះបីមិត្ត ហ៊ី គាត់រស់នៅក៏ខ្ញុំមិនទាមទារឲ្យមកប្រឈមនឹងតុលាការ ខ្ញុំសូមទទួលខុសត្រូវតែម្នាក់ឯងគត់ចំពោះឧក្រិដ្ឋកម្មនេះ។

[១២:00:១៧]

ចុងបញ្ចប់ ផ្នែកទីបីនៃសេចក្ដីថ្លែងការណ៍របស់ខ្ញុំសរសេរ ខ្ញុំបានឮមតិរបស់អ្នកជំនាញចិត្ត-សាស្ត្រ។ ទីមួយ គឺអ្នកស្រី ហ្វៀលបូ និងលោក កាស៊ុន បូណាត ខ្ញុំបានលើកសំណួមពររបស់អ្នកទាំងពីរថា ខ្ញុំត្រូវធ្វើដូចម្ដេច ដើម្បីឲ្យមនុស្សជាតិទាំងមូលលោកទទួលស្គាល់ខ្ញុំជាមនុស្សម្នានឹងគេតទៅទៀត? នេះឈរលើវិទ្យាសាស្ត្របច្ចេកទេស ដើម្បីនិយាយ ខ្ញុំមិនិយាយឈរលើពុទ្ធប្រវត្តិទេ បើពុទ្ធប្រវត្តិវាមានបញ្ហាអង្គុលីមាលត្ថេ មួយទៀតដែលខ្មែរយើងជឿ អ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ឲ្យតម្លៃ។

ដូចនេះ ខ្ញុំបាននៅពេលដែល ដុកទ័រ ឈឹម សុធារ៉ា គាត់អញ្ជើញមកនៅទីនេះឲ្យសក្ខីភាព ខ្ញុំបានសួរគាត់ថា តើខ្ញុំធ្វើយ៉ាងដូចម្ដេចដើម្បីរួមចំណែករំលែកទុក្ខសោករបស់ប្រជាជនខ្ញុំបានទូទៅប្រទេស។ នេះជាបញ្ហាដែលកន្លងផុតទៅ ហើយមាននៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្ញុំ។

តទៅទៀត ខ្ញុំសូមនិយាយអំពីដំណើរការតាមដីកាតុលាការលោកបានអនុគ្រោះឲ្យខ្ញុំមានមតិ។ ខ្ញុំមកជាប់នៅមន្ទីរឃុំឃាំងរបស់តុលាការយោធាពីថ្ងៃ៨ គេចុះបញ្ជីថ្ងៃ១០ តែតាមពិតពីថ្ងៃ៨ ខែឧសភា ១៩៩៩។ ការពិភាក្សារវាងសហប្រជាជាតិនិងរដ្ឋាភិបាលចេះតែដំណើរការ មានរអាក់រអួលម្ដង ខ្ញុំអត់មាត់ ដល់ក្រោយមកដំណើរការទៅវិញ ដោយឃើញអ្នកស្រី ម៉ារី រ៉ូប៊ីនសុន មកដល់ត្បូក្ស។ កិច្ចដំណើរបន្តទៅទៀត ដល់ខ្ញុំមកដល់ អ.វ.ត.ក ឃើញច្បាប់ដែលឡាយព្រហស្ដលេខាដោយព្រះករុណា ច្បាប់ថ្ងៃ២៧ តុលា ២០០៤ ដែលចែងថា មនុស្សដែលត្រូវប្រឈមនឹងតុលាការតែពីរក្រុមទេ។ គឺអ្នកដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ។ បញ្ហានេះ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបសួរបានបញ្ជាក់ច្បាស់ គឺអចិន្ត្រៃយ៍មជ្ឈិមបក្សប្រាំពីរនាក់។ ហើយខ្ញុំសូមបញ្ជាក់ថា អចិន្ត្រៃយ៍មជ្ឈិមបក្សនេះ ប្រាំពីរនាក់នេះ វាអនុម័តដោយមហាសន្និបាតឆ្នាំ១៩៧៦ ដល់ចាប់មនុស្សអស់ទៅ មហា

សន្និបាតវិសាមញ្ញឆ្នាំ១៩៧៨ ជ្រើសរើសថ្មីថែម។ នៅសល់តែប្រាំមួយនាក់ សម្លាប់ចោលអស់ពីរនាក់ សោ ភឹម មួយ ហើយនិង វន វេត មួយ ជ្រើសរើសថ្មីបន្ថែមម្នាក់ ខៀវ សំផន។ ដូច្នេះ៖ ទីមួយ ប៉ុល ពត, ទីពីរ នួន ជា, ទីបី អ៊ៀង ជឿន, ទីបួន អៀង សារី, ទីប្រាំ សុន សេន, ទីប្រាំមួយ ខៀវ សំផន។

[១២:០៣:៣៥]

ដូចនេះ អាអ្នកដឹកនាំកម្ពុជាប្រជាធិតេយ្យ អ្នកណាក៏ស្គាល់ដែរ ដឹងដែរថាជា ក្បាលម៉ាស៊ីនសម្រាប់ចេញមាគ៌ានយោបាយ ប្រាំមួយនាក់។ ខ្ញុំបានរាយការណ៍នៅក្នុងសេចក្ដីកំណត់របស់ខ្ញុំច្បាស់។ ដូចនេះ តាមស្មារតីនៃសេចក្ដីសម្រេច នៃដីកាបញ្ជូនសំណុំរឿងរបស់សហចៅក្រមស៊ើបសួរ អ្នកដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ប្រាំមួយនាក់។ ប្រាំពីរនាក់ ពីដើម៧៥ មក ៧៦ មក មកដល់ពី៧៨ ទៅ ប្រាំមួយនាក់។

ដោយឡែក ដីកាបញ្ជូនសំណុំរឿងទៅស៊ើបសួររបស់ចៅក្រមស៊ើបសួរដែរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបសួរដែរ។ ទទួលស្គាល់ឯកសារថ្ងៃ៣០ មីនា ១៩៧៦ ថាជាឯកសារគោល ប្រគល់សិទ្ធិអំណាចមនុស្សកម្ទេចមនុស្ស។ ហើយខ្ញុំបានវិភាគហើយ នរណាដែលគ្មានឈ្មោះនៅក្នុងនោះ គ្មានអំណាចសិទ្ធិកម្ទេចទេ។ យកហេតុផលអីមកលុបអាគោលគំនិតនេះអត់បានទេ ខ្ញុំមានភ័ស្តុតាងជូន កុយ ធួន សម្រេចសម្លាប់មនុស្សត្រូវរងគ្រោះយ៉ាងម៉េច? ណាត ពីលើកមុន ខ្ញុំអត់បានច្បាស់ទេ ឥឡូវខ្ញុំឃើញឯកសារ ខ្ញុំជឿថា ណាត ក៏អាចគ្រោះថ្នាក់ដោយសារបញ្ហានេះដែរ។ រស់ ញឹម (សូមទោស) កង ចាប ហៅ សែ លេខាភូមិភាគឧត្តរ ភ្លើៗទៅចាប់បងប្អូនប្រពន្ធ ខៀវ សំផន យកដាក់គុក។ ដឹងដល់ប៉ុល ពត ភ្លាម ប៉ុល ពត ដោះលែងបងប្អូនប្រពន្ធ ខៀវ សំផន ហើយចាប់ កង ចាប ហៅ សែ ដាក់គុក។

ដូច្នេះ រឿងសម្រេចកម្ទេចអត់បានទេ ខ្ញុំបានវិភាគបញ្ហានេះ ជាគោលការណ៍មាគ៌ាយ៉ាងម៉េច? មាគ៌ាគឺប្រជាធិបតេយ្យប្រមូលផ្ដុំ។ អ្វីដែលហៅថា ប្រជាធិបតេយ្យប្រមូលផ្ដុំ? ប្រជាធិបតេយ្យប្រមូលផ្ដុំ ខ្ញុំសូមនិយាយពាក្យបារាំងមួយម៉ាត់ចុះ *ដេម៉ូក្រាស៊ី សង់ត្រាល់លីហ្សេ* ឬក៏សង់ត្រាល់លីស្ស ដេម៉ូក្រាហ្វីក(និយាយភាសាបារាំង)។ បើនិយាយភាសាដែលគេពន្យល់ឲ្យស្រួលស្ដាប់ គេថា សមូហភាពដឹកនាំបុគ្គលទទួលខុសត្រូវដោយឡែក។ សមូហភាពគឺអី? សមូហភាព គឺបក្សទាំងមូល ដែលតំណាងឲ្យលេខាបក្ស គឺប៉ុល ពត។ ដូច្នេះគ្រប់បញ្ហា ដោយឡែកបញ្ហាកម្ទេច។ លេខាភាគអ្នកឯងមានសិទ្ធិកម្ទេចមែន ក៏ប៉ុន្តែអ្នកឯងប្រាស់ចាកការដឹកនាំរបស់បក្ស របស់សមូហភាព អ្នកឯងត្រូវតែគេចាប់។

នេះវាច្បាស់អ៊ីចឹង។ ដូច្នេះ ឯកសារនេះ ដូចលោកមេធាវីខ្ញុំបាននិយាយរួចហើយ មានមនុស្សប៉ុន្មាននាក់ ខ្ញុំអត់និយាយតទៅទៀតទេ។

[១២:០៦:៤៣]

សរុបមក គោលបំណងនៃការកាត់ទោសខ្មែរក្រហម ដើម្បីអី? ពិតជាដើម្បីរកយុត្តិធម៌ជូនប្រជាជនកម្ពុជាទូទាំងប្រទេស។ ទីពីរ ដើម្បីសុខសន្តិភាពរបស់ប្រជាជនកម្ពុជាតទៅទៀត គ្មានសង្គ្រាម គ្មានការប៉ះបោរប្រឆាំងតប។ ទីបី ដើម្បីផ្សះផ្សាជាតិ។ នេះគោលបំណងដែលមានចែង ខ្ញុំជឿជាក់ថា មាននៅក្នុងគោលគំនិតច្បាប់ច្បាស់លាស់។

ផ្ទាល់ខ្លួនខ្ញុំ ឧក្រិដ្ឋកម្មនៅស-២១ អត់បដិសេធទេ រឿងរ៉ាវដែលមានការឃុំឃាំងខ្ញុំ ចាប់តាំងពីថ្ងៃ៨ ខែឧសភា ១៩៩៦ រហូតមកដល់បច្ចុប្បន្ននេះ វាដប់ឆ្នាំ ប្រាំមួយខែ ដប់ប្រាំបីថ្ងៃ។ ដប់ប្រាំបួនថ្ងៃហើយ។ ខ្ញុំទុកជារយៈកាលដែលខ្ញុំបានសហការជាមួយនឹងតុលាការ ខ្ញុំអត់ទាមទារថា អាហ្នឹងខុសច្បាប់ អាហ្នឹងស្អីទេ ខ្ញុំទុកជារដ្ឋការដែលខ្ញុំបានសហការជាមួយតុលាការ ប៉ុន្តែបើខ្លឹមសារនេះ ដែលខ្ញុំបានរាប់រៀបរួចមកហើយ គោលគំនិតច្បាប់ដែលបង្កើត អ.វ.ត.ក នេះ ខ្ញុំសូមលើកជាសំណូមពរជូនអង្គជំនុំជម្រះមេត្តាដោះលែងខ្ញុំ។ ខ្ញុំសូមចប់ហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញជនជាប់ចោទក្រោកឈរ!

ដោយជម្រៅនៃសេចក្តីសន្និដ្ឋានបញ្ចប់ និងសម្តីចុងក្រោយដែលលោកបាននិយាយអម្បាញ់មិញនេះ ឃើញថាមានវែង ហើយចុងក្រោយគឺជនជាប់ចោទសូមឲ្យដោះលែងលោកក្រោយពេលចប់សវនាការនេះទៅ។ សំណួរសួរថា ការឲ្យសូមឲ្យដោះលែងនេះ ដោយហេតុនៃការឲ្យរួចផុតពីបទចោទប្រកាន់ ឬក៏ដោយមូលដ្ឋានដោយសារស្ថានសម្រាលនៃការសម្រេចទោស ដោយលោកបានរៀបរាប់អំពីកិច្ចសហការរបស់លោកជាមួយនឹងតុលាការនៅក្នុងអំឡុងពេលកន្លងមក ហើយធៀបជាមួយនឹងគិតគូរពិចារណាជាមួយនឹងអំឡុងពេលដែលលោកទទួលរងការឃុំខ្លួនតាំងពីឆ្នាំ១៩៩៩ រហូតដល់ពេលនេះ ដើម្បីឲ្យអង្គជំនុំជម្រះ ក៏ដូចជាសាធារណជន បានយល់ច្បាស់លាស់ពីបញ្ហានេះ ហើយជាពិសេសអង្គជំនុំជម្រះនឹងងាយក្នុងការសម្រេចសេចក្តី ពីព្រោះហេតុគឺមាននីតិវិធីនៃកិច្ចដំណើរការ គឺមានច្រើនរូបភាព។

លោកអាចបញ្ជាក់បញ្ហានេះច្បាស់លាស់បានទេ?

[១២:១១:០៦]

**ជនជាប់ចោទ៖**

សូមអរគុណលោកប្រធាន។ ចំពោះសំណួរចុងក្រោយនេះ សមត្ថភាពរបស់ខ្ញុំក្នុងការវិភាគបាន ត្រឹមដូចដែលខ្ញុំបានរាយការណ៍ជូនតែប៉ុណ្ណេះ។ តើខ្ញុំសូមឲ្យរួចខ្លួននេះ ដោះលែងខ្ញុំ មិនមែនឲ្យរួចខ្លួនទេ គឺដោះលែងខ្ញុំនេះ ដោយអាងលើមូលហេតុអី? ខ្ញុំអត់មានសម្ថតភាពពន្យល់ទេ ខ្ញុំសូមទុកឲ្យបើសិនជា លោកប្រធានអនុញ្ញាតឲ្យមេធាវីខ្ញុំ លោក ការ សាវុត្ថ បង ការ សាវុត្ថ បញ្ជាក់ជូនតុលាការ ដោយគោរព។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីណាឡើងតទៀតទេ ហើយចៅក្រមអង្គជំនុំជម្រះ តើមានអីបញ្ជាក់ទៀតទេ?

បើមិនមានទេ សូមជនជាប់ចោទអង្គុយចុះ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដំណើរការនៃនីតិវិធីកាន់តែវែង ហើយវាមានលក្ខណៈកាន់តែចម្លែកទៅនៅក្នុងកិច្ច ដំណើរការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលមិនធ្លាប់មាននៅក្នុងកម្រិតជាតិទេ។ប៉ុន្តែ ដោយសារមានមតិភាគច្រើននៃចៅក្រមអង្គជំនុំជម្រះ ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ជនជាប់ចោទ ដែលបាននិយាយចុងក្រោយអម្បាញ់ចង្អុលបង្ហាញទៅមេធាវីការពារក្ដីរបស់គាត់ ដោយគាត់ថាអ្វីដែល គាត់បាននិយាយទៅតាមកម្រិតនៃការយល់ដឹងរបស់គាត់ លើវិស័យច្បាប់ក្នុងសំណុំរឿងនេះ។

អ៊ីចឹងទេ ដើម្បីឲ្យបានច្បាស់លាស់អង្គជំនុំជម្រះសូមផ្ដល់វេទិកានេះ ដល់លោក ការ សាវុត្ថ ដើម្បីបញ្ជាក់ជំហរអំពីការដែលសុំឲ្យដោះលែងជនជាប់ចោទ ដែលសំណូមពរនេះ គឺស្របគ្នារវាងជន ជាប់ចោទជាមួយនឹងមេធាវីការពារក្ដីជាតិ។ អង្គជំនុំជម្រះទុកផ្ដល់លទ្ធភាពពេលវេលាប្រាំនាទី ការដែល ឲ្យមេធាវីមានការចាប់អារម្មណ៍បញ្ជាក់លើចំណុចនេះ។ សូមអញ្ជើញ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរព អង្គសវនាការទាំងមូល។ ខ្ញុំសូមថ្លែងអំណរគុណដែលបានឲ្យខ្ញុំបញ្ជាក់ជូន។ ពេលដែលកូនក្ដីខ្ញុំសុំឲ្យខ្លួន គាត់រួចខ្លួន ឲ្យដោះលែងខ្លួនគាត់នេះ ដោយសំអាងទៅលើចំណុចពីរ។

[១២:១៤:៤៨]

ចំណុចទីមួយ នៅវាក្យខណ្ឌ១២៩ ថៅក្រមស៊ើបអង្កេតបានបញ្ជាក់ច្បាស់ហើយថា គាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យទេ។ នេះចំណុចទីមួយ។

ចំណុចទីពីរ ក្នុងការសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ថារយៈកាលទីមួយ ពីថ្ងៃទី១៧ មេសា ៧៥ មកដល់ថ្ងៃទី៣០ មីនា ១៩៧៩-- មក៧៦ គាត់ជាអនុប្រធានស-២១។ ដូច្នេះ អនុប្រធានអត់មានត្រូវយកមកកាត់ទោសនៅទីនោះទេ។ គាត់ជាអនុប្រធានធ្វើការតាមបង្គាប់បញ្ជាប្រធាន។ ដូច្នេះជានេះជាចំណុចទីមួយ។

ទីពីរសំអាងទៅលើលិខិតចុះថ្ងៃទី៣០ មីនា ១៩៧៦ មជ្ឈិមបក្ស គឺអចិន្ត្រៃយ៍បក្ស បានចាត់តាំងមនុស្សបួនក្រុម គឺប្រគល់សិទ្ធិឲ្យមនុស្សបួនក្រុម គឺលេខាភូមិភាគទាំងប្រាំពីរ តំបន់ឯករាជ្យ លេខាតំបន់ឯករាជ្យ គឺ ប៉ុល ពត មន្ទីរជុំវិញមជ្ឈិម គឺ ខៀវ សំផន ជាអ្នកសម្រេចកម្ទេចមនុស្ស និងអគ្គសេនាធិការ គឺ សុន សេន។ ដូច្នេះ គេប្រគល់អាងលិខិតនេះ គឺច្បាស់លាស់ គេចាត់តាំងមនុស្សបួនក្រុមឲ្យទទួលខុសត្រូវក្នុងការសម្លាប់ សម្រេចសម្លាប់អ្នកណា ទុកអ្នកណា។ អ៊ីចឹងបើគេប្រគល់ឲ្យបួនក្រុមនេះហើយយើងឃើញឈ្មោះបួនក្រុមនេះហើយ មិនអាចចោទប្រកាន់ តា ឌុច ឬក៏អ្នកដទៃទៀតថា មានសិទ្ធិសម្រេចសម្លាប់ទេ។ ហើយនៅក្នុងមាត្រា២៣៨ ដែលខ្ញុំបានជម្រាបជូនអំមិញហ្នឹង អ្នកដែលបញ្ជាឲ្យសម្លាប់ អ្នកហ្នឹងហើយដែលទទួលខុសត្រូវក្នុងការសម្លាប់ មិនមែនអ្នកអនុវត្តបញ្ជាទេ ដោយមូលហេតុទាំងអស់នេះហើយ។ ដែលកូនក្តីខ្ញុំសូមឲ្យដោះលែងគាត់ ពីព្រោះគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ហើយគាត់ក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតខ្ពស់ចំពោះឧក្រិដ្ឋកម្មទេ គឺគាត់ជាអ្នកបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ បក្សកុម្មុយនីស្តកម្ពុជាគឺជាឃាតកសម្លាប់ប្រជាជនកម្ពុជារាប់លាននាក់។ ដូច្នេះ មូលហេតុនេះហើយដែលខ្ញុំសំណូមពរកូនក្តីខ្ញុំសំណូមពរឲ្យដោះលែងគាត់។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញថៅក្រម ខាតវ៉ាយច៍។

**ថៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន ដែលអនុញ្ញាតឲ្យខ្ញុំមានឱកាសសួរនេះ។ លោក ការ សាវុត្ថ តើខ្ញុំអាចយល់ដូច្នេះថា ជនជាប់ចោទសុំឲ្យកាត់រួចផុតពីបទចោទ តើដូច្នេះមែនដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកជំទាវ ថៅក្រមអន្តរជាតិ បញ្ហាដែលសុំឲ្យដោះលែងនេះ បានសេចក្តីថា សុំ

ឲ្យរួចផុតពីបទចោទហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមសម្រាកមួយនាទី ហើយខាងឌីវីឌី ចាត់ចែងរៀបចំឌីវីឌី។

*(ខាងសោតទស្សន៍រៀបចំឌីវីឌី ពីម៉ោង១២:១៨នាទី ដល់ម៉ោង១២:២០នាទី)*

[១២:២០:៣៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដំណើរការនៃនីតិវិធីស្តាប់នូវសេចក្តីថ្លែង នូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីឃើញថារបស់ភាគីឃើញថាដល់ទីបញ្ចប់បានចប់សព្វគ្រប់ហើយ។

ក្រោយពីបានបញ្ចប់ការពិភាក្សាដេញដោលលើភ័ស្តុតាង និងក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលដោយផ្ទាល់មាត់របស់ភាគីរួចមក ក្នុងនាមអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខ្ញុំសូមជម្រាបជូនដល់ភាគីនានា និងសាធារណជនទាំងអស់ឲ្យបានជ្រាបដូចខាងក្រោមនេះ៖

អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដំណើរការសវនាការជំនុំជម្រះលើអង្គសេចក្តី សំណុំរឿងលេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ បទល្មើសដែលមានបញ្ញត្តិនៅក្នុងមាត្រា ៥០០, ៥០១ និង៥០៦។

ដំណើរការសវនាការពិភាក្សាដេញដោល ពិនិត្យភ័ស្តុតាងបានចាប់ផ្តើមពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ចំណាយរយៈពេលអស់៧២ថ្ងៃ និងសវនាការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគី ចាប់ផ្តើមទីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលចំណាយពេលវេលាអស់៥ថ្ងៃ។ គិតមកទល់នឹងពេលនេះ កិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តី លើសំណុំរឿងលេខ០០១ បានប្រព្រឹត្តទៅអស់រយៈពេលសរុប៧៧ថ្ងៃ។ នាពេលនេះដំណើរការសវនាការលើអង្គសេចក្តីចំពោះសំណុំរឿងលេខ០០១ ឃើញថា ចប់សព្វគ្រប់ហើយ។

[១២:២៣:១០]

មុននឹងប្រកាសបញ្ចប់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណ

ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា មានភាគីនៃរឿងក្ដីដែលបានចូលរួម ដែលរួមមាន៖ ដើមបណ្ដឹងរដ្ឋប្បវេណីនិងអ្នកដែលរស់រានមានជីវិតពីមន្ទីរសន្ដិសុខស-២១ មន្ទីរសន្ដិសុខស-២៤ ឬព្រៃស សាក្សី និងអ្នកជំនាញ ដែលបានផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះកន្លងមក។ មកពីការិយាល័យរដ្ឋបាល និងអង្គភាពផ្នែកចំណុះដែលមានភារកិច្ចពាក់ព័ន្ធនឹងកិច្ចដំណើរការសវនាការ ជាពិសេសអង្គភាពបកប្រែភាសា និងដោយឡែកចំពោះអ្នកបកប្រែភាសានៅក្នុងសាលសវនាការនេះ។ ផ្នែកខាងសោតទស្សន៍ និងរូបភាព។ អង្គភាពជនរងគ្រោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ អង្គភាពគាំពារការពារក្ដី។ អនុរក្សមន្ទីរឃុំឃាំង។ ផ្នែកកិច្ចការសាធារណៈ។ ផ្នែកសន្ដិសុខនិងសុវត្ថិភាព និងផ្នែកសេវាកម្មទូទៅ។ ផ្នែកផ្សេងៗទៀត និងអ្នកដទៃផ្សេងទៀតទាំងភាគីជាតិ និងទាំងភាគីអន្តរជាតិ។ មន្ត្រីបុគ្គលិកមកពីស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្នែកសន្ដិសុខទូទៅ ផ្នែកពន្លត់អគ្គីសភ័យ ផ្នែកពេទ្យ និងផ្នែកដទៃទៀត និងមន្ត្រីបុគ្គលិកមកពីអង្គការក្រៅរដ្ឋាភិបាលមួយចំនួនមានដូចជា អង្គការចិត្តសាស្ត្រសង្គមអន្តរវប្បធម៌ ធី.ភី.អូ ជាដើម។ ដែលអ្នកទាំងអស់ដូចបានរៀបរាប់ខាងលើនេះបានចូលរួម និងជួយជ្រោមជ្រែងគាំទ្រដល់កិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលសដំបូងលើសំណុំរឿងលេខ០០១ អស់ពីកម្លាំងកាយចិត្តបញ្ញាស្មារតី តាំងពីថ្ងៃចាប់ផ្ដើមដំបូងរហូតដល់ទីបញ្ចប់ប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អប្រសើរ។

[១២:២៥:០៨]

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបិទកិច្ចពិភាក្សាដេញដោល ពិនិត្យភ័ស្តុតាងលើសំណុំរឿងក្ដីលេខ០០១ត្រឹមនេះ។ អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបដល់ភាគី និងសាធារណជនបានជ្រាបថាបន្ទាប់ពីនេះទៅ អង្គជំនុំជម្រះសាលសដំបូងនឹងចាប់ផ្ដើមនូវកិច្ចការថ្មីមួយទៀតរបស់ខ្លួន គឺការពិភាក្សាពិចារណា សម្រេចសេចក្ដី និងរៀបចំនូវសាលក្រមវិនិច្ឆ័យសេចក្ដីលើសំណុំរឿងលេខ០០១នេះ។

ទាក់ទងទៅនឹងកាលបរិច្ឆេទសវនាការប្រកាសសាលក្រម អង្គជំនុំជម្រះសាលាដំបូងមិនទាន់អាចកំណត់ជាក់លាក់បានទេ ដោយហេតុថាសំណុំរឿងក្ដីនេះមានទ្រង់ទ្រាយធំ និងត្រូវរៀបចំជាបីភាសាផ្សេងៗគ្នា ភាសារបស់អ.វ.ត.ក។ អង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការប្រកាសសាលក្រមដល់ភាគី និងសាធារណជនបានជ្រាបជាមុនក្នុងកាលវេលាសមស្របមុនពេលប្រកាសសាលក្រម។

អង្គជំនុំជម្រះសាលាដំបូង ប្រកាសផ្អាកសវនាការថ្ងៃនេះត្រឹមនេះ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ឯកាលបរិច្ឆេទកំណត់ឲ្យនាំខ្លួនជនជាប់ចោទមកកាន់សាលសវនាការក្នុងឱកាសតុលាការប្រកាសសាលក្រម អង្គជំនុំជម្រះនឹងចេញដីកាបង្គាប់ជាពេលក្រោយក្នុងកាលវេលាសមស្របឲ្យបានមុនសវនាការ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១២:២៦នាទី]*